ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP

# គណនេយ្យភាពរបស់សាលារៀន

## ការចូលរួមរបស់សហគមន៍ ក្នុងការងារគ្រប់គ្រងរបស់សាលារៀន កម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅកម្ពុជា




ណូ ហ្វាតា និង ហេង គ្រេង
មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ


ខែមករា ឆ្នាំ២០១៦

# គណនេយ្យភាពរបស់សាលារៀន

## ការចូលរួមរបស់សហគមន៍ក្នុងការងារគ្រប់គ្រងរបស់សាលារៀន
## កម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅកម្ពុជា

ឈួ ហ្វាតា និង ហេង គ្រេង

មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ខែមករា ឆ្នាំ២០១៦

## តារាងមាតិកា


បញ្ជីតារាង ........ v
បញ្ជីតួលេខ ........ vi
សេចក្ដីថ្លែងអំណរគុណ ........ vii
អក្សរកាត់ ........ viii
និយមន័យនៃពាក្យដែលប្រើ ........ ix
សេចក្ដីសង្ខេប ........ ១

១. សេចក្ដីផ្ដើម និងបរិបទ ........ ៤
គណនេយ្យភាពរបស់សាលារៀននៅកម្ពុជា ........ ៦
សំណួរសម្រាប់ការស្រាវជ្រាវ ........ ១០

២. ការពិនិត្យមើលឯកសារដែលមានស្រាប់ ........ ១១
គំរូជាលក្ខណៈអន្តរជាតិនៃគណនេយ្យភាពសាលារៀនសម្រាប់ការប្រតិបត្តិ ........ ១១
ការគ្រប់គ្រងដោយផ្អែកលើសាលារៀន ........ ១៤
ការចូលរួមរបស់សហគមន៍ និងគណនេយ្យភាពរបស់សាលារៀន ........ ១៦
គណនេយ្យភាព ស្នាដៃបំពេញការងាររបស់សាលារៀន និងការសិក្សារៀនសូត្ររបស់សិស្សានុសិស្ស ........ ១៦
វិធីសាស្ត្រអន្តរជាតិចំពោះគណនេយ្យភាពរបស់សហគមន៍សម្រាប់សាលារៀន ........ ១៧

៣. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២០
សំណាក ........ ២០
ការប្រើប្រាស់ឧបករណ៍ ........ ២២
ការវិភាគទិន្នន័យ ........ ២៣
ដែនកំណត់នៃការសិក្សា ........ ២៤

៤. លទ្ធផលរកឃើញ និងការវិភាគ ........ ២៦
លក្ខណៈ និងសមាសភាពរបស់គណៈកម្មការទ្រទ្រង់សាលារៀន ........ ២៦
ការចូលរួមជាទូទៅរបស់សហគមន៍នៅក្នុងការគ្រប់គ្រងសាលារៀន ........ ២៨
ការចូលរួមរបស់សហគមន៍ទៅតាមតំបន់ ........ ៣២
ការចូលរួមរបស់សហគមន៍តាមកម្រិតសាលារៀន ........ ៣៥
ការចូលរួមរបស់សហគមន៍ ៖ ការវិភាគលម្អិតមួយ ........ ៣៥
ការរៀបចំផែនការអភិវឌ្ឍសាលារៀន ........ ៣៥
ការត្រួតពិនិត្យការរៀនសូត្ររបស់សិស្ស ........ ៣៧
ការប្រមូល និងការគ្រប់គ្រងមូលនិធិ ........ ៣៨
ការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន ........ ៣៩
ការចែករំលែកបទពិសោធន៍ និងបំណិនជីវិត ........ ៤០
ការទប់ស្កាត់ភាពមិនប្រក្រតី ........ ៤១

ការកសាងសមត្ថភាព..........................................................................................................................៤២
ការបំពេញការងាររបស់សាលារៀន ...........................................................................................................៤៣
ការប្រមូល និងការប្រើប្រាស់ទិន្នន័យរបស់កុមារដែលគ្រប់អាយុចូលរៀន.........................................................៤៤
អត្រាបោះបង់ការសិក្សា និងអត្រាឡើងថ្នាក់ ..........................................................................................៤៤
ពេលវេលាដែលចំណាយទៅលើភារកិច្ចនៃការគ្រប់គ្រងសាលារៀន ..............................................................៤៥
គណនេយ្យភាពរបស់សាលារៀនដែលគេយល់ឃើញ ......................................................................................៤៥
សកម្មភាពវាយតម្លៃសាលារៀន...............................................................................................................៤៦
បញ្ហារបស់សាលារៀន ៖ ការយល់ឃើញរបស់នាយកសាលា ...........................................................................៤៧
បញ្ហារបស់សាលារៀន ៖ ការយល់ឃើញរបស់សិស្ស.....................................................................................៤៨
បញ្ហារបស់សាលារៀន ៖ បទពិសោធន៍របស់តំណាង NGO ...........................................................................៤៩
ការទទួលខុសត្រូវចំពោះភារកិច្ចនៃការបំពេញការងាររបស់សាលារៀន ...........................................................៥០
ការបោះពុម្ពផ្សាយរបាយការណ៍របស់សាលារៀន.........................................................................................៥១
ការបំពេញការងាររបស់សាលារៀនតាមការយល់ឃើញរបស់ SSC និងអ្នកដែលមិនមែន SSC...........៥៣
ការពេញចិត្តចំពោះការបំពេញការងាររបស់សាលារៀន .................................................................................៥៤
បញ្ហាប្រឈម .......................................................................................................................................៥៧
ការខ្វះការយល់ដឹងរបស់នាយកសាលាទៅលើតួនាទី និងការទទួលខុសត្រូវរបស់ SSC ....................៥៧
ការខ្វះការយល់ដឹងរបស់ SSCs ទៅលើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន...............................៥៨
ការលើកទឹកចិត្ត និងការគាំទ្រពីសហគមន៍ទាប.........................................................................................៥៩
បញ្ហានៃការប្រាស្រ័យទាក់ទង និងកិច្ចសហប្រតិបត្តិការ ..............................................................................៥៩
ការផ្តល់មូលនិធិ និងការរៃអង្គាសមូលនិធិ ..............................................................................................៦០
ការប្រតិបត្តិល្អរបស់ SSC ៖ ករណីរបស់សាលារៀនចំនួន២ ...........................................................................៦០

៥. ការពិភាក្សា.........................................................................................................................................៦៤
ការចូលរួមរបស់សហគមន៍ ....................................................................................................................៦៤
ការបំពេញការងាររបស់សាលារៀន ...........................................................................................................៦៥
៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ .............................................................................................................៦៧

សេចក្តីសន្និដ្ឋាន...................................................................................................................................៦៧
អនុសាសន៍...........................................................................................................................................៦៨
ពង្រឹងនូវការអនុវត្តសេចក្តីណែនាំរបស់ SSC ដែលមានស្រាប់ឡើងវិញ ៖ .....................................................៦៨
ការពង្រឹងសមត្ថភាពនាយកសាលា និង SSCs ........................................................................................៦៩
កែលម្អការសម្របសម្រួលក្នុងចំណោមតួអង្គសំខាន់ៗ ...............................................................................៦៩
ការពង្រឹងគណនេយ្យភាពផ្នែកហិរញ្ញវត្ថុ ................................................................................................៦៩
ការផ្តល់អំណាចដល់តួនាទីរបស់ក្រុមប្រឹក្សាឃុំ..........................................................................................៧០
ឯកសារយោង ........................................................................................................................................៧១

ឧបសម្ព័ន្ធ ..............................................................................................................................................៧៤

ឧបសម្ព័ន្ធ ក៖ កម្រងសំនួរសម្រាប់សម្ភាសន៍ (នាយក) ..... ៧៤
ឧបសម្ព័ន្ធ ខ៖ កម្រងសំនួរសម្រាប់សម្ភាសន៍ គណៈកម្មការទ្រទ្រង់សាលា..... ៨១
ឧបសម្ព័ន្ធគ៖ កម្រងសំនួរសម្រាប់សម្ភាសន៍ឪពុកម្តាយសិស្សដែលមិនមែនជាគណៈកម្មការទ្រទ្រង់សាលារៀន ..... ៨៧
ឧបសម្ព័ន្ធ ឃ៖ សំណួរណែនាំសម្រាប់ការសម្ភាសន៍ NGO..... ៩១
ឧបសម្ព័ន្ធ ង៖ សំណួរពិភាក្សាក្រុមជាមួយសិស្សានុសិស្ស ..... ៩២
ឧបសម្ព័ន្ធ ច៖ លិខិតយល់ព្រមចូលរួមក្នុងការសិក្សាស្រាវជ្រាវ ..... ៩៤
ឧបសម្ព័ន្ធ ឆ៖ លិខិតអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា..... ៩៦

## បញ្ជីតារាង

តារាងទី១ ៖ សេចក្តីណែនាំស្តីពីការចូលរួមរបស់ SSC នៅក្នុងសកម្មភាពរបស់សាលារៀន..... ៨
តារាងទី២ ៖ ចំនួនសំណាកនៅតាមខេត្តនីមួយៗទៅតាមស្ថានភាពរបស់សាលារៀន..... ២១
តារាងទី៣ ៖ គណនេយ្យភាពរបស់សាលារៀន ..... ៤៦
តារាងទី៤៖ បញ្ហារបស់សាលារៀនដោយផ្អែកលើការពិភាក្សាជាក្រុមជាមួយសិស្សចំនួន១២ក្រុមមកពីខេត្តចំនួន៥ និងរាជធានីភ្នំពេញ..... ៤៩

# បញ្ជីតួលេខ


តួលេខទី១ ៖ ការចូលរួមរបស់SSCនៅក្នុងសកម្មភាពនានារបស់សាលារៀន ........................................៣១
តួលេខទី២ ៖ ការចូលរួមរបស់ SSC នៅក្នុងសកម្មភាពរបស់សាលារៀនទៅតាមតំបន់.......................... ៣៣
តួលេខទី៣ ៖ កម្រិតនៃការអប់រំរបស់នាយកសាលានៅតាមតំបន់....................................................៣៤
តួលេខទី៤ ៖ ការចូលរួមរបស់ SSC នៅក្នុងការរៀបចំផែនការអភិវឌ្ឍសាលារៀន .................................៣៦
តួលេខទី៥ ៖ ការចូលរួមនៅក្នុងការពង្រឹងការចុះឈ្មោះចូលរៀន......................................................៣៧
តួលេខទី៦ ៖ ការចូលរួមរបស់ SSC ក្នុងការត្រួតពិនិត្យការរៀនសូត្ររបស់សិស្ស .................................៣៨
តួលេខទី៧ ៖ ការចូលរួមរបស់ SSC នៅក្នុងការប្រមូល និងគ្រប់គ្រងមូលនិធិ .....................................៣៩
តួលេខទី៨ ៖ ការចូលរួមរបស់ SSC នៅក្នុងការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន .. ៤០
តួលេខទី៩ ៖ ការចូលរួមរបស់ SSC នៅក្នុងការចែករំលែកបទពិសោធន៍ និងបំណិនជីវិត....................... ៤១
តួលេខទី១០ ៖ ការចូលរួមរបស់ SSC ក្នុងការទប់ស្កាត់ភាពមិនប្រក្រតី ..............................................៤២
តួលេខទី១១ ៖ ការចូលរួមរបស់ SSC ក្នុងការកសាងសមត្ថភាព .......................................................៤៣
តួលេខទី១២ ៖ ការប្រមូលទិន្នន័យកុមារគ្រប់អាយុចូលរៀន............................................................ ៤៤
តួលេខទី១៣ ៖ ការប្រើប្រាស់ទិន្នន័យរបស់សាលារៀន ................................................................... ៤៤
តួលេខទី១៤ ៖ ពេលវេលាដែលគេចំណាយទៅលើភារកិច្ចគ្រប់គ្រងសាលារៀន ................................... ៤៥
តួលេខទី១៥ ៖ សកម្មភាពវាយតម្លៃរបស់សាលារៀន.......................................................................៤៧
តួលេខទី១៦ ៖ បញ្ហារបស់សិស្សនៅតាមសាលារៀន .......................................................................៤៧
តួលេខទី១៧ ៖ បញ្ហារបស់គ្រូបង្រៀននៅតាមសាលារៀន................................................................ ៤៨
តួលេខទី១៨ ៖ ការទទួលខុសត្រូវចំពោះភារកិច្ចនៃការបំពេញការងាររបស់សាលារៀន .......................... ៥១
តួលេខទី១៩ ៖ ការបោះពុម្ពផ្សាយនូវរបាយការណ៍ស្តីពីការបំពេញការងាររបស់សាលារៀន តាមការយល់ឃើញរបស់ SSCs..........................................................................................................................៥២
តួលេខទី២០៖ ការបោះពុម្ពផ្សាយរបាយការណ៍ស្តីពីការបំពេញការងាររបស់សាលារៀនសម្រាប់សាធារណៈជនទូទៅ តាមការយល់ឃើញរបស់សមាជិកមិនមែន SSC ...............................................................៥២
តួលេខទី២១ ៖ អំពីការបំពេញការងាររបស់សាលារៀន តាមការយល់ឃើញរបស់SSC............................៥៣
តួលេខទី២២ ៖ អំពីការបំពេញការងាររបស់សាលារៀន តាមរយៈការយល់ឃើញរបស់អ្នកមិនមែនSSC..... ៥៤
តួលេខទី២៣ ៖ ការពេញចិត្តចំពោះការបំពេញការងាររបស់សាលារៀន តាមការយល់ឃើញរបស់ SSC..... ៥៤
តួលេខទី២៤៖ ការពេញចិត្តចំពោះការបំពេញការងាររបស់សាលារៀន តាមការយល់ឃើញរបស់សមាជិកសហគមន៍ដែលមិនមែនជាសមាជិកSSC........................................................................ ៥៦

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមនុស្សជាច្រើន ដែលបានចូលរួមចំណែកក្នុងការចងក្រងរបាយការណ៍នេះ។ ជាបឋម យើងសូមថ្លែងអំណរគុណដោយស្មោះ និងយ៉ាងជ្រាលជ្រៅចំពោះអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) ក្នុងការផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបុគ្គលិករបស់ខ្លួនក្នុងការសម្របសម្រួលការងាររៀបចំឯកសារ ព្រមទាំងការផ្តល់ព័ត៌មានត្រឡប់ទៅលើឧបករណ៍សម្រាប់ការស្រាវជ្រាវ និងសេចក្តីព្រាងរបាយការណ៍នីមួយៗ ក៏ដូចជាការបញ្ចប់នូវរបាយការណ៍នេះដែរ។ ទី២ ការសិក្សានេះនឹងមិនអាចបញ្ចប់ទៅបានដោយពេញលេញទេ ប្រសិនបើមិនមានការចូលរួមពីអ្នកប្រមូលទិន្នន័យជាច្រើននាក់ គឺ សុត វិសាល និង ហោ យូហាន មកពីមហាវិទ្យាល័យអប់រំ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជាវង់ សុគារិទ្ធ និងធី សាវិរិន មកពីវិទ្យាស្ថានជាតិអប់រំ ឃុត សុខា និង កៅ សុវណ្ណសុផល មកពីក្រសួងអប់រំ យុវជន និងកីឡា និង ណូ មីស្សី ដែលបានខិតខំប្រឹងប្រែងក្នុងការប្រមូលទិន្នន័យទាំងអស់យ៉ាងលម្អិត និងជាក់លាក់ពីសាលារៀន និងសហគមន៍។

ទី៣ សូមសំដែងរដឹងគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុកចំពោះជំនួយដែលមិនអាចកាត់ថ្លៃបានទាំងអស់របស់ពួកគាត់ដែលធ្វើឲ្យដំណើរការនៃការប្រមូលទិន្នន័យទាំងមូលត្រូវបានធ្វើឡើងដោយរលូន និងប្រកបដោយលទ្ធផលផ្លែផ្កា។ ទី៤ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកក្រុមទីប្រឹក្សាស្រាវជ្រាវទាំងអស់ និងតំណាងមកពីអង្គការ NGO ដែលជាសមាជិករបស់អង្គការ NEP ដែលបានឆ្លៀតឱកាសដ៏មមាញឹករបស់ខ្លួនដើម្បីចូលរួមប្រជុំ ព្រមទាំងផ្តល់យោបល់ និងជាតុចូលប្រកបដោយន័យស្ថាបនាទៅលើឧបករណ៍សម្រាប់ការស្រាវជ្រាវ និងសេចក្តីព្រាងរបាយការណ៍នៃការស្រាវជ្រាវនេះ។ ទី៥ យើងសូមថ្លែងអំណរគុណជាពិសេសចំពោះលោកស្រី Crystal Goodman ចំពោះការផ្តល់យោបល់សម្រាប់ការស្រាវជ្រាវ និងជួយកែសម្រួលរបាយការណ៍នៃការស្រាវជ្រាវនេះ។ ចុងក្រោយ ប៉ុន្តែសំខាន់ជាងគេបំផុតនោះ ក្រុមស្រាវជ្រាវសូមវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដោយស្មោះសរពីសំណាក់សិស្សានុសិស្ស គ្រូបង្រៀន នាយកសាលា សហគមន៍ និងតំណាង NGO ចំពោះពេលវេលា និងការឆ្លើយតបដ៏ស្មោះត្រង់របស់ខ្លួនដែលបានផ្តល់ឲ្យសម្រាប់ការសិក្សាស្រាវជ្រាវនេះ។ បើគ្មានចំឡើយដ៏ស្មោះត្រង់ និងកិច្ចសហការរបស់ពួកគាត់ទេនោះ យើងនឹងពុំមានទិន្នន័យដ៏មានតម្លៃសម្រាប់ការវិភាគនេះទេ។

សមាជិកក្រុម ទីប្រឹក្សាស្រាវជ្រាវ ៖

| | |
|---|---|
| លោក គីម តារា | នាយកប្រចាំប្រទេស អង្គការអប់រំពិភពលោកនៅប្រទេសកម្ពុជា |
| លោក ព្រីង មរកត | អនុប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ក្រសួងអប់រំ យុវជន និងកីឡា |
| លោកបណ្ឌិត រស់ សុវាចា | អតីតមន្ត្រីសម្របសម្រួលការអប់រំសម្រាប់ទាំងអស់គ្នា ការិយាល័យ UNESCO ភ្នំពេញ |
| លោក សៅ វណ្ណា | នាយកប្រតិបត្តិអង្គការសម្ពភាពសម្រាប់បឋមសិក្សានៅកម្ពុជា |
| លោក Jan Noorlander | អ្នកគ្រប់គ្រងកម្មវិធីអប់រំ អង្គការ Care អន្តរជាតិនៅកម្ពុជា |

# អក្សរកាត់

| | |
|---|---|
| CC | ក្រុមប្រឹក្សាឃុំ |
| CwDs | កុមារពិការ |
| D & D | វិមជ្ឈការ និងវិសហមជ្ឈការ |
| DoE | ការិយាល័យអប់រំស្រុក |
| DTMT | ក្រុមការងារបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| NEP | អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| OECD | អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច |
| PB | ថវិកាកម្មវិធី |
| PISA | កម្មវិធីសម្រាប់វាយតម្លៃសិស្សជាលក្ខណៈអន្តរជាតិ |
| PLSS | ប្រព័ន្ធនៃការគាំទ្រការរៀនសូត្ររបស់ឪពុកម្តាយ |
| PO | អង្គការមាតាបិតាសិស្ស (Parental Organization) |
| PoE | មន្ទីរអប់រំខេត្ត |
| PTA | សមាគមមាតាបិតាសិស្ស |
| SSC | គណៈកម្មការទ្រទ្រង់សាលារៀន |
| TIMSS | និន្នាការសម្រាប់ការសិក្សាផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រអន្តរជាតិ |
| TPAP | ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន |

# និយមន័យនៃពាក្យដែលប្រើ

*គណៈកម្មការទ្រទ្រង់សាលារៀន (SSCs)* សំដៅទៅលើសមាជិកគណៈកម្មការទ្រទ្រង់សាលារៀន ដែលត្រូវបានគេជ្រើសរើសឲ្យធ្វើការជាមួយសាលារៀនដើម្បីធានាថា សាលារៀនមានគណនេយ្យភាពលើតួនាទីរបស់ខ្លួនចំពោះសហគមន៍ និងសង្គម។

*សមាជិកមិនមែនគណៈកម្មការទ្រទ្រង់សាលារៀន ឬសមាជិកមិនមែន SSC* សំដៅទៅលើឳពុកម្តាយរបស់កុមារ ដែលកំពុងសិក្សានៅសាលារៀននានាដែលទិន្នន័យសម្រាប់ការសិក្សានេះត្រូវបានគេប្រមូល និងដែលត្រូវបានគេសម្ភាសន៍ជាផ្នែកមួយនៃការសិក្សានេះ។

*ការចូលរួមរបស់សហគមន៍* សំដៅទៅលើកម្រិតនៃការពាក់ព័ន្ធរបស់គណៈកម្មការទ្រទ្រង់សាលារៀននៅ ក្នុងដំណើរប្រតិបត្តិការរបស់សាលារៀនដោយផ្អែកលើសេចក្តីណែនាំរបស់ SSC ដែលបានរៀបចំឡើងនៅក្នុងឆ្នាំ2013 ដែលមានភារៈកិច្ច និងការទទួលខុសត្រូវចំនួន ៨ចំណុច។ ការចូលរួមរបស់ SSC ត្រូវបានគេវាយតម្លៃដោយផ្អែកទៅលើការយល់ឃើញរបស់ SSCs សមាជិកមិនមែន SSCs និងនាយកសាលា។

*ការបំពេញការងាររបស់សាលារៀន* សំដៅទៅលើសកម្មភាពនានានៅក្នុងសាលារៀនដែលតាមរយៈសកម្មភាពទាំងនោះសាលារៀនត្រូវមានគណនេយ្យភាពចំពោះសហគមន៍ ដែលផ្ទុយទៅនឹងលទ្ធផលនៃការសិក្សារបស់សិស្សដែលគេបានវាស់វែង។

*គណនេយ្យភាពរបស់សាលារៀន* ត្រូវបានគេវាស់ដោយផ្អែកលើមូលដ្ឋាននៃកម្រិតនៃការចូលរួមរបស់សហគមន៍ និងការបំពេញការងាររបស់សាលារៀន។ ការវាស់វែងទាំង២នេះគឺជាធាតុចូលដែលគេដាក់បញ្ចូលគ្នាដើម្បីឆ្លុះបញ្ចាំងពីវិសាលភាពដែលសាលារៀនមានគណនេយ្យភាពចំពោះដំណើរការផ្ទាល់របស់ខ្លួន ចំពោះការរៀនសូត្ររបស់សិស្ស និងចំពោះសហគមន៍ជាទូទៅ។

# សេចក្តីសង្ខេប

បច្ចុប្បន្ននេះការអប់រំគឺជាចំណុចសំខាន់ជាងគេបំផុតចំពោះរបៀបវារៈនៃការអភិវឌ្ឍ និងនយោបាយរបស់ប្រទេសភាគច្រើននៅលើសកលលោក។ ប្រទេសនីមួយៗកំពុងតែធ្វើការដើម្បីនាំមកនូវការអប់រំដែលមានសមធម៌ និងបានចូលរៀនប្រកបដោយគុណភាពខ្ពស់សម្រាប់ប្រជាជនរបស់ខ្លួន។ បើគិតពីគុណភាពអប់រំ គំរូនៃការកំណត់គុណភាពអប់រំដែលអាចធ្វើទៅបានគឺគំរូនៃដំណើរការនៃការផលិត (production-function model) ទោះបីជាគំរូនេះហួសសម័យទៅហើយក៏ដោយ។ រហូតមកដល់ពេលថ្មីៗនេះ ដំណើរការដែលពាក់ព័ន្ធនឹងអ្វីដែលកំពុងកើតឡើងនៅតាមសាលារៀន និងជាមួយគ្រូបង្រៀន បានក្លាយទៅជាកត្តាដ៏ចំបងបំផុតក្នុងការផលិតនូវសិស្សដែលទទួលបានលទ្ធផលនៃការសិក្សាខ្ពស់ជាមួយនឹងចំនួនថវិកាដែលមានដូចគ្នា។ ស្របជាមួយនឹងចំណុចនេះក្នុងរយៈកាលពីរបីទសវត្សរ៍កន្លងមកនេះ ពាក្យ*គណនេយ្យភាព* បានលេចឡើងជាញឹកញាប់នៅក្នុងសេចក្តីថ្លែងការនយោបាយ និងការស្រាវជ្រាវស្តីពីគុណភាពអប់រំ។

នៅក្នុងប្រទេសកម្ពុជា គោលគំនិតស្តីពីវិមជ្ឈការ និងគណនេយ្យភាពទើបតែកើតមានឡើងក្នុងរយៈពេលថ្មីៗនេះប៉ុណ្ណោះ។ វាមិនមែនរហូតទាល់តែដល់ទសវត្សឆ្នាំ១៩៩០ទេ ដែលវិមជ្ឈការត្រូវបានគេណែនាំនៅក្នុង ប្រទេសកម្ពុជាក្រោមការជំរុញដ៏ខ្លាំងក្លាមួយពីទីភ្នាក់ងារផ្តល់ជំនួយ។ ចលនានេះត្រូវបានគេពង្រឹងឡើងវិញក្រោយមកទៀតនៅឆ្នាំ២០០២។ ការធ្វើប្រតិភូកម្មអំណាចផ្នែករដ្ឋបាលក៏មានឥទ្ធិពលច្រើនផងដែរទៅលើផ្នែកអប់រំ។ ការចូលរួមរបស់ភាគីដែលពាក់ព័ន្ធខុសៗគ្នា នៅក្នុងដំណើរការសាលារៀនបានចាប់ផ្តើមជាមួយនឹងកម្មវិធីសាលាកម្រងដែលត្រូវបានគេណែនាំនៅក្នុងឆ្នាំ១៩៩២ ចំណែកឯការកិច្ចនៃការចូលរួមរបស់សហគមន៍នៅក្នុងការគ្រប់គ្រង និងដំណើរការសាលារៀន គឺទើបតែចាប់ផ្តើមនៅក្នុងរយៈពេលដូចគ្នានៃការបង្កើតគណៈកម្មការទ្រទ្រង់សាលារៀន (SSCs) នៅក្នុងឆ្នាំ២០០២ប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃជាទ្រង់ទ្រាយធំទៅលើដំណើរការរបស់ SSCs ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ បានបង្ហាញឲ្យឃើញនូវការព្រួយបារម្ភស្រដៀងៗគ្នា។ តួនាទីដែលគេរំពឹងទុករបស់ SSCs គឺមានចំនួនច្រើនណាស់ ទោះជាយ៉ាងនេះក្តី នៅក្នុងការអនុវត្តជាក់ស្តែង សកម្មភាពរបស់ពួកគាត់ត្រូវបានគេរកឃើញថា ភាគច្រើនវិលជុំវិញតែការរៃអង្គាសមូលនិធិ និងការរួមចំណែកដល់សាលារៀនតែប៉ុណ្ណោះ ចំណែកឯការទទួលខុសត្រូវរបស់ពួកគាត់ដែលនៅសល់ជាច្រើនទៀតមិនទាន់បានអនុវត្តទេ។ ដោយយល់ឃើញនូវការប្រឈមមុខនានានៃការចូលរួមតិចតួចរបស់សហគមន៍ចំពោះគណនេយ្យភាពរបស់សាលារៀននៅថ្នាក់មូលដ្ឋាន MoEYS បានដាក់ចេញនូវសកម្មភាពជាអទិភាពមួយចំនួននៅក្នុងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (TPAP) ដែលទើបតែបង្កើតឡើងក្នុងពេលថ្មីៗនេះ ដើម្បីស្វែងរកការកែលម្អរសមត្ថភាពថ្នាក់មូលដ្ឋាន ក្នុងការចូលរួមការគ្រប់គ្រងសាលារៀន។

ការសិក្សាស្រាវជ្រាវស្តីពីការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការសាលារៀនបឋមសិក្សា និងមធ្យម សិក្សាបឋមភូមិនេះ ត្រូវបានធ្វើឡើងនៅក្នុងខេត្តចំនួន៥ និងរាជធានីភ្នំពេញដោយមានការពាក់ព័ន្ធនឹងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗដូចជា នាយកសាលាចំនួន១០៨នាក់ សមាជិក SSCs ចំនួន៣៦៦នាក់ មាតាបិតាសិស្សចំនួន២៦៥នាក់ និងសមាជិកបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលចំនួន១៥នាក់ ហើយមានការពិភាក្សាជាក្រុម ចំនួន១២ក្រុម ជាមួយនឹងសិស្សានុសិស្សចំនួន៧២នាក់ នៅក្នុងសាលាបឋមសិក្សាចំនួន៩០សាលា និងសាលាមធ្យមសិក្សាបឋមភូមិចំនួន១៨សាលា។ ការសិក្សានេះមានបំណងពិនិត្យមើលពីកម្រិតនៃដំណើរការរបស់ SSCs ដើម្បីកំណត់ពីការប្រតិបត្តិល្អ និងការប្រឈមនានាសម្រាប់ការចូលរួមរបស់ SSCs នៅ

ក្នុងការលើកកម្ពស់គុណភាពនៃការអប់រំសាលារៀន។ ហេតុដូច្នេះហើយ យើងសង្ឃឹមថា លទ្ធផលនានាដែលបានមកពីការសិក្សានេះនឹងក្លាយជាជំនួយដល់ MoEYS ក្នុងការបង្កើតគោលនយោបាយដ៏រឹងមាំនានាសម្រាប់ការអនុវត្ត។

ការវិភាគទៅលើទិន្នន័យដែលបានទទួលពីនាយកសាលា សិស្សានុសិស្ស SSCs សមាជិកមិនមែនគណៈកម្មការទ្រទ្រង់សាលារៀន (Non-SSCs គឺឪពុកម្តាយរបស់កុមារនៅតាមសាលារៀននានា ដែលគេបានសិក្សា) និងបុគ្គលិក NGO បានបង្ហាញនូវការរកឃើញសំខាន់ៗមួយចំនួន។ **ទី១ ទោះបីជាការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការរបស់សាលារៀនត្រូវបានគេរកឃើញថា មានកម្រិតទាបក៏ដោយ ក៏មានការរីកចំរើនមួយចំនួនដែរចំពោះលក្ខណៈនៃការចូលរួមរបស់គាត់** នៅពេលដែលគេប្រៀបធៀបជាមួយនឹងការសិក្សានានាកន្លងមក។ លទ្ធផលនានាបង្ហាញថា សមាជិក SSCs មានការយល់ដឹងកាន់តែច្រើនឡើងពីតួនាទីនៃការទទួលខុសត្រូវរបស់ខ្លួន បើទោះបីជាការយល់ដឹងនេះនៅមិនទាន់ដល់កម្រិតមួយដែលគេចង់បាននៅឡើយ ហើយមានការចូលរួមនៅក្នុងសកម្មភាពផ្សេងៗគ្នារបស់សាលារៀនច្រើនជាងអ្វីដែលគេរាយការណ៍កាលពីទសវត្សមុន។ មានការចូលរួមកាន់តែច្រើនឡើងមួយពីសំណាក់សហគមន៍នៅក្នុងការត្រួតពិនិត្យមើលដំណើរការនៃការសាងសង់សាលារៀន និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់។ SSCs ក៏បានផ្តល់នូវជំនួយកាន់តែច្រើនឡើងដល់សាលារៀនដើម្បីធានាបាននូវបរិយាកាសដែលមានសុវត្ថិភាព និងងាយស្រួលសម្រាប់អ្នកសិក្សារៀនសូត្រ។

វិសាលភាពនៃការចូលរួមរបស់សហគមន៍ត្រូវបានគេរកឃើញថា មានភាពខុសប្លែកគ្នាទៅតាមតំបន់ (ខេត្ត/ រាជធានី) ប៉ុន្តែមិនមានភាពខុសគ្នានៅកម្រិតសាលារៀនទេ (សាលារៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ)។ ទិន្នន័យរបស់នាយកសាលា និង SSCs បច្ចុប្បន្ននេះគាំទ្រភស្តុតាងដែលថា សមាជិក SSCs នៅតាមសាលារៀននៅក្រៅរាជធានីភ្នំពេញមានកម្រិតនៃការចូលរួមកាន់តែខ្ពស់នៅក្នុង "ការប្រមូល និងការគ្រប់គ្រងមូលនិធិ" និង "ការកសាងសមត្ថភាព"។ ទិន្នន័យក៏បានបង្ហាញបន្ថែមទៀតថា SSCs នៅតាមសាលារៀននៅក្រៅរាជធានីភ្នំពេញទំនងជាមានកម្រិតនៃការចូលរួមកាន់តែខ្ពស់នៅក្នុង "ការតាមដានការសិក្សារៀនសូត្ររបស់សិស្សានុសិស្ស" "ការកសាង និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន" និង "ការចែករំលែកបទពិសោធន៍ និងបំណិនជីវិត" បើប្រៀបធៀបជាមួយនឹងសមភាគីរបស់គាត់នៅក្នុងទីក្រុង។ ការវិភាគបន្តទៀតបានបង្ហាញថា ការចូលរួមរបស់ SSCs នៅក្នុងសកម្មភាពរបស់សាលារៀនមានភាពខុសគ្នាជាដុំកំភួននៅតាមខេត្ត ($p < .05$)។ ភស្តុតាងបង្ហាញថាខេត្ត រតនៈគីរី សៀមរាប និងរាជធានីភ្នំពេញ មានការចូលរួមតិចបំផុតដែលគេបានមើលឃើញពីសំណាក់សមាជិក SSC នៅក្នុងសកម្មភាពរបស់សាលារៀន។ មានការមើលឃើញមួយពីការចូលរួមដ៏តិចតួចរបស់ SSCs នៅតាមសាលារៀននៅក្នុងខេត្តកំពត និងព្រៃវែង។ ខេត្តកំពង់ចាមមានការចូលរួមរបស់ SSC ខ្ពស់ជាងគេបំផុតដែលគេមើលឃើញនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់សាលារៀន។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលនានាដែលបានមកពីការប្រើប្រាស់ទិន្នន័យរបស់នាយកសាលា និង SSCs បានបញ្ជាក់ថា នៅក្នុងករណីភាគច្រើនគេពុំមើលឃើញមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ទេ ចំពោះកម្រិតនៃការចូលរួមរបស់សហគមន៍នៅក្នុងសកម្មភាពរបស់សាលារៀនរវាងសាលារៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ($p > 0.05$)។ ភាពខុសគ្នាដែលគេកត់សំគាល់គឺមានតែការចងក្រងឯកសារស្តីពី "ការពង្រឹងការចុះឈ្មោះចូលរៀននៅតាមសាលារៀន" និង "ការទប់ស្កាត់ភាពមិនប្រក្រតី" ប៉ុណ្ណោះ ទោះជាយ៉ាងនេះក្តី ភស្តុតាងនៃភាពផ្ទុយគ្នានេះត្រូវបានគេប្រមូលតែពីនាយកសាលា និងសមាជិក SSCs ទេ។ ទិន្នន័យបង្ហាញថា សាលារៀនបឋមសិក្សាជារួមត្រូវបានបង្ហាញភស្តុតាងថា កម្រិតនៃការចូលរួមរបស់សហគមន៍កាន់តែខ្ពស់នៅក្នុងសកម្មភាព

នានាដែលលើកកម្ពស់ការចុះឈ្មោះចូលរៀននៅសាលារៀន ចំណែកឯការចូលរួមសកម្មភាពនៅតាមសាលារៀនមធ្យមសិក្សាបឋមភូមិវិញ គឺមានកម្រិតកាន់តែខ្ពស់ឡើងដែលទាក់ទងនឹងការទប់ស្កាត់ភាពមិនប្រក្រតី។

ការអប់រំរបស់នាយកសាលាអាចដើរតួនាទីមួយ នៅក្នុងការកំណត់ពីកម្រិតនៃការចូលរួមរបស់ SSCs នៅក្នុងសកម្មភាពសាលារៀនរបស់ខ្លួន។ នៅតាមបណ្តាខេត្តនានា ដែលនាយកសាលាកាន់តែច្រើននៅតាមសាលារៀនដែលយើងបានសិក្សាមានកម្រិតសញ្ញាប័ត្របរិញ្ញាប័ត្រ ការយល់ឃើញគឺកាន់តែមានភាពប្រសើរឡើង ចំពោះការចូលរួមរបស់ SSCs នៅក្នុងការគ្រប់គ្រងសាលារៀន។

**ទី២ ការសិក្សានេះបង្ហាញឲ្យឃើញនូវសេចក្តីសន្និដ្ឋានមួយដែលថា មានគម្លាតជាដុំកំភួនមួយរវាង SSCs និងឪពុកម្តាយ ដែលមិនមែនជាផ្នែកមួយរបស់ SSC ចំពោះការយល់ដឹងពីរបៀបដែលសាលារៀនកំពុងដំណើរការ** ជាពិសេសទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវរបស់ SSCs ដែលគេមានបំណងតភ្ជាប់នូវគម្លាតនេះ។ ឪពុកម្តាយដែលមិនពាក់ព័ន្ធជាមួយ SSCs ទំនងជាមានអារម្មណ៍ថានៅដាច់កាន់តែឆ្ងាយពីសាលារៀនដែលធ្វើឲ្យការយល់ដឹងរបស់ពួកគាត់ទៅលើអ្វីដែលSSCsកំពុងអនុវត្តកាន់តែមានកម្រិតថែមទៀត បើប្រៀបធៀបជាមួយនឹងសមភាគីដែលជាសមាជិក SSCs របស់ខ្លួន។ នៅក្នុងការសម្ភាសន៍ក្រុមនីមួយៗ បានចែករំលែកនូវបញ្ហាប្រឈមស្រដៀងៗគ្នាទាក់ទងនឹងការចូលរួមរបស់សហគមន៍ក្នុងការបំពេញការងាររបស់សាលារៀន។ ចំណុចទាំងនេះរាប់បញ្ចូលទាំង៖ ការខ្វះខាតការយល់ដឹងរបស់នាយកសាលាពីតួនាទី និងការទទួលខុសត្រូវរបស់ SSCs ហើយក្នុងកាលៈទេសៈខ្លះគឺខ្វះការប្តេជ្ញាចិត្តទៅលើគណនេយ្យភាពចំពោះសហគមន៍ ការខ្វះការយល់ដឹងរបស់ SSCs ទៅលើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ការមានទឹកចិត្ត ឬការជឿជាក់តិចតួចពីសំណាក់សហគមន៍/អាជ្ញាធរដែនដី បញ្ហានៃការប្រាស្រ័យទាក់ទង និងកិច្ចសហប្រតិបត្តិការ ក្នុងចំណោមនាយកសាលា SSCs និងសហគមន៍ ព្រមទាំងការខ្វះខាតនូវការផ្តល់មូលនិធិដើម្បីធ្វើឲ្យការងាររបស់ SSCs មាននិរន្តរភាព។ ការវិភាគនេះក៏បានលើកឡើងដែរថា មានការប្រតិបត្តិល្អមួយចំនួនក្នុងការធានា និងលើកកម្ពស់ការងាររបស់ SSCs និងការចូលរួមរបស់សហគមន៍។ ការសិក្សានេះសន្និដ្ឋានថា SSCs ប្រហែលជាមិនអាចដំណើរការបានល្អទេ ប្រសិនបើចំណុចនានាដូចខាងក្រោមនេះ ពុំបានកើតមាន៖ តួនាទី និងការទទួលខុសត្រូវរបស់ SSCs ត្រូវបានគេផ្សព្វផ្សាយឲ្យបានច្បាស់លាស់ដល់នាយកសាលា និងសមាជិក SSCs ខ្លួនឯង សមាជិក SSC ត្រូវបានគេជ្រើសរើសពីចំណោមក្រុមនានាដែលមានចំណេះដឹង មានឥទ្ធិពល មានការប្តេជ្ញាចិត្ត ការប្រាស្រ័យទាក់ទងរវាងនាយកសាលា និង SSCs ត្រូវបានគេតភ្ជាប់ឲ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត ហើយចំណុចបញ្ហានានានៅក្នុងការផ្តល់ហិរញ្ញវត្ថុ និងធនធានផ្សេងៗសម្រាប់សកម្មភាពរបស់ SSCs ត្រូវបានគេដោះស្រាយ។

ដើម្បីដោះស្រាយនូវចំណុចបញ្ហាមួយចំនួនដែលគេបានរកឃើញនៅក្នុងការសិក្សានេះ និងដើម្បីលើកកម្ពស់គណនេយ្យភាពរបស់សាលារៀន ការសិក្សានេះបានលើកឡើងនូវអនុសាសន៍ចំនួន៥ ដោយរាប់បញ្ចូលទាំងការពង្រឹងនូវការអនុវត្តន៍សេចក្តីណែនាំរបស់ SSCs ដែលមានស្រាប់ឡើងវិញ ពង្រឹងសមត្ថភាពរបស់នាយកសាលា និង SSCs កែលម្អការសម្របសម្រួលក្នុងចំណោមអ្នកអនុវត្តសំខាន់ៗ លើកកម្ពស់គណនេយ្យភាពផ្នែកហិរញ្ញវត្ថុ និងចុងក្រោយតែមិនមែនអស់នោះទេគឺការផ្តល់អំណាចទៅលើតួនាទីរបស់ក្រុមប្រឹក្សាឃុំ / សង្កាត់។

# ១. សេចក្តីផ្តើម និងបរិបទ

ការអប់រំគឺជាចំណុចសំខាន់បំផុតនៃរបៀបវារៈនៃការអភិវឌ្ឍ និងនយោបាយរបស់ប្រទេសជាច្រើននៅជុំវិញពិភពលោក។ ប្រទេសនីមួយៗកំពុងធ្វើការយ៉ាងផ្ចិតផ្ចង់ដើម្បីនាំមកនូវការអប់រំប្រកបដោយសមធម៌ និងមានលទ្ធភាពទទួលយកបានដែលមានគុណភាពខ្ពស់សម្រាប់ប្រជាជនរបស់ខ្លួន។ ដោយសារប្រទេសកំពុងអភិវឌ្ឍមានការរីកចំរើនជាពិសេសទៅលើគោលដៅនៃ*សិទ្ធិទទួលបាន*ការអប់រំ យើងអាចមើលឃើញនូវការផ្លាស់ប្តូរការយកចិត្តទុកដាក់ទៅលើចំណុចបញ្ហាផ្នែក*គុណភាព*នៃការអប់រំនោះ ដោយទទួលស្គាល់ថា វត្តមានរបស់សាលារៀនខ្លួនឯងមិនទាន់គ្រប់គ្រាន់នៅឡើយទេក្នុងការធានាបាននូវលទ្ធផលល្អនៃការសិក្សារៀនសូត្រ។ ទោះជាយ៉ាងណាក៏ដោយ ពាក្យ *គុណភាព* ត្រូវបានគេកំណត់និយមន័យខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ ដែលធ្វើឲ្យមានការលំបាកក្នុងការកំណត់និយមន័យតែមួយ។ គោលដៅរួមដែលប្រទេសនីមួយៗមានដូចគ្នាគឺការសម្រេចបានរបស់សិស្សក្នុងការឆ្លើយតបទៅនឹងលទ្ធផលនៃការសិក្សារៀនសូត្រជាក់លាក់ បន្ទាប់ពីការរៀនសូត្រនៅសាលារៀនសម្រាប់ចំនួនឆ្នាំជាក់លាក់។ តាមធម្មតា លទ្ធផលនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈលទ្ធផលរបស់សិស្សទៅលើការធ្វើតេស្តតាមស្តង់ដារជាតិ ឬអន្តរជាតិ ដូចជា PISA ឬ TIMSS និងកម្រិតនៃការទទួលបានការងារធ្វើរបស់សិស្សរបស់ខ្លួនបន្ទាប់ពីបញ្ចប់ការសិក្សា។

ទាក់ទងនឹងគុណភាព ទោះបីជាវាហួសសម័យបន្តិចទៅហើយក៏ដោយ ក៏គំរូដែលអាចដំណើរការបានចំពោះការកំណត់និយមន័យគុណភាពនៃការអប់រំ គឺជាគំរូនៃដំណើរការនៃការផលិត (production-function model)។ ទ្រឹស្តីនេះពិនិត្យមើលគុណភាពអប់រំដែលទាក់ទងនឹងធាតុចូល និងដំណើរការ។ របាយការណ៍លំអិតរបស់ Coleman et al. (១៩៦៦) បានរកឃើញថាធាតុចូលរបស់សាលារៀនមានឥទ្ធិពល (ផលជះ) យ៉ាងខ្លាំងទៅលើការសិក្សារៀនសូត្ររបស់សិស្ស។ ការរកឃើញនេះបានអំពាវនាវឲ្យមានការវិនិយោគថែមទៀតទៅលើធាតុចូលពីសំណាក់រដ្ឋាភិបាលនីមួយៗនៅជុំវិញពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាច្រើនថែមទៀតក្នុងពេលថ្មីៗនេះពីសំណាក់បញ្ញវន្តជាច្រើននាក់ផ្សេងទៀត (ឧទាហរណ៍ Huneshek, ២០១០) លើកឡើងថា ដំណើរការនៃការបង្រៀន និងការរៀននៅតាមគ្រឹះស្ថានអប់រំនានា ជារឿយៗត្រូវបានគេបានគេសំដៅថាជា "ប្រអប់ខ្មៅ" ដែលគេដាក់នៅចន្លោះកណ្តាលរវាងធាតុចូល និងលទ្ធផល ដើរតួនាទីចំបងមួយនៅក្នុងការលើកកម្ពស់គុណភាពនៃការសិក្សារៀនសូត្ររបស់សិស្ស។ ដំណើរការទាំងនេះរាប់បញ្ចូលទាំងដំណើរការទាំងឡាយណាដែលផ្តល់នូវគណនេយ្យភាពរបស់គ្រូបង្រៀន និងសាលារៀនចំពោះការបំពេញភារកិច្ចរបស់ខ្លួនដើម្បីធានាថា សិស្សបានរៀននូវអ្វីដែលគេរំពឹងទុកថាពួកគេនឹងរៀន។ ដោយសារចំណុចនេះ ពាក្យ *គណនេយ្យ-ភាព* បានក្លាយទៅជាទិដ្ឋភាពនៃវិធីសាស្ត្រនានា ដែលគេពិភាក្សាគ្នាជាញឹកញាប់ចំពោះការធានាបាននូវគុណភាពអប់រំក្នុងរយៈពេលពីរបីទសវត្សចុងក្រោយនេះ។

ទោះបីជានៅមានការពិភាក្សាដេញដោលច្រើនទៅលើការគាំទ្រ និងការប្រឆាំងចំពោះវាក៏ដោយ ក៏គោលគំនិតនៃគណនេយ្យភាពរបស់សាលារៀន បានចាប់ផ្តើមជាលើកដំបូងទៅក្នុងការសិក្សាស្រាវជ្រាវពីការអប់រំ និងការពិភាក្សាដេញដោលពីគោលនយោបាយទំនងជាកើតមានឡើងនៅក្នុងទសវត្សឆ្នាំ១៩៦០ (Beneniste, ១៩៨៥)។ ចាប់តាំងពីពេលនោះមក អន្តរាគមន៍នានាដែលមានគោលបំណងលើកកម្ពស់គណនេយ្យភាពរបស់សាលារៀនបានក្លាយទៅជាផ្នែកមួយនៃការឆ្លើយតបផ្នែកគោលនយោបាយ ដើម្បីនាំមកនូវគុណភាពរបស់សាលារៀន និងពេលខ្លះឆ្លើយតបទៅនឹងតម្រូវការជាសាធារណៈសម្រាប់សេវាកម្មអប់រំដែល

មានកែលម្អនៅក្នុងមធ្យោបាយមួយដែលកាន់តែមានប្រសិទ្ធិភាពតម្លៃ (Figlio & Page, ២០០៣)។ អន្តរាគមន៍ទាំងនេះត្រូវបានគាំទ្រដោយឈរលើភស្តុតាងដែលរាប់បញ្ចូលទាំងការសិក្សាមួយរបស់ OECD ដែលបានធ្វើឡើងនៅក្នុងឆ្នាំ២០១១ ដែលបានពិនិត្យមើលទៅលើទំនាក់ទំនងនានារវាងលទ្ធផលនៃការសិក្សារៀនសូត្រមុខវិជ្ជាគណិតវិទ្យា អំណាន និងវិទ្យាសាស្ត្រ និងការវាស់វែងទៅលើគណនេយ្យភាពរបស់សាលារៀន។ ការសិក្សានោះបានរកឃើញថា ប្រទេសជាច្រើនដែលសាលារៀនមានគណនេយ្យភាពចំពោះលទ្ធផលរបស់ខ្លួនតាមរយៈការផ្សព្វផ្សាយនូវប័ណ្ណ ស្តីពីការប្រតិបត្តិរបស់សាលារៀនជាសាធារណៈគឺមានលទ្ធភាពច្រើនជាងក្នុងការលៃបំរុងធនធានរបស់ខ្លួនសម្រាប់លើកកម្ពស់អត្រាលទ្ធផលនៃការសិក្សារបស់សិស្សកាន់តែមានប្រសិទ្ធិភាពផ្ទុយទៅវិញនៅក្នុងប្រទេសនានា ដែលពុំមានការរៀបចំនូវគណនេយ្យភាពរបៀបនេះ សិស្សហាក់ដូចជាទទួលបានលទ្ធផលសិក្សាខ្សោយជាង (OECD, ២០១១)។ ឧទាហរណ៍នៅក្នុងប្រទេសជប៉ុន កូរ៉េ ញ៉ូវហ្សីលែន និងហុងកុងដែលបានផ្តល់នូវគណនេយ្យភាព និងស្វ័យភាពយ៉ាង ច្រើនដល់សាលារៀនរបស់ខ្លួនក្នុងការកំណត់ការអនុវត្តកម្មវិធីសិក្សា និងការវាយតម្លៃសមិទ្ធផលនៃការសិក្សារបស់សិស្សមានកម្រិតខ្ពស់មែនទែនទៅលើការធ្វើតេស្ត PISA។

ក្រៅពីលើកកម្ពស់នូវគុណភាពនៃការរៀនសូត្ររបស់សិស្សដែលជាគោលដៅចុងក្រោយ ការស្រាវជ្រាវបានលើកឡើងថា គណនេយ្យភាពរបស់សាលារៀនកាន់តែប្រសើរឡើងក៏មានលទ្ធភាពទាក់ទាញបេក្ខជនដែលមានសមត្ថភាពមកធ្វើជាគ្រូបង្រៀនដែរនៅកន្លែងដែលគេអាចធ្វើឲ្យសាលារៀន និងគ្រូបង្រៀនកាន់តែមានស្វ័យភាពថែមទៀតនៅថ្នាក់មូលដ្ឋាន (Figlio & Page, ២០០៣)។ គេក៏បានបង្ហាញឲ្យឃើញនូវការជួយកសាងនូវទំនុកចិត្តរបស់សហគមន៍មូលដ្ឋាន ដើម្បីឲ្យសហគមន៍ទាំងនោះមានឆន្ទៈក្នុងការផ្តល់មូលនិធិកាន់តែច្រើន និងចូលរួមចំណែកកាន់តែប្រសើរឡើងដល់សាលារៀន។ គណនេយ្យភាពកាន់តែប្រសើរអាចផ្តល់នូវការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវរួមគ្នាកាន់តែខ្លាំងរបស់គ្រូបង្រៀន សិស្សានុសិស្ស និងសហគមន៍ ចំពោះភារកិច្ចនៃការកែលម្អការបំពេញការងាររបស់សាលារៀន។

ការពិភាក្សាដេញដោលមិនត្រូវបានគេធ្វើឡើងតែចំពោះការគាំទ្រ និងការប្រឆាំងនឹងគណនេយ្យភាពទេ តែថែមទាំងទៅលើរបៀបដែលពាក្យនេះត្រូវបានគេកំណត់និយមន័យទៀតផង។ ទោះបីពាក្យគណនេយ្យ-ភាព ជាពាក្យមួយដែលមានលក្ខណៈស្មុគស្មាញដូចដែលបានបញ្ជាក់ពីខាងលើក៏ដោយ ក៏ឥឡូវនេះពាក្យនេះមានលក្ខណៈទូទៅទៅហើយនៅក្នុងឯកសាររដ្ឋបាលសាធារណៈ។ យើងកម្រឃើញពាក្យនេះណាស់នៅក្នុងរយៈពេលពីរបីទសវត្សកន្លងមកនេះ (Dubnick ១៩៩៨, pp. ៦៩–៧០) ប៉ុន្តែបច្ចុប្បន្ន ពាក្យនេះលេចឡើងនៅគ្រប់ទីកន្លែងនៅក្នុងការប្រតិបត្តិ"គ្រប់លក្ខណៈទាំងអស់នៃការវិភាគ និងវោហារសាស្ត្រ ព្រមទាំងជាបន្ទុកខ្លាំងរបស់រដ្ឋាភិបាលប្រជាធិបតេយ្យ" (Mulgan, ២០០០)។ ជាប្រពៃណី អត្ថន័យត្រូវបានគេកំណត់ចំពោះដំណើរការដែលគេហៅថា "ទទួលខុសត្រូវ" ចំពោះអាជ្ញាធរមួយចំនួនសម្រាប់សកម្មភាពនានារបស់អ្នកណាម្នាក់ (Jones ១៩៩២, p. ៧៣)។ និយមន័យនេះគឺស្រដៀងគ្នាទៅនឹងនិយមន័យដែល Stecher និង Kirby បានកំណត់ដែរ (២០០៤, p. ២២) ដែលសំដៅពាក្យនេះទៅលើ "ការអនុវត្តនូវការប្រកាន់យកប្រព័ន្ធអប់រំដែលទទួលខុសត្រូវចំពោះគុណភាពនៃផលិតផលរបស់ខ្លួន ពោលគឺចំណេះដឹង ជំនាញ និងឥរិយាបទរបស់សិស្សានុសិស្ស"។ ទោះជាយ៉ាងណាក៏ដោយ គោលគំនិតរបស់គណនេយ្យភាពបានបាត់បង់នូវអត្ថន័យត្រង់ដើមរបស់វាមួយចំនួន ហើយមានតម្រូវការសម្រាប់ការបកស្រាយជាប្រចាំ និងការចាត់ប្រភេទដែលកាន់តែស្មុគស្មាញឡើង (Day និង Klein ១៩៨៧; Sinclair ១៩៩៥)។

គោលបំណង ឬគោលដៅរបស់កម្មវិធីគណនេយ្យភាពបានផ្លាស់ប្តូរក្នុងរយៈពេលកន្លងមកពីប្រព័ន្ធ *ប្រសិទ្ធិផល* ទៅរក*គុណភាព* នៃការអប់រំទៅរក*ផលិតភាព* របស់អង្គការ និងទៅរក*ភាពនៃការឆ្លើយតប*ពីខាងក្រៅចំពោះអទិភាពជាសាធារណៈ ឬតម្រូវការផ្នែកទីផ្សារ (Burke, ២០០៥)។ មិនជាបញ្ហាអ្វីទេថា តើគោលបំណងរបស់ពាក្យនេះផ្លាស់ប្តូរកម្រិតណានោះ Burke (២០០៥) ដែលបានឯកភាពទៅលើគំរូនៃគណនេយ្យភាពរបស់សាលារៀនរបស់ Mayston និង Jesson (១៩៨៨) បានបន្តលើកទឡ្ហីករថា គណនេយ្យភាពរបស់សាលារៀនគឺការអនុញ្ញាតឲ្យភាគីដែលពាក់ព័ន្ធនានាដឹងឲ្យបានច្បាស់លាស់ថា តើសាលារៀនបានអនុវត្តនូវសកម្មភាពមួយចំនួនដូចតទៅនេះដែរឬទេ ៖ (១) បានប្រើប្រាស់នូវអំណាចរបស់ខ្លួនបានសមស្រប (២) កំពុងតែធ្វើការដើម្បីសម្រេចបានបេសកកម្ម ឬអទិភាពរបស់ខ្លួន (៣) រាយការណ៍ពីការអនុវត្តរបស់ខ្លួនដល់សាធារណៈជនទូទៅ (៤) បានប្រើប្រាស់ធនធាននានាដែលមានប្រកបដោយប្រសិទ្ធិផល និងប្រសិទ្ធិភាពដើម្បីទទួលបាននូវឥទ្ធិពល (ផលជះ) (៥) ផលិតនូវផលិតផល និងសេវាកម្មផ្សេងៗដែលមានគុណភាពអាចទទួលយកបាន ព្រមទាំង (៦) បម្រើតម្រូវការសាធារណៈ។ ក្នុងករណីដូចនេះ ប្រព័ន្ធគណនេយ្យភាពបន្ទាប់មកបានក្លាយជាប្រព័ន្ធដែលមានអំណាចយ៉ាងខ្លាំងសម្រាប់ការផ្តល់រង្វាន់ និងការដាក់ទណ្ឌកម្មសាលារៀនតាមរយៈការបង្កើនការផ្តល់មូលនិធិដល់សាលារៀនដែលបំពេញការងារបានល្អ និងការដាក់ទណ្ឌកម្មដល់សាលារៀនដែលបំពេញការងារមិនបានល្អ (Figlio & Page, ២០០៣)។ ហេតុដូច្នេះហើយ គណនេយ្យភាពធ្វើឲ្យសាលារៀនមានលទ្ធភាពក្នុងការផ្តល់ការអប់រំដែលមានគុណភាពខ្ពស់កាត់បន្ថយនូវការអនុវត្តដែលទំនងជាបង្កឲ្យមានការឈឺចាប់ ឬខ្វះសមធម៌ ព្រមទាំងមានមធ្យោបាយនានាដើម្បីកំណត់ និងកែតម្រូវបញ្ហាដែលអាចកើតមាន (Darling-Hammond & Snyder, ២០១៥)។

### *គណនេយ្យភាពរបស់សាលារៀននៅកម្ពុជា*

ការពិនិត្យមើលគោលនយោបាយ និងឯកសារស្រាវជ្រាវរបស់រាជរដ្ឋាភិបាល និងទីភ្នាក់ងារអន្តរជាតិនានា បង្ហាញឲ្យឃើញនូវការកើនឡើងនូវការតស៊ូមតិឲ្យមានការចូលរួមរបស់សហគមន៍នៅក្នុងការអប់រំ។ ការតស៊ូមតិនេះមួយផ្នែកគឺផ្អែកលើតម្រូវការមួយក្នុងការបែងចែកការទទួលខុសត្រូវលើការផ្តល់ធនធានសម្រាប់ប្រព័ន្ធអប់រំ ប៉ុន្តែក៏មានគោលបំណងក្នុងការបង្កើននូវទំហំ ការជាប់ទាក់ទង និងឥទ្ធិពល (ផលជះ) របស់សាលារៀនផងដែរ។ ក្របខ័ណ្ឌគោលនយោបាយជាច្រើនដែលនៅជុំវិញចលនាទាំងនេះជាប់ទាក់ទងគ្នាជាមួយនឹងការផ្លាស់ប្តូរនានាឆ្ពោះទៅរកការធ្វើវិមជ្ឈការការទទួលខុសត្រូវចំពោះការអប់រំ (Bray, ២០០៣)។ ចំពោះចំណុចនេះ ការអប់រំសម្រាប់មនុស្សជំនាន់ថ្មីត្រូវបានគេជឿជាក់ថា ជាការទទួលខុសត្រូវរបស់មនុស្សគ្រប់គ្នាដើម្បីឲ្យគេអាចទទួលបាននូវគណនេយ្យភាពខ្ពស់។ វិធីសាស្ត្រនៃគណនេយ្យភាពសាលារៀន-សហគមន៍បានរីករាលដាលយ៉ាងទូលំទូលាយនៅជុំវិញពិភពលោក (Figlio & Loeb, ២០១១) ហើយការសិក្សាស្រាវជ្រាវពីការអប់រំជាច្រើនបង្ហាញថា ការចូលរួមរបស់ភាគីដែលពាក់ព័ន្ធនានា ពោលគឺឪពុកម្តាយសិស្ស គណៈកម្មការទ្រទ្រង់សាលារៀន (SSCs) និងក្រុមប្រឹក្សាឃុំ/សង្កាត់ (CCs) នៅក្នុងការគ្រប់គ្រងធនធាន និងបុគ្គលិករបស់សាលារៀនមានសារៈសំខាន់ណាស់ចំពោះលទ្ធផលនៃការសិក្សារបស់អ្នករៀនសូត្រ (Hanushek & Raymond, ២០០៤, ២០០៥)។ នៅក្នុងន័យនេះ គណនេយ្យភាពត្រូវបានគេមើលឃើញថា ជាយន្តការមួយក្នុងចំណោមយន្តការជាច្រើនដែលលើកទឹកចិត្តឲ្យមន្ត្រីនានាធ្វើសកម្មភាព ដើម្បីផលប្រយោជន៍របស់សាធារណៈជន។ បើពុំមានសិទ្ធិទទួលបាននូវឯកសារនានាផ្នែកអភិបាលកិច្ច និងព័ត៌មានផ្សេងៗទៀតជាសាធារណៈទេ ធនធានដែល

មានតិចតួចស្តួចស្តើងរួចទៅហើយនេះអាចត្រូវបានគេប្រើប្រាស់ដោយខ្វះខ្វាយ ឬប្រើប្រាស់នៅក្នុងមធ្យោបាយដែលមិនត្រឹមត្រូវ។

នៅក្នុងប្រទេសកម្ពុជា គោលគំនិតផ្នែកវិមជ្ឈការ និងគណនេយ្យភាពទើបតែកើតឡើងក្នុងពេលថ្មីៗនេះប៉ុណ្ណោះ។ តាមប្រវត្តិសាស្ត្រ ប្រព័ន្ធនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈមជ្ឈការមែនទែនដោយសារការចូលរួមរបស់រដ្ឋាភិបាលថ្នាក់កណ្តាលស្ទើរតែនៅគ្រប់ការសម្រេចចិត្តទាំងអស់សម្រាប់ការប្រតិបត្តិ។ អង្គភាពសាធារណៈនៅថ្នាក់ក្រោមជាតិមានស្វ័យភាព ឬសិទ្ធិឯករាជ្យតិចតួចមែនទែន។ វាមិនមែនរហូតទាល់តែដល់ចុងទសវត្សឆ្នាំ១៩៩០ទេ ដែលវិមជ្ឈការត្រូវបានគេណែនាំនៅក្នុងប្រទេសកម្ពុជាដោយសារការជម្រុញយ៉ាងខ្លាំងក្លាពីសំណាក់ទីភ្នាក់ងារផ្តល់ជំនួយ។ ទីភ្នាក់ងារផ្តល់ជំនួយបានមើលឃើញថា ប្រព័ន្ធដែលបានរៀបចំរចនាសម្ព័ន្ធយ៉ាងល្អនៅថ្នាក់មូលដ្ឋានពុំបានធ្វើជាតំណាងដែលចាំបាច់របស់សហគមន៍ និងឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋានទេ។ ជាងនេះទៅទៀត ការចំណាយ ការធ្វើសេចក្តីសម្រេចចិត្ត និងការយល់ពីឥទ្ធិពល (ផលជះ) ពុំមានតម្លាភាពទេនៅថ្នាក់មូលដ្ឋាន។ ការយល់ដឹងពីសារៈសំខាន់របស់គណនេយ្យភាពតាមរយៈវិមជ្ឈការ រាជ-រដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តអនុវត្តកម្មវិធីកំណែទម្រង់យ៉ាងទូលំទូលាយ ដើម្បីបង្កើតនូវស្ថាប័នតាមបែបប្រជាធិបតេយ្យផ្សេងៗនៅថ្នាក់មូលដ្ឋាន និងដើម្បីធ្វើវិមជ្ឈការអំណាច។ នៅក្នុងឆ្នាំ២០០២ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតឲ្យមានក្រុមប្រឹក្សាឃុំ/សង្កាត់ឯករាជ្យ។ អ្នកទាំងឡាយណាដែលរស់នៅតាមតំបន់ជនបទមានសំឡេងមួយក្នុងការជ្រើសរើសអ្នកដឹកនាំតាមមូលដ្ឋានរបស់ខ្លួន ទោះបីជាអភិបាលស្រុក និងខេត្តនៅតែត្រូវបានតែងតាំងដោយរដ្ឋាភិបាលថ្នាក់កណ្តាលក៏ដោយ (Sendara & Ojendal, ២០០៧)។

នៅក្នុងវិស័យអប់រំ ការចូលរួមរបស់ភាគីដែលពាក់ព័ន្ធខុសៗគ្នានៅក្នុងដំណើរការសាលារៀនបានចាប់ផ្តើមជាមួយនឹងកម្មវិធី*កម្រងសាលារៀន* ដែលត្រូវបានគេណែនាំនៅក្នុងឆ្នាំ១៩៩២។ នៅពេលដែលកម្មវិធីនេះត្រូវបានគេវាយតម្លៃថាបានទទួលជោគជ័យចំពោះជំនួយបច្ចេកទេសដល់គ្រូបង្រៀន និងនាយកសាលា (Turner, ២០០២) ភារកិច្ចដទៃផ្សេងទៀតនៃការចូលរួមរបស់សហគមន៍នៅក្នុងការគ្រប់គ្រង និងដំណើរការរបស់សាលារៀន គឺទើបតែចាប់ផ្តើមនៅក្នុងពេលដូចគ្នានៃការបង្កើតគណៈកម្មការទ្រទ្រង់សាលារៀន (SSCs) នៅក្នុងឆ្នាំ២០០២ទេ។ តាមរយៈបទបញ្ជានេះ សាលារៀននីមួយៗត្រូវតែមានគណៈកម្មការទ្រទ្រង់សាលារៀនមួយ ហើយសមាជិករបស់គណៈកម្មការនោះរួមមានអាជ្ញាធរដែនដី និងបុគ្គលដែលលេចធ្លោនានា ដោយរាប់បញ្ចូលទាំងព្រះសង្ឃ ឪពុកម្តាយសិស្ស ក្នុងគោលបំណងឲ្យសហគមន៍ និងភាគីដែលពាក់ព័ន្ធផ្សេងៗទៀតចូលរួមក្នុងភារកិច្ចដែលទាក់ទងនឹងសាលារៀន ដោយរាប់ចាប់តាំងពីការគ្រប់គ្រងថវិការបស់សាលារៀនរហូតដល់ការធានាគុណភាពនៃការអប់រំ។ វត្តមានរបស់ SSCs បានកត់សម្គាល់នូវការរីកចម្រើនជាមូលដ្ឋានមួយរបស់រដ្ឋាភិបាលក្នុងការធ្វើឲ្យសហគមន៍បានចូលរួមកាន់តែទូលំទូលាយថែមទៀតនៅក្នុងការគ្រប់គ្រង និងដំណើរការសាលារៀន។ ដោយផ្អែកលើសេចក្តីណែនាំឆ្នាំ២០១២ ស្តីពីការបង្កើត SSCs សមាជិកទាំងអស់ត្រូវបានគេរំពឹងទុកថានឹងចូលរួមនៅក្នុងសកម្មភាពស្នូលចំនួន៨គឺ៖ (១) ការកសាង និងអនុវត្តផែនការអភិវឌ្ឍសាលារៀន (២) ការប្រមូល និងជម្រុញកុមារចូលរៀន (៣) ការតាមដានការសិក្សារៀនសូត្ររបស់សិស្ស (៤) ស្វែងរកចំណូល និងគ្រប់គ្រងថវិកា (៥) អភិវឌ្ឍ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន (៦) ចែករំលែកបទពិសោធន៍ និងបំណិនជីវិត (៧) ទប់ស្កាត់ភាពមិនប្រក្រតី និង (៨) ការកសាងសមត្ថភាព។

តារាងទី១ ៖ សេចក្តីណែនាំស្តីពីការចូលរួមរបស់ SSC នៅក្នុងសកម្មភាពរបស់សាលារៀន

| |
|---|
| **ក. កសាង និងអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន** |
| 1. ចូលរួមកសាងផែនការអភិវឌ្ឍន៍សាលារៀន ដោយពិភាក្សាកំណត់នូវបញ្ហា គោលបំណង សកម្មភាព ប្រភពថវិកា ពេលវេលាអនុវត្ត និងកម្មវិធីផ្សេងៗ។<br>2. ពិភាក្សាពីចំណុចបញ្ហារបស់សាលារៀន ដើម្បីរៀបចំការធ្វើផែនការទាក់ទងនឹងទិសដៅ សកម្មភាព ប្រភពចំណូល និងក្របខ័ណ្ឌពេលវេលា។<br>3. ចូលរួមក្នុងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរបស់សាលារៀន។<br>4. សហការជាមួយសាលារៀនដើម្បីធ្វើសមាហរណកម្មផែនការសាលារៀនទៅក្នុងផែនការវិនិយោគឃុំ/សង្កាត់។ |
| **ខ. ការប្រមូល និងជម្រុញកុមារចូលរៀន** |
| 1. គាំទ្រគ្រួសារដែលក្រីក្របំផុតដែលមិនអាចបញ្ជូនកូនមកសាលារៀនបាន។<br>2. លើកកម្ពស់ការយល់ដឹងចំពោះសារៈសំខាន់នៃការចូលរៀនដល់សហគមន៍។ |
| **គ. ការតាមដានការសិក្សារៀនសូត្ររបស់សិស្ស** |
| 1. ជួយផ្តល់ដំបូន្មានដល់មាតាបិតាសិស្សឲ្យត្រួតពិនិត្យមើលការសិក្សារៀនសូត្ររបស់កូនខ្លួន។<br>2. ទាក់ទងនាយកសាលា និងគ្រូបង្រៀនដើម្បីចែករំលែកព័ត៌មានស្តីពីការត្រួតពិនិត្យមើលសិស្ស ក្នុងគោលបំណងកែលម្អការសិក្សារៀនសូត្ររបស់សិស្ស។<br>3. ចូលរួមការប្រជុំត្រួតពិនិត្យប្រចាំខែជាមួយនាយកសាលា និងបុគ្គលិកផ្សេងៗទៀតរបស់សាលារៀន។<br>4. ចូលរួមផ្សព្វផ្សាយការងារសុខភាពនៅតាមសាលារៀន។ |
| **ឃ. ស្វែងរកចំណូល និងគ្រប់គ្រងថវិកា** |
| 1. ចូលរួមក្នុងសកម្មភាពនានាក្នុងការរៃអង្គាសមូលនិធិសម្រាប់ការកែលម្អសាលារៀន។<br>2. គ្រប់គ្រង និងប្រើប្រាស់ថវិការបស់សាលារៀន។ |
| **ង. ចូលរួមក្នុងការសាងសង់ ជួសជុល និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន** |
| 1. ចូលរួមនៅក្នុងការរៃអង្គាសមូលនិធិសម្រាប់ការកែលម្អបរិក្ខារសាលារៀន។<br>2. ត្រួតពិនិត្យការសាងសង់សាលារៀន និងសកម្មភាពក្នុងការថែរក្សា។ |
| **ច. ការចែករំលែកបទពិសោធន៍ និងបំណិនជីវិត** |
| 1. ចូលរួមនៅក្នុងការចែករំលែកចំណេះដឹងស្តីពីបំណិនជីវិតដល់សហគមន៍។<br>2. ចងក្រងនូវចំណេះដឹង និងបទពិសោធន៍ដែលលើកកម្ពស់បំណិនជីវិតទៅក្នុងឯកសារសម្រាប់ការរៀនសូត្ររបស់សិស្ស។ |
| **ឆ. ការទប់ស្កាត់ភាពមិនប្រក្រតីក្នុង និងក្រៅសាលារៀន** |
| 1. ផ្តល់ឲ្យសហគមន៍នូវព័ត៌មានដែលចាំបាច់ដើម្បីជៀសវាងនូវសកម្មភាពនានាដែលប្រឆាំងនឹងសាលារៀន និងការសិក្សារៀនសូត្ររបស់សិស្ស។<br>2. ផ្តល់ការគាំទ្រដល់សិស្សដែលប្រព្រឹត្តខុសឆ្គង<br>3. ដោះស្រាយនូវបញ្ហានានាដែលសិស្សបានបង្កឡើងនៅក្នុង និងនៅក្រៅសាលារៀន។ |

ជ. ការកសាងសម្ថតាពរបស់SSC

1. លើកកម្ពស់ការប្រាស្រ័យទាក់ទងរវាងសាលារៀន និងសហគមន៍។
2. ធ្វើការជាមួយ ក្រុមការងារបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក ស្តីពីការវាយតម្លៃការសិក្សារៀនសូត្ររបស់សិស្ស និងការអនុវត្តន៍ការងាររបស់គ្រូបង្រៀន។
3. ចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីការកសាងសមត្ថភាព។
4. ចូលរួមនៅក្នុងការងារតាមមូលដ្ឋានក្នុងគោលបំណងកែលម្អការបំពេញការងាររបស់សាលារៀន។

ក្រោយមក គំនិតផ្តួចផ្តើមនេះត្រូវបានពង្រឹងឡើងវិញដោយគោលនយោបាយនានាស្តីពីសាលាកុមារមេត្រី ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៥-២០០៩ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១០-២០១៤ និងគោលនយោបាយគ្រូបង្រៀនឆ្នាំ២០១២ ក្នុងគោលបំណងធានានូវភាពជាអ្នកដឹកនាំ និងគណនេយ្យភាពរបស់សាលារៀនឲ្យបានរឹងមាំតាមរយៈការឲ្យភាគីដែលពាក់ព័ន្ធផ្សេងៗគ្នា ចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់សាលារៀន។ នេះជាសញ្ញាល្អមួយចំពោះក្របខ័ណ្ឌ និងការរៀបចំបទបញ្ញានេះ ដោយសារតាមទ្រឹស្តីវាផ្តល់អំណាចដល់សហគមន៍ ព្រមទាំងនាំទៅរកការធ្វើសេចក្តីសម្រេចចិត្តតាមបែបចូលរួម និងនៅតាមមូលដ្ឋាននៅសាលារៀនបឋមសិក្សា។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាពីមុនៗមកស្តីពីការអនុវត្តរបស់គណៈកម្មការទ្រទ្រង់សាលារៀនបានរកឃើញថា SSCs នៅមិនទាន់អនុវត្តបាននូវយន្តការនេះឲ្យមានប្រសិទ្ធិភាពនៅឡើយទេដើម្បីបំពេញការទទួលខុសត្រូវ និងតួនាទីដែលមានចែងនៅក្នុងសេចក្តីណែនាំនានា។ ការខកខានពុំបានអនុវត្តតាមសេចក្តីណែនាំនានា ធ្វើឲ្យអភិបាលកិច្ចរបស់សាលារៀនមានកម្រិតខ្សោយមែនទែន ហើយធ្វើឲ្យអំណាច និងការចូលរួមរបស់សហគមន៍តាមមូលដ្ឋានមានកម្រិតបំផុតនៅក្នុងសេវាកម្មអប់រំជាសាធារណៈ។ ការវាយតម្លៃពីដំណើរការរបស់ SSCs បានទទួលស្គាល់ថា ពួកគាត់បានដើរតួនាទីដ៏សំខាន់មួយនៅក្នុងការអង្គាសមូលនិធិ និងការធានាសុវត្ថិភាពចំពោះការរួមវិភាគទានជាធនធានរបស់សហ-គមន៍ដល់សាលារៀន ប៉ុន្តែបានសន្និដ្ឋានថា តួនាទីផ្សេងៗជាច្រើនទៀតដែលគេរំពឹងទុកសម្រាប់ SCCs មិនត្រូវបានបំពេញជាទូទៅទេ។ សំឡេងរបស់ពួកគាត់នៅតែពុំត្រូវបានគេស្តាប់ដដែលនៅក្នុងការងារគ្រប់គ្រងសាលារៀន ហើយនាយកសាលានៅតែក្តោបក្តាប់យ៉ាងណែនទៅលើហិរញ្ញវត្ថុ និងការធ្វើសេចក្តីសម្រេចចិត្តរបស់សាលារៀន (Nguon, ២០១១; Pellini, ២០០៥, ២០០៧)។ ឪពុកម្តាយដែលបានចូលរួមនៅក្នុងការសិក្សាទាំងនេះមានទំនោរទៅរកការជឿជាក់ថា គ្រូបង្រៀនមានការទទួលខុសត្រូវទាំងស្រុងចំពោះការធានាថា កូនៗរបស់ខ្លួនទទួលបានការអប់រំនៅសាលារៀនប្រកបដោយគុណភាពល្អ។ ពួកគាត់យល់ពីតួនាទីផ្ទាល់ខ្លួនរបស់គាត់ និងតួនាទីរបស់គ្រូបង្រៀននៅក្នុងបរិបទដែលខុសគ្នាមួយ។ ចំពោះឪពុកម្តាយ តួនាទីចំបងរបស់គ្រូបង្រៀនគឺត្រូវបំពាក់ឲ្យកូនរបស់ខ្លួននូវជំនាញនៃការសិក្សា ហើយវាមិនសមស្របទេដែលឪពុកម្តាយទៅ"រំខាន" ចំពោះតួនាទីនេះ (Shoraku, ២០០៨)។ ជាតួយ៉ាង ឪពុកម្តាយកម្ពុជាបានចូលរួមតែក្នុងការបរិច្ចាកថវិកាដល់សាលារៀន ផ្តល់កំលាំងពលកម្មសម្រាប់ជួសជុលសាលារៀន និងចូលរួមនៅក្នុងការប្រជុំរបស់សាលារៀនប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ពួកគាត់ជាទូទៅមិនបានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ឬការរៀបចំថវិកា ឬសកម្មភាពផ្សេងៗទៀតរបស់សាលារៀនដែលជួយលើកកម្ពស់គុណភាពអប់រំសម្រាប់កូនៗរបស់ខ្លួនឡើយ។

ដោយយល់ឃើញពីចំណុចបញ្ហាដែលបានបញ្ជាក់ពីខាងដើមចំពោះការចូលរួមតិចតួចរបស់សហគមន៍នៅក្នុងគណនេយ្យភាពរបស់សាលារៀនទាំងនៅក្នុងសាលារៀននៅតាមជនបទ និងទីប្រជុំជន ក្រសួងអប់រំ

យុវជន និងកីឡា បានដាក់ចេញនូវវិធានការអទិភាពដែលទាក់ទងមួយចំនួននៅក្នុងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (TPAP) ដែលបានឯកភាពកាលពីឆ្នាំ២០១៥។ នៅក្នុងTPAP ក្រសួងអប់រំមានបំណងរៀបចំឲ្យមានភស្តុតាងជាមូលដ្ឋានស្តីពីសមត្ថភាព និងដំណើរការពិតប្រាកដរបស់ SCCs ដើម្បីបង្កើតគោលនយោបាយដ៏រឹងមាំមួយ តែមិនទាន់អាចធ្វើទៅបាននៅឡើយ ដែលគោលនយោបាយនេះធ្វើឲ្យមានលំហូរការងារ និងការបំពេញការងារប្រកបដោយប្រសិទ្ធិភាពចំពោះគណនេយ្យភាពរបស់សាលារៀននៅថ្នាក់មូលដ្ឋាន។ TPAP ក៏ដាក់ចេញនូវផែនការនានាផងដែរ ដើម្បីកែលម្អសមត្ថភាពតាមមូលដ្ឋានស្តីពីការគ្រប់គ្រងនៅតាមសាលារៀនផ្ទាល់ដែលគេមើលឃើញថា ជាតម្រូវការមួយដើម្បីមានលទ្ធភាពអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ (គោលនយោបាយD&D) របស់រាជរដ្ឋាភិបាលកម្ពុជា។ កំណែទម្រង់គោលនយោបាយ D&D ពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់អង្គភាពថ្នាក់ក្រោមជាតិក្នុងការបំពេញការងារផ្ទាល់របស់ខ្លួនដោយមានការគាំទ្រពីអង្គភាពថ្នាក់កណ្តាល និងថ្នាក់ជាតិ ប៉ុន្តែមិនមានការត្រួតត្រាដោយផ្ទាល់ទេ (Niazi, ២០១១)។ នៅក្នុងបរិបទនេះ ការសិក្សាស្រាវជ្រាវនេះមានបំណងផ្តល់ព័ត៌មានស្តីពីសកម្មភាពគោលនយោបាយសំខាន់ៗមួយចំនួន ដើម្បីឲ្យគេអនុវត្តនៅថ្នាក់ក្រោមជាតិ និងបន្ថែមទៅលើភស្តុតាងជាមូលដ្ឋានសម្រាប់គាំទ្រសកម្មភាពរបស់រាជរដ្ឋាភិបាល និងសហគមន៍ដើម្បីលើកកម្ពស់សេវាកម្មអប់រំ។

### *សំណួរសម្រាប់ការស្រាវជ្រាវ*

ក្នុងគោលបំណងពិនិត្យមើលពីតថភាពនៃគណនេយ្យភាពរបស់សាលារៀននៅក្នុងប្រទេសកម្ពុជា ការសិក្សាស្រាវជ្រាវនេះមានបំណងឆ្លើយនឹងសំណួរនានាដូចខាងក្រោម ៖

1. តើការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការសាលារៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅក្នុងប្រទេសកម្ពុជាបានកម្រិតណា?
2. តើកត្តាអ្វីខ្លះដែលទប់ស្កាត់ភាគីដែលពាក់ព័ន្ធទាំងអស់មិនឲ្យចូលរួមបានពេញលេញនៅក្នុងដំណើរការរបស់សាលារៀន?
3. តើសមាជិក SSC និងអ្នកផ្សេងៗទៀត ដែលមិនមែនជាសមាជិក SSCs មានការយល់ឃើញខុសគ្នា ឬទៅលើការអនុវត្ត និងការប្រឈមមុខនានារបស់ SSCs?
4. តើអ្វីជាការប្រតិបត្តិល្អនៃការចូលរួមរបស់សហគមន៍នៅក្នុងការលើកកម្ពស់គណនេយ្យភាពរបស់សាលារៀននៅក្នុងប្រទេសកម្ពុជា?

## ២. ការពិនិត្យមើលឯកសារដែលមានស្រាប់

គោលគំនិតនៃគណនេយ្យភាពរបស់សាលារៀនលេចរូបរាងឡើងជាលើកដំបូងនៅក្នុងទសវត្សឆ្នាំ១៩៦០ (Beneniste, ១៩៨៥)។ គោលបំណង និងអត្ថន័យរបស់វានៅតែកំពុងត្រូវបានគេស្វែងយល់នៅឡើយនៅក្នុងការប្រតិបត្តិជាក់ស្តែង និងនៅក្នុងឯកសារដែលមានស្រាប់ ហេតុដូច្នេះហើយពុំមានការយល់ដឹងដែលច្បាស់លាស់តែមួយគត់ពីគោលគំនិតនេះទេ។ ទោះជាយ៉ាងណាក៏ដោយ គោលដៅ និងនិយមន័យនានារបស់គណនេយ្យ-ភាពនៅក្នុងវិស័យអប់រំរាប់បញ្ចូលទាំងការជឿជាក់ចំពោះសេវាកម្មអប់រំនៅតាមមូលដ្ឋាន ស្វ័យបញ្ញត្តិ ច្បាប់ និងបដិញ្ញាការិយាធិបតេយ្យ គោលដៅ និងលទ្ធផលនៃការប្រតិបត្តិ គំនិតផ្តួចផ្តើមផ្នែកគោលនយោបាយ និងសេចក្តីណែនាំខាងនយោបាយ ហើយជាចុងក្រោយគឺទីផ្សារសាធារណៈ និងគ្រឿងលើកទឹកចិត្តរបស់រាជរដ្ឋា-ភិបាល (Burke, ២០០៥)។

***គំរូជាលក្ខណៈអន្តរជាតិនៃគណនេយ្យភាពសាលារៀនសម្រាប់ការប្រតិបត្តិ***

គណនេយ្យភាពសាលារៀនត្រូវបានគេអនុវត្តខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ ហើយពួកបញ្ញាវន្តក៏មានការយល់ឃើញផ្ទុយគ្នាដែរទោះបីជាស្ថិតនៅក្នុងបរិបទដូចគ្នាក៏ដោយ។ គោលគំនិតនៃគណនេយ្យភាពមានលក្ខណៈទូលំទូលាយមែនទែន ហើយគេអាចដោះស្រាយវាទៅតាមមធ្យោបាយផ្សេងៗជាច្រើន។ ឧទាហរណ៍ គេអាចដាក់បញ្ចូលការប្រើប្រាស់ដំណើរការផ្នែកនយោបាយ ដើម្បីបញ្ជាក់អះអាងពីគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ការណែនាំពីកំណែទម្រង់ដោយផ្តោតលើទីផ្សារដើម្បីបង្កើនគណនេយ្យភាពចំពោះឪពុកម្តាយ និងកុមារ ឬការបង្កើតប្រព័ន្ធគណនេយ្យភាពដោយផ្អែកលើការទទួលខុសត្រូវរួមគ្នា (peer-base) ដើម្បីបង្កើនគណនេយ្យភាពផ្នែកវិជ្ជាជីវៈរបស់គ្រូបង្រៀន (Figlio & Loeb, ២០១១)។ និយមន័យនៃពាក្យគណនេយ្យភាពដែលគេគិតគូរជាទូទៅបំផុតនោះ គឺទាក់ទងនឹងការប្រើប្រាស់យន្តការដែលមានមូលដ្ឋានលើទិន្នន័យរដ្ឋបាល ដែលមានបំណងបង្កើននូវលទ្ធផលសិក្សារបស់សិស្សតាមរយៈការលើកឡើងនូវស្នាដៃបំពេញការងាររបស់សាលារៀននីមួយៗ ឬគ្រឹះស្ថានអប់រំនានា។

ជាតួយ៉ាង ប្រទេសជាច្រើនប្រើប្រាស់នូវការធ្វើតេស្តស្តង់ដារដែលមានសារៈសំខាន់បំផុត (high-stake) ដើម្បីវាស់វែងពីស្នាដៃបំពេញការងាររបស់សាលារៀន និងដើម្បីធានាបាននូវគណនេយ្យភាពចំពោះសកម្មភាពនានារបស់សាលារៀន (Figlio & Loeb, ២០១១)។ វិធានការនៃការវាស់វែងពីគណនេយ្យភាពរបស់សាលារៀននេះ ត្រូវបានគេណែនាំជាលើកដំបូងនៅសហរដ្ឋអាមេរិកនៅក្នុងទសវត្សឆ្នាំ១៩៩០ ទោះបីវាត្រូវបានគេអនុវត្តយូរយារណាស់មកហើយក៏ដោយ នៅក្នុងចក្រភពអង់គ្លេសចាប់តាំងពីទសវត្សឆ្នាំ១៩៨០ (Burgess, Propper, Slatter, & Wilson, ២០០៥)។ គំរូមួយនៃការវាស់វែងមួយដូចនេះ ធ្វើឲ្យសាលារៀនស្ថិតនៅក្នុងស្ថានភាពនៃការទទួលរង្វាន់ និងការដាក់ទណ្ឌកម្ម។ តាមការរៀបរាប់ដោយសាមញ្ញ សាលារៀនទាំងឡាយណាដែលសិស្សរបស់ខ្លួនប្រតិបត្តិការសិក្សាបានល្អ ដោយទទួលបានលទ្ធផលល្អនៅក្នុងការប្រឡងថ្នាក់ជាតិ បានទទួលរង្វាន់ចំពោះការដំឡើងថវិការួម (budget share) ការតំឡើងប្រាក់បៀវត្សរ៍សម្រាប់សមាជិកបុគ្គលិករបស់ខ្លួន និង/ ឬស្វ័យភាពរបស់សាលារៀនច្រើនថែមទៀត ចំណែកឯសាលារៀនដែលសម្រេចលទ្ធផលបានទាបទទួលពិន័យពីរដ្ឋ។ លទ្ធផលនៃការប្រឡងថ្នាក់ជាតិមានបំណងដាក់បញ្ចូលនូវលទ្ធ-ផលនៃការសិក្សារៀនសូត្រសំខាន់ៗ និងស្តង់ដារដែលមានការឆ្លុះបញ្ចាំងជាមួយកម្មវិធីសិក្សាដែលបានកំណត់ដោយរដ្ឋាភិបាល។

Reeves (១៩៩៨) អះអាងថា គណនេយ្យភាពរបស់សាលារៀនមិនត្រូវដាក់បញ្ចូលតែពិន្ទុនៃការធ្វើតេស្តលទ្ធផលសិក្សាតែមួយមុខទេ ហេតុដូច្នេះហើយពិន្ទុមិនមែនជាការឆ្លុះបញ្ចាំងទាំងស្រុងទៅលើការរៀនសូត្ររបស់សិស្សឡើយ។ Reeves បានសង្កត់ធ្ងន់បន្ថែមទៀតទៅលើតួនាទី និងការទទួលខុសត្រូវរបស់គ្រូបង្រៀនសាលារៀន និងសហគមន៍។ ហេតុដូច្នេះហើយ គាត់បានផ្តល់នូវគោលការណ៍សំខាន់ៗចំនួន៥ ដែលត្រូវបានគេប្រើប្រាស់ដើម្បីវាស់វែងពីកម្រិតនៃគណនេយ្យភាពរបស់សាលារៀន៖ ភាពស្របគ្នា ភាពជាក់លាក់ ភាពជាប់ទាក់ទង ការគោរពចំពោះភាពខុសប្លែកគ្នា និងការកែលម្អជាបន្តបន្ទាប់។

សាលារៀនត្រូវមានគណនេយ្យភាពចំពោះការសិក្សារៀនសូត្ររបស់សិស្សដែលតាមធម្មតាត្រូវបានគេវាស់វែងទៅតាមពិន្ទុតេស្តស្តង់ដារ។ គណនេយ្យភាពនេះត្រូវបានអ្នកធ្វើសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយសន្មត់យ៉ាងទូលំទូលាយថា តាមពិតការធ្វើតេស្តពីខាងក្រៅក៏វាស់វែងបានគ្រប់គ្រាន់ដែរពីការរៀនសូត្ររបស់សិស្ស។ Jones, ២០០៤ អះអាងថា គេត្រូវតែចោទជាសំណួរចំពោះចំណុចទាំងនេះ និងការសន្មត់ផ្សេងៗទៀតអំពីគណនេយ្យភាពរបស់សាលារៀន ប្រសិនបើយើងត្រូវបង្កើតឲ្យមានគំរូគណនេយ្យភាពដែលកាន់តែទទួលជោគជ័យច្រើនថែមទៀត។ សាលារៀនក៏ត្រូវមានគណនេយ្យភាព ចំពោះសុខុមាលភាពផ្នែករាងកាយ និងអារម្មណ៍របស់សិស្ស ការសិក្សារៀនសូត្ររបស់សិស្ស ការសិក្សារៀនសូត្ររបស់គ្រូបង្រៀន សមធម៌ និងសិទ្ធិទទួលបាន ព្រមទាំងការកែលម្អដែរ។ ចំពោះចំណុចនេះ សាលារៀនក៏ត្រូវមានគណនេយ្យភាពចំពោះភាគីដែលពាក់ព័ន្ធចម្បងៗរបស់ខ្លួនផងដែរ ៖ សិស្សានុសិស្ស ឪពុកម្តាយ និងសហគមន៍មូលដ្ឋាន។ ហេតុដូច្នេះហើយ ប្រព័ន្ធគណនេយ្យភាពដែលបានកំណត់នៅក្នុងប្រព័ន្ធអប់រំរបស់ជាតិ ត្រូវជួយសាលារៀនឲ្យបំពេញតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវមានលទ្ធភាពកែលម្អការសិក្សារៀនសូត្ររបស់សិស្ស និងការប្រតិបត្តិរបស់សាលារៀន ផ្តល់នូវសេចក្តីណែនាំ និងព័ត៌មានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តនៅតាមមូលដ្ឋាន ព្រមទាំងផ្តល់នូវតុល្យភាពមួយនៃការទទួលខុសត្រូវ និងអំណាចក្នុងចំណោមស្ថាប័នរដ្ឋាភិបាលក្នុងកម្រិតខុសៗគ្នា។

Beneniste (១៩៨៥) បានណែនាំគោលបំណងសំខាន់នៃគណនេយ្យភាពរបស់សាលារៀននៅក្នុងលក្ខណៈយ៉ាងសាមញ្ញមួយ ពោលគឺដើម្បីត្រួតពិនិត្យ និងវាយតម្លៃថា តើសាលារៀនបានបំពេញការងារបានល្អកម្រិតណាដើម្បីឲ្យគេអាចផ្តល់រង្វាន់ដល់សាលារៀនដែលមានស្នាដៃបំពេញការងារល្អ ខណៈដែលការដាក់ពិន័យអាចត្រូវបានគេដាក់ទៅលើសាលាដែលអនុវត្តការងារពុំបានល្អ។ គំរូនេះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយចាប់តាំងពីពេលនោះមក។ បើយោងតាម Beneniste គណនេយ្យភាពរបស់សាលារៀន មានតួនាទីសំខាន់ៗចំនួន៣គឺ៖ ដើម្បីជូនដំណឹង ដើម្បីណែនាំសកម្មភាពឡើងវិញ និងដើម្បីកែសម្រួលអ្វីដែលគេបានធ្វើ។ យន្តការគណនេយ្យភាពផ្តល់នូវព័ត៌មានដល់សាធារណៈជនអំពីអ្វីដែលសាលារៀនកំពុងធ្វើ និងបញ្ជូនព័ត៌មានមកឲ្យសាលារៀនវិញអំពីអ្វីដែលសាធារណជនចង់បាន។ ព័ត៌មាននេះត្រូវបានគេប្រើប្រាស់ដើម្បីជួយសាលារៀន គ្រូបង្រៀន សិស្ស និងសាធារណៈជនឲ្យយល់ពីគ្នាទៅវិញទៅមកកាន់តែច្បាស់ថែមទៀត។ ដំណាក់កាលទី២ គឺត្រូវស្នើសុំឲ្យគ្រូបង្រៀន ឬសាលារៀនឲ្យកែលម្អភារកិច្ច និងស្នាដៃបំពេញការងារជាក់លាក់មួយចំនួន។ ដំណាក់កាលនេះត្រូវធ្វើឡើងនៅពេលដែលការផ្តល់រង្វាន់ជាវិជ្ជមាន និងការដាក់ពិន័យត្រូវបានគេដាក់បញ្ចូលប្រសិនបើសាលារៀននៅតែពុំបានអនុវត្តការងារបានល្អបន្ទាប់ពីមានធនធាន ឬជំនួយបន្ថែមទៀត។ Beneniste ព្រមានថា ប្រព័ន្ធគណនេយ្យភាព ពេលខ្លះត្រូវបានគេប្រើប្រាស់ខុសដើម្បីកែតម្រូវការអនុវត្តជាក់ស្តែងដែលគេមិនចង់បាន ហើយថារដ្ឋាភិបាលមួយចំនួនបានប្រើប្រាស់ប្រព័ន្ធនេះដើម្បីវាស់វែងពីអ្វីដែលខ្លួនសម្រេចបានរួចទៅហើយ។ ចំពោះចំណុចនេះ Beneniste ជឿជាក់ថាប្រព័ន្ធគណនេយ្យភាពអាចជាកាំបិតមុខពីរ។

ជាការគួរឲ្យចាប់អារម្មណ៍ Finn (២០០២) បានប្រៀបធៀបប្រព័ន្ធគណនេយ្យភាពវិស័យអប់រំទៅនឹងតួអង្គសំខាន់ៗចំនួន៤ ៖ Bob ជាតួអង្គដែលអនុវត្តតាមច្បាប់ និងនិតិវិធី។ Carol ជាតួអង្គដែលជឿជាក់លើវិជ្ជាជីវៈ និងជំនាញឯកទេស។ Ted ជាតួអង្គដែលជឿជាក់លើស្តង់ដារដែលបានកំណត់ និងពិនិត្យ ផ្ទៀងផ្ទាត់ដោយប្រៀបធៀបទៅនឹងស្តង់ដារទាំងនេះ ព្រមទាំង Alice ជាតួអង្គដែលជឿជាក់លើអតិថិជនក្នុងការទាមទារ និងជ្រើសរើសអ្វីដែលគេត្រូវការតាមរយៈសេវាកម្មរបស់ទីផ្សារ។ Finn វាយតម្លៃថា ប្រទេសជាច្រើននៅជុំវិញពិភពលោកកំពុងតែប្រើប្រាស់ Ted ដែលជាប្រព័ន្ធពីលើចុះក្រោមមួយដែលស្តង់ដារជាតិ និងការធ្វើតេស្តទូទាំងប្រទេសត្រូវបានគេប្រើប្រាស់ដើម្បីត្រួតពិនិត្យមើលជាប្រចាំទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស។ គាត់បានអះអាងថា ក្នុងគោលបំណងធ្វើឲ្យប្រព័ន្ធគណនេយ្យភាពវិស័យអប់រំមានដំណើរការផ្នែកនីមួយៗ ក្នុងចំណោមផ្នែកទាំង៤នេះ ចាំបាច់ត្រូវមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក។ នៅក្នុងចំណុចនេះស្តង់ដារជាតិដែលត្រូវបានគេបង្កើតឡើងតាមរយៈច្បាប់ ហើយបទបញ្ញាផ្សេងៗត្រូវតែកំណត់សម្រាប់អាជ្ញាធរមូលដ្ឋាននីមួយៗ ដើម្បីឲ្យមានលក្ខណៈច្បាស់លាស់ពីអ្វីដែលគេត្រូវសម្រេចឲ្យបាន។ នៅក្នុងចំណុចនេះ ការប៉ាន់ស្មាន និងការវាយតម្លៃពីលទ្ធផលនៃការអប់រំមិនត្រូវបានគេផ្តោតតែទៅលើពិន្ទុតេស្តនោះទេ ប៉ុន្តែទៅលើជំនាញ និងចំណេះដឹងដែលទីផ្សារពលកម្មត្រូវការផងដែរ។ អាជ្ញាធរមូលដ្ឋាន និងសាលារៀនចាំបាច់ត្រូវស្វាគមន៍ការពិនិត្យរបស់សមាជិកសហគមន៍ អ្នកមានវិជ្ជាជីវៈ និងអ្នកឯកទេស ដើម្បីគាំទ្រដល់ដំណើរការកាន់តែប្រសើរឡើងនាពេលអនាគត។

រដ្ឋាភិបាល ឬអាជ្ញាធរអប់រំតាមមូលដ្ឋានមួយចំនួនដាក់បញ្ចូលអនុក្រុមសូចនាករមួយចំនួនដូចជាអត្រាវត្តមានរបស់សិស្ស និង ឬគ្រូបង្រៀន អត្រាបោះបង់ការសិក្សា និងអត្រាគង់វង្សបន្ថែមទៅលើលទ្ធផលនៃការធ្វើតេស្តរបស់សិស្សនៅក្នុងការគណនាពីសន្ទស្សន៍ ដែលគេប្រើប្រាស់សម្រាប់គណនេយ្យភាពរបស់សាលារៀន។ ជាទូទៅ សូចនាករដែលមិនមែនជាការធ្វើតេស្ត ត្រូវបានគេផ្តល់តម្លៃតិចជាងលទ្ធផលនៃការធ្វើតេស្តរបស់សិស្សនៅក្នុងសន្ទស្សន៍នៃការប្រតិបត្តិទូទៅ។ តម្លៃប្រកបដោយប្រសិទ្ធិភាព តាមធម្មតាមានតម្លៃតិចជាងតម្លៃដែលគេចាត់តាំងជាផ្លូវការសម្រាប់ទិន្នន័យដែលមិនមែនជាការធ្វើតេស្ត ដោយសារតម្លៃដែលមានប្រសិទ្ធិភាពរបស់ផ្នែកមួយនៃសន្ទស្សន៍គណនេយ្យភាពពឹងផ្អែកទៅលើភាពខុសប្លែកគ្នារបស់ផ្នែកផ្សេងៗពីសាលារៀនមួយទៅសាលារៀនមួយ ហើយសូចនាករនានាដូចជាវត្តមានប្រចាំថ្ងៃជាមធ្យម មានភាពប្រែប្រួលតិចជាងនៅគ្រប់សាលាទាំងអស់ជាងលទ្ធផលនៃការធ្វើតេស្ត។ ទោះជាយ៉ាងនេះក្តី ការដាក់បញ្ចូលសូចនាករដែលមិនមែនជាការធ្វើតេស្តអាចបញ្ជូនសារមួយដែលថាលក្ខណៈផ្សេងៗដូចជា ការឡើងថ្នាក់ទាន់ពេលវេលា អត្រាបញ្ចប់ការសិក្សា និងវត្តមានទាំងគ្រូបង្រៀន និងសិស្សត្រូវបានគេឲ្យតម្លៃ (Linn, ២០០៤)។

គំរូដែលមានឥទ្ធិពល និងល្បីល្បាញមួយផ្សេងទៀតទាក់ទងនឹងប្រព័ន្ធគណនេយ្យភាពក្នុងវិស័យអប់រំត្រូវ បាន Levin (១៩៧៤) ណែនាំ។ Levin បានរៀបចំក្របខ័ណ្ឌទ្រឹស្តីដ៏រឹងមាំមួយនៃគណនេយ្យភាពរបស់សាលារៀនថាជាដំណើរការមួយនៃការរាយការណ៍ពីការប្រតិបត្តិ ជាដំណើរការផ្នែកបច្ចេកទេស ជាដំណើរការផ្នែកនយោបាយ និងជាដំណើរការផ្នែកស្ថាប័ន។ ការរាយការណ៍ពីស្នាដៃបំពេញការងាររបស់សាលារៀន ជាទូទៅគឺមានមូលដ្ឋានលើការប្រឡង និងលទ្ធផលសំខាន់ៗផ្សេងទៀតរបស់សិស្សសម្រាប់ភាគីពាក់ព័ន្ធ ផ្នែកអប់រំ ដើម្បីឲ្យគេអាចវាយតម្លៃស្នាដៃបំពេញការងាររបស់សាលារៀនបាន។

ដំណើរការផ្នែកបច្ចេកទេសគឺជាគោលដៅសម្រាប់សម្រេចបានប្រព័ន្ធនៃការចុះឈ្មោះចូលរៀន។ ការចុះឈ្មោះចូលរៀនមានគោលដៅច្បាស់លាស់ផ្សេងៗរបស់វា ហើយដំណើរការផ្នែកបច្ចេកទេសធ្វើឲ្យទទួល

ជោគជ័យនៃការសម្រេចបានគោលដៅនានាទោះបីជាមានឧបសគ្គផ្នែកហិរញ្ញវត្ថុ ធនធានមនុស្ស និងកត្តាផ្សេងៗទៀតក៏ដោយ។ ក្នុងការធ្វើដូច្នេះ ជាទូទៅ គំរូនៃការធានាគុណភាពត្រូវបានគេប្រើប្រាស់ដើម្បីកែលម្អប្រសិទ្ធិផល និងប្រសិទ្ធិភាពរបស់សាលារៀនថាជាប្រព័ន្ធនៃការប្រតិបត្តិមួយ។ ដំណើរការផ្នែកនយោបាយព្យាយាមឆ្លើយនឹងសំណួរថាតើ សាលារៀនត្រូវមានគណនេយ្យភាពចំពោះអ្នកណា បើទោះបីជាគោលដៅរួមនានានៃការអប់រំ និងរបស់សាលារៀនត្រូវបានគេកំណត់ជាក់លាក់រួចហើយក៏ដោយ។ តាមធម្មតា សាលារៀនឈរជាតំណាងឲ្យតម្រូវការនានារបស់ភាគីដែលពាក់ព័ន្ធខុសៗគ្នាដែលពួកគេម្នាក់ៗ មានគោលដៅនៃការអប់រំខុសៗគ្នា។ ដំណើរការផ្នែកនយោបាយស្វែងរកការធ្វើឲ្យក្រុមមួយពេញចិត្តជាងក្រុមមួយផ្សេងទៀត។ នៅក្នុងគោលគំនិតនៃគណនេយ្យភាពដែលជាដំណើរការមួយផ្នែកស្ថាប័ន ភាពស្របច្បាប់នៃដំណើរការនៃការអប់រំដែលជួយនាំទៅរកសង្គមមួយដែលកាន់តែល្អប្រសើរ គេចាំបាច់ត្រូវតែកំណត់ និងផ្តល់ឲ្យ។ ដោយប្រើប្រាស់គំរូរបស់ Levin Ng (២០១០) មានលទ្ធភាពកំណត់ពីការវាយតម្លៃប្រព័ន្ធគណនេយ្យភាពរបស់សាលារៀននៅក្នុងប្រទេសសឹង្ហបូរី។ គាត់បានរកឃើញថា ប្រទេសសឹង្ហបូរីប្រើប្រាស់ដំណើរការនៃការធ្វើរបាយការណ៍ និងបច្ចេកទេសក្នុងអំឡុងពេលនៃ "ដំណាក់កាលនៃការកំណត់ស្តង់ដារ" (នៅពាក់កណ្តាលទសវត្សឆ្នាំ១៩៦០ ដល់ពាក់កណ្តាលទសវត្សឆ្នាំ១៩៨០) ដំណើរការផ្នែកនយោបាយនៅក្នុងអំឡុងនៃ "ដំណាក់កាលនៃគណនេយ្យ-ភាពតាមមូលដ្ឋាន" (ពាក់កណ្តាលទសវត្សឆ្នាំ១៩៨០ ដល់ពាក់កណ្តាលទសវត្សឆ្នាំ១៩៩០) និងដំណើរការផ្នែកស្ថាប័ននៅក្នុងអំឡុងពេលនៃ "ដំណាក់កាលនៃការផ្តល់ និងការផ្ទេរប្រឌិត" (ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ រហូតដល់បច្ចុប្បន្ន)។

ទោះបីជាគំរូខុសៗគ្នាត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយដើម្បីពន្យល់ និងវាស់វែងពីកម្រិតនៃគណនេយ្យភាពរបស់សាលារៀនក៏ដោយ ក៏ការឯកភាពរួមគ្នាលើការពន្យល់នានា និងការវាស់វែងពីស្នាដៃបំពេញការងារដែលសមស្របនៅមិនទាន់មាននៅឡើយ។ ទោះជាយ៉ាងនេះក្តី នៅក្នុងការពិនិត្យមើលឡើងវិញនូវឯកសារដែលមានស្រាប់យ៉ាងទូលំទូលាយស្តីពីស្នាដៃបំពេញការងារ និងគំរូគណនេយ្យភាព យើងអាចមើលឃើញពីភាពដូចគ្នា (commonalities) ជាច្រើន។ មានការយល់ឃើញរួមគ្នាមួយថា សាលារៀនចាំបាច់ត្រូវបំពេញការងារនៅក្នុងមធ្យោបាយមួយ ដើម្បីធានាបាននូវការអនុម័តយល់ព្រមពីសំណាក់សាធារណជន ដើម្បីសម្រេចបាននូវលទ្ធផលដែលមានតម្លៃខ្ពស់ (high value-outcome) ទោះបីថវិកា ដែលគេផ្តល់ឲ្យមានចំនួនតិចតួចក៏ដោយ។ ទោះជាយ៉ាងនេះក្តី វាទប្បដិវាទកើតចេញពីការកំណត់លទ្ធផលដែលគេចង់បានចំពោះការចុះឈ្មោះចូលរៀន។

### *ការគ្រប់គ្រងដោយផ្អែកលើសាលារៀន*

គំរូនៃការគ្រប់គ្រងដោយផ្អែកលើសាលារៀនត្រូវបានអនុវត្តនៅក្នុងប្រទេសអភិវឌ្ឍជាច្រើន ដូចជាប្រទេសអង់គ្លេស ញូវហ្សឺឡែន ឬ Victoria អូស្ត្រាលី កាណាដា និងសហរដ្ឋអាមេរិកសម្រាប់រយៈពេលពីរបីទសវត្សកន្លងមកនេះ។ ជាសំខាន់ ការគ្រប់គ្រងដោយផ្អែកលើសាលារៀនពាក់ព័ន្ធនឹងប្រភេទមួយចំនួននៃការផ្ទេរការទទួលខុសត្រូវ និងការធ្វើសេចក្តីសម្រេចចិត្ត ដែលជារឿយៗការទទួលខុសត្រូវចំពោះប្រតិបត្តិការរបស់សាលារៀន ផ្ទេរទៅឲ្យនាយកសាលា គ្រូបង្រៀន ឪពុកម្តាយ និងសមាជិកសហគមន៍ផ្សេងៗទៀតរបស់សាលារៀនទទួលខុសត្រូវរួមគ្នាតែម្តង (Barrera-Osorio, Fasih, & Patrinos, ២០០៩)។ Caldwell (n.d) កំណត់វាថាជា "ការធ្វើវិមជ្ឈការជាលក្ខណៈប្រព័ន្ធទៅឲ្យសាលារៀននូវសិទ្ធិ និងការទទួលខុសត្រូវក្នុងការធ្វើ

សេចក្តីសម្រេចចិត្តទៅលើកិច្ចការសំខាន់ៗទាក់ទងនឹងប្រតិបត្តិការរបស់សាលារៀននៅក្នុងក្របខ័ណ្ឌ ដែលគេបានកំណត់នៅថ្នាក់កណ្តាលទាក់ទងនឹងគោលដៅ គោលនយោបាយ កម្មវិធីសិក្សា ស្តង់ដារ និងគណនេយ្យភាព"។

ជាប្រវត្តិសាស្ត្រ ទោះបីជាប្រទេសជាច្រើនបានអនុវត្តប្រព័ន្ធមជ្ឈការនៅក្នុងវិស័យអប់រំដែលផ្តល់អំណាច និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តទាំងអស់ទៅឲ្យរដ្ឋាភិបាលថ្នាក់កណ្តាលក៏ដោយ ក៏នៅដើមសតវត្សទី២១ គេអាចមើលឃើញនៅចលនានានានៅទូទាំងពិភពលោកក្នុងការកែប្រែរូបភាពនៃការងាររដ្ឋបាលសាធារណៈទៅជាប្រព័ន្ធវិមជ្ឈការ។ នៅក្នុងវិស័យអប់រំមានកំណែទម្រង់ប្រព័ន្ធសំខាន់ៗចំនួន៣ ដែល Caldwell និង Spinks (១៩៩៨) បានរកឃើញ ៖ ការកសាងនូវប្រព័ន្ធស្វ័យគ្រប់គ្រងរបស់សាលារៀន (ការគ្រប់គ្រងដោយផ្អែកលើសាលារៀន) ការផ្តោតដោយគ្មានការប្រែប្រួលទៅលើលទ្ធផលនៃការសិក្សារៀនសូត្រ និងការបង្កើតឡើងនូវសាលារៀនសម្រាប់សង្គមពុទ្ធិ និងសេដ្ឋកិច្ចសកល។ សេចក្តីសន្និដ្ឋានរបស់ពួកគាត់គឺថា ការគ្រប់គ្រងដោយផ្អែកលើសាលារៀន បានក្លាយទៅជារឿងសាមញ្ញបំផុតក្នុងចំណោមគោលនយោបាយអប់រំរបស់ជាតិ ហើយថា មូលនិធិចម្បងៗនានាត្រូវបានគេលៃបម្រុងទុកសម្រាប់អនុវត្តប្រព័ន្ធបែបនេះនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។

គោលគំនិតស្នូលមួយនៃការគ្រប់គ្រងដោយផ្អែកលើសាលារៀនគឺត្រូវធានាថាសាលារៀននីមួយៗ និងការិយាល័យអប់រំតាមមូលដ្ឋានមានគណនេយ្យភាពចំពោះឪពុកម្តាយ សិស្ស អ្នកបោះឆ្នោតនៅតាមមូលដ្ឋាន និងអ្នកនយោបាយនៅមូលដ្ឋាន។ ស្វ័យភាពក្នុងកម្រិតខ្ពស់ត្រូវបានគេផ្តល់ឲ្យសាលារៀន ដើម្បីឲ្យសាលារៀនអាចប្រតិបត្តិការបានដោយឯករាជ្យ។ សាលារៀននីមួយៗត្រូវតែផ្តល់ឲ្យនូវលទ្ធផលចុងក្រោយនៃ "គុណភាពអប់រំខ្ពស់ និងដែលគេចង់បាន"។ ជាទូទៅ សាលារៀន និងសហគមន៍មូលដ្ឋានមានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តកាន់តែខ្លាំងទាក់ទងនឹងខ្លឹមសារនៃការសិក្សារៀនសូត្រ ការធ្វើផែនការចំណាយ ការធ្វើផែនការសម្រាប់អភិវឌ្ឍ និងកែលម្អសាលារៀន ព្រមទាំងការអនុវត្តភារកិច្ចផ្សេងៗ ជាច្រើនដោយខ្លួនឯងផ្ទាល់។ ទោះជាយ៉ាងណាក៏ដោយ ជាការឆ្លើយតប សាលារៀនចាំបាច់ត្រូវមានគណនេយ្យភាពចំពោះការសម្រេចចិត្តរបស់ខ្លួនក្នុងការប្រើប្រាស់ធនធានដែលមានតាមរយៈការផ្តល់នូវលទ្ធផលដែលគេចង់បាននៅក្នុងដំណើរការនៃការអប់រំ (Mayston & Jesson, ១៩៨៨)។ នោះគឺអ្វីដែលគោលគំនិតនៃគណនេយ្យភាពរបស់សាលារៀនមានសារៈសំខាន់ចំពោះវិធីសាស្ត្រនៃការគ្រប់គ្រងដោយផ្អែកលើសាលារៀន។

ទោះបីជាការគ្រប់គ្រងដោយផ្អែកលើសាលារៀន ត្រូវបានគេមើលឃើញថាជាគំរូប្រកបដោយជោគជ័យមួយនៃការគ្រប់គ្រងការងារអប់រំនៅក្នុងប្រទេសអភិវឌ្ឍ តាមរយៈការកើនឡើងនូវលទ្ធផលនៃការសិក្សារបស់សិស្សក៏ដោយ ក៏ការសិក្សានានាទៅលើផលជះរបស់វានៅក្នុងប្រទេសកំពុងអភិវឌ្ឍ បានបង្ហាញឲ្យឃើញនូវការកែលម្អតិចតួចចំពោះគុណភាពអប់រំ (ឧទាហរណ៍ Fullan & Watson, ២០០០; Ouchi & Segal, ២០០៣; Volansky & Friedman, ២០០៣)។ កង្វះនូវភាពជោគជ័យនេះត្រូវបានគេសន្មត់ថា បណ្តាលមកពីថវិកាទាបនៅក្នុងប្រទេសកំពុងអភិវឌ្ឍ សមត្ថភាពទាបរបស់នាយកសាលានៅក្នុងការប្រតិបត្តិសាលារៀនផ្ទាល់របស់ខ្លួន និងការធានាសុវត្ថិភាពចំពោះការចូលរួមរបស់សហគមន៍ ឲ្យបានកាន់តែទូលំទូលាយឡើងនៅក្នុងការអភិវឌ្ឍ និងដំណើរការរបស់សាលារៀន។

### *ការចូលរួមរបស់សហគមន៍ និងគណនេយ្យភាពរបស់សាលារៀន*

ដូចដែលបានពន្យល់នៅក្នុងផ្នែកខាងលើការចូលរួមរបស់សហគមន៍មូលដ្ឋានត្រូវបានគេបង្ហាញថា ជាជំនួយដ៏ច្រើនសម្រាប់សាលារៀនក្នុងការប្រតិបត្តិដំណើរការរបស់ខ្លួនឲ្យបានពេញលេញបំផុត។ ការទទួលខុសត្រូវរួមគ្នារបស់សហគមន៍មូលដ្ឋានក្នុងការអភិវឌ្ឍសាលារៀនជួយកំណត់អត្ថន័យពិតប្រាកដនៃគណនេយ្យភាពរបស់សាលារៀន (Linn, ២០០៣)។ ការចូលរួមរបស់សាធារណជន ពោលគឺមិនមែនត្រឹមតែក្នុងចំណោមអ្នកអប់រំ និងសិស្សានុសិស្សប៉ុណ្ណោះទេ តែថែមទាំងអ្នកកាន់ការងាររដ្ឋបាល អ្នករៀបចំគោលនយោបាយ ឪពុកម្តាយ និងអ្នកស្រាវជ្រាវផ្នែកអប់រំកែលម្អការអប់រំបានតាមរយៈការទទួលខុសត្រូវរួមគ្នា។ នៅក្នុងន័យនេះ ប្រព័ន្ធគណនេយ្យភាពដែលមានប្រសិទ្ធិភាពមួយត្រូវពាក់ព័ន្ធគ្រប់ភាគីទាំងអស់នៅក្នុងការងារអប់រំរួម ឬជាសាធារណៈ។ ការចូលរួមមិនគ្រាន់តែកែលម្អគណនេយ្យភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្នែកផ្សេងៗនៃគណនេយ្យភាពដែលមិនអាចញែកឲ្យដាច់ពីគ្នាបាន ដូចជាស្វ័យភាព គណនេយ្យភាព និងការជឿទុកចិត្ត (Burke, ២០០៥; Cornwall, Lucas & Pasteur, ២០០០)។

សហគមន៍អាចចូលរួមនៅក្នុងសកម្មភាពមួយចំនួនដើម្បីធានាថា សាលារៀនកំពុងនាំមកនូវលទ្ធផលដែលគេចង់បានសម្រាប់កូនៗរបស់គាត់។ ឧទាហរណ៍ ដោយមានព័ត៌មាន និងការគាំទ្រត្រឹមត្រូវ សហគមន៍អាចត្រួតពិនិត្យ និងវាយតម្លៃការងាររបស់សាលារៀន និងគ្រូបង្រៀន។ នៅត្រង់ចំណុចនេះ ពួកគាត់អាចពិនិត្យមើលពីរបៀបដែលសាលារៀន និងគ្រូបង្រៀនអនុវត្តកម្មវិធីសិក្សារបស់ជាតិសម្រាប់ការរៀនសូត្រពេញលេញរបស់សិស្សានុសិស្ស ព្រមទាំងរកឲ្យឃើញនូវឧបសគ្គនានាដែលសាលារៀន និងគ្រូបង្រៀនមាន និងស្វែងរកដំណោះស្រាយដែលអាចធ្វើទៅបាន។ ទី២ សាលារៀនក៏ត្រូវការជំនួយពីសហគមន៍ដែរ ក្នុងការរៀបចំផែនការកែលម្អសាលារៀន និងផែនការថវិកា។ តាមការអះអាង ចំណុចនេះមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍដែលភស្តុតាងនានាបញ្ជាក់ថា នាយកសាលា និងបុគ្គលិករបស់សាលារៀនមានសមត្ថភាពទាបក្នុងការរៀបចំផែនការអប់រំ។ ការចូលរួមរបស់សហគមន៍ក៏ជាយន្តការមួយដែរក្នុងការធានាបាននូវតម្លាភាពចំពោះតួនាទី និងការទទួលខុសត្រូវរបស់សាលារៀន។ សហគមន៍ អាចធ្វើការជាមួយសាលារៀនក្នុងការលើកកម្ពស់បរិស្ថានល្អសម្រាប់ការរៀន និងការបង្រៀន ពេលខ្លះរាប់បញ្ចូលទាំងទិដ្ឋភាពនានាដែលគេពិពណ៌នាថា សាលារៀន “មានលក្ខណៈមេត្រីសម្រាប់ការរៀនសូត្រ” ដែលរាប់បញ្ចូលទាំងសុវត្ថិភាព ភាពស្រស់ស្អាត និងបរិស្ថានរូបវន្តរបស់សាលារៀន។

### *គណនេយ្យភាព ស្នាដៃបំពេញការងាររបស់សាលារៀន និងការសិក្សារៀនសូត្ររបស់សិស្សានុសិស្ស*

ភស្តុតាងជាអន្តរជាតិបង្ហាញថា គណនេយ្យភាពជួយផ្តល់នូវស្នាដៃបំពេញការងារខ្ពស់របស់សាលារៀនដែលទីបញ្ចប់លើកកម្ពស់ការសិក្សារៀនសូត្ររបស់សិស្ស។ ការសិក្សាស្រាវជ្រាវដែលលេចធ្លោមួយស្តីពីកំណែទម្រង់គណនេយ្យភាពថ្មីៗនេះ បានរកឃើញនូវឥទ្ធិពលវិជ្ជមាននានា ទៅលើលទ្ធផលនៃការរៀនសូត្ររបស់សិស្សនៅក្នុងការប្រឡងថ្នាក់ជាតិ (ឧទាហរណ៍ Burgess, et al., ២០០៥ Carnoy និង Loeb ២០០៣; Hanushek និង Raymond ២០០៤)។ បើយោងតាមទ្រឹស្តីនៃសកម្មភាពរបស់គណនេយ្យភាព (Amo, ២០១៥; Figlio& Ladd, ២០០៧; Jacob, ២០០៥; Smith & O’Day, ១៩៩០) ការធ្វើឲ្យអ្នកអប់រំ និងថ្នាក់ដឹកនាំសាលារៀនមានគណនេយ្យភាពចំពោះលទ្ធផលនៃការសិក្សារៀនសូត្ររបស់សិស្សានុសិស្ស (ពោលគឺគណនេយ្យភាពដែលផ្អែកលើលទ្ធផលនៃការសិក្សានឹងជំរុញលើកទឹកចិត្តពួកគាត់ធ្វើឲ្យភាពស្របគ្នារវាងអាកប្ប

កិរិយា និងការអនុវត្តការណែនាំដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្ស។ នៅក្នុងការសិក្សានានារបស់ Deere និងStrayer (២០០១) ព្រមទាំង Cullen និង Reback (២០០៦) នៅក្នុងរដ្ឋ Texas គណនេយ្យភាពកាន់តែទូលំទូលាយឡើង គឺជាប់ទាក់ទងនឹងការកើនឡើងយ៉ាងច្រើនចំពោះអត្រាគង់វង្សនៅក្នុងថ្នាក់។ ការសិក្សាមួយចំនួនបានរកឃើញថា គោលនយោបាយគណនេយ្យភាពកាន់តែមានប្រសិទ្ធិភាពច្រើនថែមទៀតនៅតាមបណ្តារដ្ឋនានា ដែលមានការធ្វើប្រតិភូកម្មកាន់តែច្រើនឡើងនូវការធ្វើសេចក្តីសម្រេចចិត្តទៅឲ្យថ្នាក់មូលដ្ឋាន។ ឧទាហរណ៍ Loeb និង Strunk (២០០៧) បានសន្និដ្ឋានថា បើគ្មានការត្រួតត្រាខ្លះពីថ្នាក់មូលដ្ឋានទេ ទោះបីគោលនយោបាយគណនេយ្យភាពត្រូវបានគិតគូរយ៉ាងល្អិតល្អន់យ៉ាងណាក៏ដោយ ក៏គោលនយោបាយនោះមានប្រសិទ្ធិភាពតិចដែរ ហើយពេលខ្លះគ្មានប្រសិទ្ធិភាព និងបង្កការឈឺចាប់ទៀតផង។

គណនេយ្យភាពរបស់សាលារៀនមិនត្រឹមតែកែលម្អពិន្ទុតេស្តរបស់សិស្សានុសិស្សប៉ុណ្ណោះទេ។ បញ្ញវន្តផ្នែកគណនេយ្យភាពមួយចំនួន ដែលមានទទ្បីករប្រឆាំងនឹងការប្រើប្រាស់ពិន្ទុតេស្ត នៅក្នុងការកំណត់គណនេយ្យភាពរបស់សាលារៀនបានរៀបចំការសិក្សាជាច្រើន ដើម្បីពិនិត្យមើលពីរបៀបដែលគណនេយ្យភាពដើរតួនាទីដ៏សំខាន់មួយចំពោះការសិក្សារៀនសូត្ររបស់សិស្ស។ ការសិក្សានានាបានរកឃើញថា យន្តការគណនេយ្យភាពរបស់សាលារៀនក៏អាចកែលម្អលទ្ធផលសិក្សារៀនសូត្រ ជំនាញក្នុងការដោះស្រាយបញ្ហា កិច្ចសហការ ការប្រាស្រ័យទាក់ទង ភាពប៉ិនប្រសប់ និងការអត់ធ្មត់ដែរ (Turnipseed & Darling-Hammond, ២០១៥)។ ពួកគាត់បានអះអាងថា ជំនាញទាំងនេះពិតជាមានសារៈសំខាន់ខ្លាំងជាងពិន្ទុតេស្តដែលសិស្សសម្រេចបានទៅទៀត ដោយសារជំនាញទាំងនេះជួយអ្នកបញ្ចប់ការសិក្សាឲ្យរៀបចំខ្លួនសម្រាប់ឱកាសការងារដែលតម្រូវឲ្យមានជំនាញដែលផ្ទេរបាន និងដែលសិស្សមិនអាចរំពឹងទុកមុន បាននៅពេលជ្រើសរើសមុខវិជ្ជាជាក់លាក់នានាដើម្បីសិក្សា ឬការបណ្តុះបណ្តាលបច្ចេកទេស។

### *វិធីសាស្ត្រអន្តរជាតិចំពោះគណនេយ្យភាពរបស់សហគមន៍សម្រាប់សាលារៀន*

យុទ្ធសាស្ត្រផ្សេងៗគ្នាជាច្រើនដើម្បីបង្កើនគណនេយ្យភាពរបស់សាលារៀន ត្រូវបានគេអនុវត្តទាំងនៅក្នុងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍដោយមានទាំងទទួលជោគជ័យ និងបរាជ័យនៅក្នុងបរិបទខុសៗគ្នា។ ដើម្បីធានាបាននូវការប្រតិបត្តិល្អបំផុតនានា ប្រទេសដែលជាសមាជិក OECD ភាគច្រើនបានអនុវត្តនូវយន្តការដែលរួមបញ្ចូលគ្នាមួយដើម្បីធ្វើឲ្យសាលារៀនមានគណនេយ្យភាព។ យន្តការទាំងនេះត្រូវបានគេចងជាកម្រងគណនេយ្យភាពចំនួន៣ធំៗ ៖ គណនេយ្យភាពនៃស្នាដៃបំពេញការងារ គណនយ្យភាពផ្នែកបទបញ្ញា និងគណនេយ្យភាពផ្នែកទីផ្សារ (OECD ២០១១)។ ស្ថិតក្រោមគណនេយ្យភាពនេះ សាលារៀនតាមតំបន់ជនបទគឺជាកម្មវត្ថុចំពោះការធ្វើរបាយការណ៍ស្តីពីស្នាដៃបំពេញការងាររបស់ខ្លួន ជាពិសេសការសិក្សារៀនសូត្ររបស់សិស្សដើម្បីឲ្យអង្គភាពអភិបាលកិច្ច និងសាធារណៈជន អធិការកិច្ចខាងក្រៅ ការអនុវត្តស្វ័យវាយតម្លៃដែលបានរៀបចំផែនការ និងជាទៀងទាត់ ព្រមទាំងការប្រកួតប្រជែងដើម្បីទទួលបានមូលនិធិ។ ស្នាដៃបំពេញការងារពុំបានល្អនៅក្នុងប្រព័ន្ធទាំងនេះអាចបណ្តាលឲ្យមានការកាត់បន្ថយចំពោះថវិការបស់សាលារៀន។ គំរូរបស់ OEDC សង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការមានប្រព័ន្ធត្រួតពិនិត្យដែលបានបង្កើតឡើងយ៉ាងល្អិតល្អន់ និងសកម្មដើម្បីសម្របសម្រួលស្នាដៃបំពេញការងាររបស់សាលារៀននៅថ្នាក់មូលដ្ឋាន។

នៅទ្វីបអាស៊ី វិធីសាស្ត្រទូទៅមួយចំពោះគណនេយ្យភាពរបស់សាលារៀនគឺការអនុវត្តនូវការចងសាលារៀនជាកម្រង និងការចូលរួមរបស់សហគមន៍ក្នុងអភិបាលកិច្ចសាលារៀន បើទោះបីជាឈ្មោះដែលគេប្រើ និង

ការអនុវត្តជាក់ស្តែងអាចមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយក៏ដោយ (Wheeler et al., ១៩៩៤, ដូចដែលបានដកស្រង់នៅក្នុង Pellini, ២០០៧)។ នៅក្នុងប្រទេសថៃ កម្រងសាលារៀនដើរតួនាទីជាយន្តការមួយក្នុងការលើកកម្ពស់ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ និងធ្វើឲ្យសាលារៀនមានគណនេយ្យភាពចំពោះអភិបាលកិច្ចសាលារៀន។ ឥណ្ឌាបានណែនាំឲ្យបង្កើតសមាគមមាតាបិតាសិស្ស និងគ្រូបង្រៀន (PTA) ដើម្បីធ្វើការឲ្យបានស្អិតរមួតជាមួយគណៈគ្រប់គ្រងសាលា។ ហ្វីលីពីនបង្កើតប្រព័ន្ធគាំទ្រការសិក្សារៀនសូត្ររបស់ឪពុកម្តាយ (PLSS)។ ឥណ្ឌូនេស៊ីបង្កើតអង្គការមាតាបិតាសិស្ស (PO)។ ទោះជាយ៉ាងនេះក៏ដោយ ប្រទេសទាំងនេះមានបញ្ហាស្រដៀងគ្នា ដែលបញ្ហាភាគច្រើនបំផុតដែលគេកត់សំគាល់គឺការខ្វះការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។ ការវាយតម្លៃជាលក្ខណៈទ្រឹស្តីបានលើកឡើងថា អំណាចនៃការធ្វើសេចក្តីសម្រេចចិត្តនៅតែស្ថិតក្នុងដៃរបស់នាយកសាលាដដែល។ គំរូរបស់ប្រទេសឥណ្ឌូនេស៊ីត្រូវបានគេវិនិច្ឆ័យថាពុំបានទទួលជោគជ័យទេដោយសារគ្រូបង្រៀនមិនត្រូវបានគេដាក់បញ្ចូលទៅក្នុងយន្តការនានាដែលគេបង្កើតឡើង ដោយពឹងផ្អែកខ្លាំងពេកតែទៅលើសមាជិកសហគមន៍។ គំរូកម្រងសាលារៀនរបស់ប្រទេសនេប៉ាល់ក៏មិនត្រូវបានគេមើលឃើញថាមានដំណើរការល្អដែរ ដោយសារគំរូនៃការគ្រប់គ្រងសាលារៀននៅតែត្រូវបានគេរៀបចំរចនាសម្ព័ន្ធ ដែលមានលក្ខណៈតាមឋានានុក្រមដដែល។ សាលារៀននានាខកខានក្នុងការឲ្យសហគមន៍ចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តដែលជាហេតុបង្កឲ្យមានការបង្កើតឡើងនូវការចូលរួមក្លែងក្លាយ របស់សហគមន៍នៅក្នុងអភិបាលកិច្ចសាលារៀន។

នៅក្នុងប្រទេសកម្ពុជាកម្មវិធី កម្រងសាលារៀនត្រូវបានគេណែនាំនៅឆ្នាំ១៩៩២ ដោយមានគោលបំណងមួយក្នុងការលើកកម្ពស់ការចូលរួមរបស់សហគមន៍ ដើម្បីជួយសាលារៀនឲ្យបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយគណនេយ្យភាព (Pellini, ២០០៧)។ បន្ទាប់ពីនោះមក គណៈកម្មការទ្រទ្រង់សាលារៀន (SSCs) ត្រូវបានគេបង្កើតឡើងជាកម្លាំងអន្តរការីមួយ ដើម្បីភ្ជាប់ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍។ យន្តការទាំងពីរនេះមានបំណងផ្តល់នូវវេទិកានៃការគាំទ្រមួយសម្រាប់សហគមន៍នៅក្នុងការជួយសាលារៀនឲ្យបំពេញភារកិច្ចរបស់ខ្លួនទាំងប្រកបដោយប្រសិទ្ធិភាព និងគណនេយ្យភាព។ ប៉ុន្តែភស្តុតាងបង្ហាញថា យន្តការទាំងនេះមិនត្រូវបានគេកំណត់ថាទទួលជោគជ័យទេដោយសារការខ្វះខាតនូវធនធានមនុស្ស និងហិរញ្ញវត្ថុ (ឧទាហរណ៍ Shoraku, ២០០៨; Thida & Joy, ២០១២)។ ដើម្បីធ្វើឲ្យសាលារៀនមានគណនេយ្យភាពតាមរយៈការចូលរួមរបស់សហគមន៍ គឺជាការប្រឈមមុខដ៏ខ្លាំងក្លាមួយ។ ទោះជាយ៉ាងណាក៏ដោយ Shoraku (២០០៨) ផ្តល់អនុសាសន៍មួយទាក់ទងនឹងវិធីសាស្ត្ររួមចំពោះចំណុចនេះ ៖ ១) បណ្តុះបណ្តាលគ្រូបង្រៀន និងនាយកសាលានូវបច្ចេកទេសនៃភាពជាអ្នកដឹកនាំជាមូលដ្ឋាន និងជំនាញក្នុងការចងក្រងសហគមន៍ (ឧទាហរណ៍ ការប្រើប្រាស់ថវិកាសាលារៀន ការផ្តល់ហិរញ្ញវត្ថុ និងការចងក្រងសហគមន៍) ២) បណ្តុះបណ្តាលបុគ្គលិករដ្ឋាភិបាលថ្នាក់មូលដ្ឋានស្តីពីការត្រួតពិនិត្យ ការគ្រប់គ្រង និងការវាយតម្លៃប្រតិបត្តិការរបស់សាលារៀន នៅក្នុងករណីនេះគឺសំដៅទៅលើក្រុមការងារបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក ទី៣) បង្កើតនូវអង្គការស្វ័យភាពដែលមានមូលដ្ឋាននៅតាមសាលារៀនដាច់ដោយឡែកសម្រាប់ក្រុមដែលមានការចាប់អារម្មណ៍ផ្ទាល់ខ្លួន និងប្រជាជនធម្មតាផ្សេងៗទៀត (ឧទាហរណ៍ អង្គការឪពុកម្តាយ និងអង្គការដែលមានមូលដ្ឋាននៅសាលារៀន) ដើម្បីឲ្យមានលំហរដែលមានលក្ខណៈសង្គតភាពសម្រាប់ការពិភាក្សាដោយបើកចំហរអំពីការអប់រំកូនៗរបស់ពួកគាត់។ Thida និង Joy[1] (២០១២) បានសង្កត់ធ្ងន់ទៅលើលក្ខខ័ណ្ឌដំបូងចំពោះ

[1] ឯកសារមួយដែលបោះពុម្ពនៅមុនសន្និសិទ្ធិ អាស៊ីស្តីពីការអប់រំឆ្នាំ២០១២ Osaka, Japan

ជោគជ័យនៃការគ្រប់គ្រងដោយផ្អែកលើសាលារៀននៅក្នុងប្រទេសកម្ពុជាដែលរាប់បញ្ចូលទាំងការរៀបចំភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសម្រាប់បុគ្គលិករបស់សាលារៀន ជាពិសេសនាយកសាលា ព្រមទាំងវិធីសាស្ត្រនៃការធ្វើសេចក្តីសម្រេចចិត្តតាមបែបចូលរួមឲ្យបានច្រើនថែមទៀត នៅក្នុងការគ្រប់គ្រងសាលារៀន ជាពិសេសពីសំណាក់គ្រូបង្រៀន និង SSCs។ នៅក្នុងឆ្នាំ២០១៤ អង្គការ CARE បានអនុវត្តនូវគំរូមួយនៃការពង្រឹងគណៈ-កម្មការទ្រទ្រង់សាលារៀននៅភាគឥសាន្តរបស់ប្រទេសកម្ពុជា ដែលស្វែងរកដំណោះស្រាយកត្តាទាំងនេះក្នុងភាពជាដៃគូជាមួយក្រសួងអប់រំ យុវជន និងកីឡា។ គំរូនេះសង្កត់ធ្ងន់ទៅលើការបណ្តុះបណ្តាលក្រុមការងារបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក (DTMTs) និង SSCs ដើម្បីលើកកម្ពស់ការចូលរួម សមត្ថភាព និងការយល់ដឹងរបស់ពួកគាត់ទៅលើតួនាទី និងការទទួលខុសត្រូវរបស់គាត់។ ការវាយតម្លៃបង្ហាញថា វគ្គបណ្តុះ-បណ្តាល បានបង្ហាញនូវប្រសិទ្ធិភាព និងផលប្រយោជន៍ចំពោះការកើនឡើងនូវការចូលរួម សមត្ថភាព និងការយល់ដឹងរបស់ពួកគាត់ទៅលើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ទោះបីជាការពិតការសិក្សានេះត្រូវបានគេរៀបចំឡើងនៅតំបន់ដាច់ស្រយាលនៅក្នុងប្រទេសកម្ពុជាដែលធនធានមនុស្ស និងហិរញ្ញវត្ថុនៅមានកម្រិតក៏ដោយ។

ទ្វីបអាហ្វ្រិកមានគំរូស្រដៀងគ្នាដែរចំពោះគណនេយ្យភាពរបស់សាលារៀន តាមរយៈការចូលរួមរបស់សហគមន៍នៅក្នុងអភិបាលកិច្ចសាលារៀន។ ឧទាហរណ៍ Benin បានព្យាយាមសាកល្បងគំរូមួយដែលផ្ទេរការធ្វើសេចក្តីសម្រេចចិត្តពីថ្នាក់កណ្តាលទៅថ្នាក់មូលដ្ឋាន។ សាលារៀនមានសិទ្ធិគ្រប់គ្រងមូលនិធិនានា ដែលទទួលបានពីរដ្ឋាភិបាលកណ្តាល និងប្រើប្រាស់មូលនិធិទាំងនោះសម្រាប់គោលបំណងក្នុងការអប់រំ (ឧទាហរណ៍ ជួលគ្រូបង្រៀននៅតាមសហគមន៍)។ ជាងនេះទៅទៀត PTAs ត្រូវបានគេណែនាំដើម្បីឲ្យសហគមន៍ចូលរួមក្នុងប្រព័ន្ធនេះ។ ទោះជាយ៉ាងនេះក៏ដោយ លទ្ធផលដែលគេទទួលបានតាមរយៈការខិតខំប្រឹងប្រែងនេះមានលក្ខណៈចំរុះគ្នា។ គេបានរកឃើញថា ការចូលរួមរបស់សហគមន៍មានទាំងលក្ខណៈពិតប្រាកដ និងសិប្បនិម្មិត ដោយសារតែមានអ្នកដឹងនាំតាមមូលដ្ឋានតែពីរបីនាក់ប៉ុណ្ណោះដែលធ្វើសេចក្តីសម្រេចចិត្តចុងក្រោយ។ នៅក្នុងប្រទេស Malawi ការចូលរួមរបស់សហគមន៍ត្រូវបានគាំទ្រដោយគំនិតផ្តួចផ្តើមនៃការផ្តល់អំណាចដល់សហ-គមន៍ដែលតាមរយៈនោះសហគមន៍មានភាពជាម្ចាស់ចំនួន២០% នៃធនធានផ្សេងៗ នៅក្នុងគម្រោងដែលផ្តល់មូលនិធិដោយរដ្ឋាភិបាល។ យន្តការនេះបានទទួលជោគជ័យមួយចំនួនដែរ ប៉ុន្តែជោគជ័យនេះគឺទទួលបានជាក់លាក់តែចំពោះការសាងសង់សាលារៀនប៉ុណ្ណោះ (Rose, ២០០៣, ដូចដែលបានដកស្រង់នៅក្នុង Pellini, ២០០៧)។ ការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំផែនការនៅតែស្ថិតនៅក្រោមការណែនាំរបស់អ្នកដឹកនាំតាមមូលដ្ឋាន មន្ត្រីថ្នាក់កណ្តាល ឬអ្នកតាក់តែងគោលនយោបាយ។ នៅក្នុងប្រទេសហ្គាណា គណនេយ្យភាពរបស់សាលារៀនក៏ត្រូវបានគេផ្សព្វផ្សាយតាមរយៈដំណើរការវិមជ្ឈការ និងការចូលរួមរបស់សហគមន៍ដែរ។ ទំនាក់ទំនងសាលារៀន និងសហគមន៍ត្រូវបានគេបង្កើតឡើង ប៉ុន្តែគេបានអះអាងថាវាមិនទទួលបានជោគជ័យដូចដែលគេរំពឹងទុកទេ។ ក្រៅពីការខ្វះការចាប់អារម្មណ៍ពីសហគមន៍ដោយសារភាពក្រីក្រ សហគមន៍មានបទពិសោធន៍តិចតួចនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តតាមបែបវិមជ្ឈការនេះ បើតាមអ្វីដែលគេបានរាយការណ៍។ ដើម្បីលើកកម្ពស់ការចូលរួមរបស់សហគមន៍ (Chapman et al. ២០០២) ចង្អុលបង្ហាញថាសហគមន៍ត្រូវការការបណ្តុះបណ្តាលឲ្យបានគ្រប់គ្រាន់ ស្តីពីរបៀបចូលរួមឲ្យមានប្រសិទ្ធិភាពនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត (ដូចដែលបានដកស្រង់នៅក្នុង Pellini, ២០០៧)។ នៅក្នុងចំណុចនេះ គេចាំបាច់ត្រូវកសាងសមត្ថភាពរបស់សហគមន៍ ដើម្បីចូលរួមនៅក្នុងដំណើរការអភិបាលកិច្ចរបស់សាលារៀន ដើម្បីធ្វើឲ្យយន្តការជាផ្លូវការនេះបានទទួលជោគជ័យ។

## ៣. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឆ្លើយនឹងសំណួរសម្រាប់ការស្រាវជ្រាវដែលបានកំណត់ ការប្រមូលទិន្នន័យផ្នែកបរិមាណក្នុងចំនួនដ៏ច្រើន ព្រមទាំងទិន្នន័យបែបគុណភាពដែលមានលក្ខណៈស៊ីជម្រៅ និងលម្អិតត្រូវបានគេតម្រង់ទិស។ ហេតុដូច្នេះហើយ ការសិក្សានេះប្រើប្រាស់ទាំងវិធីសាស្ត្រនៃការស្រាវជ្រាវទាំងបែបបរិមាណ និងគុណភាព។ ការសិក្សានេះអនុវត្តនូវការរៀបចំការស្រាវជ្រាវតាមបែបសង្កេតមួយដើម្បីធ្វើឲ្យមានការយល់ដឹងមួយពីការអនុវត្តក្នុងពេលបច្ចុប្បន្ននេះស្ដីពីការចូលរួមរបស់សហគមន៍ និងយោបល់ជាសាធារណៈស្ដីពីស្នាដៃបំពេញការងាររបស់សាលារៀនតាមមូលដ្ឋាន។ ការរៀបចំនូវបាតុភូតវិទ្យា (phenomenological) នៅក្នុងការស្រាវជ្រាវបែបគុណភាពត្រូវបានគេប្រើប្រាស់ដើម្បីកំណត់ពីចំណុចបញ្ហា និងការប្រឈមមុខនានាក្នុងការលើកកម្ពស់គណនេយ្យភាពរបស់សាលារៀននៅថ្នាក់ក្រោមជាតិ។

***សំណាក***

គម្រោងនៃការស្រាវជ្រាវនេះត្រូវបានធ្វើឡើងនៅក្នុងខេត្តចំនួន៥ និងទីក្រុងមួយ ពោលគឺរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ ខេត្ត និងក្រុងដែលជាសំណាកនេះត្រូវបានគេជ្រើសរើសតាមមធ្យោបាយនៃការជ្រើសរើសសំណាកដែលមានគោលបំណងច្បាស់លាស់ ដោយសារការសិក្សានេះចង់រកឲ្យឃើញនូវភាពខុសគ្នានៅក្នុងចំណោមតំបន់ខុសៗគ្នា។ នៅក្នុងខេត្តនីមួយៗ ស្រុកចំនួន៣ (ស្រុកដែលជាតំបន់ទីក្រុងចំនួនមួយ ស្រុកនៅតាមតំបន់ជនបទប៉ុន្តែនៅជិតទីប្រជុំជនចំនួនមួយ និងស្រុកនៅតាមទីជនបទ ប៉ុន្តែនៅឆ្ងាយពីទីប្រជុំជនចំនួនមួយ) ត្រូវបានគេជ្រើសរើស។ សាលារៀនចំនួន១៨០ ត្រូវបានគេជ្រើសរើសជាសំណាកសម្រាប់ការសិក្សានេះ ដោយប្រើប្រាស់ការជ្រើសរើសសំណាកចោះៗ ជាលក្ខណៈស្រទាប់ក្នុងគោលបំណងពន្យល់ពីភាពខុសគ្នានៃចំនួនរបស់សាលារៀនដែលគេសង្កេតមើលនៅថ្នាក់បឋមសិក្សា និងធម្យមសិក្សា។ អត្រាផលធៀប ៥:១ ត្រូវបានគេប្រើប្រាស់ជាមូលដ្ឋានមួយសម្រាប់ការជ្រើសរើសសាលារៀនបឋមសិក្សា និងមធ្យមសិក្សានីមួយៗ នៅក្នុងការសិក្សានេះ ដោយឲ្យស្របគ្នាជាមួយនឹងសមមាត្រនៃសាលារៀនដូចនេះដែលបានសង្កេតនៅថ្នាក់ជាតិដោយយោងទៅតាមទិន្នន័យរបស់ MoEYS។ ដោយផ្អែកលើអត្រាផលធៀបនេះសាលារៀនបឋមសិក្សាចំនួន១៥ និងសាលារៀនមធ្យមសិក្សាបឋមភូមិចំនួន៣ ត្រូវបានគេជ្រើសរើសចោះៗពីខេត្តនីមួយៗ ដើម្បីកំណត់ពីភាពទូទៅនៃលទ្ធផលនៃការស្រាវជ្រាវនេះ។ ហេតុដូច្នេះហើយ នៅតាមស្រុកនីមួយៗសាលារៀនបឋមសិក្សាចំនួន៥ និងសាលារៀនធម្យមសិក្សាបឋមភូមិចំនួន១ ត្រូវបានគេជ្រើសរើសជាសាលារៀនសំណាកសម្រាប់ការស្រាវជ្រាវនេះ។ ការសិក្សានេះក៏រាប់បញ្ចូលអង្គការមិនមែនរដ្ឋាភិបាល (NGOs) ចំនួន១៥ដែរ ដែលបាននឹងកំពុងធ្វើការយ៉ាងទូលំទូលាយទៅលើចំណុចបញ្ហាស្ដីពីគណនេយ្យភាពរបស់សាលារៀន និងសង្គមនៅក្នុងខេត្តដែលបានជ្រើសរើស និងនៅទូទាំងប្រទេស។

ជាសរុប អ្នកចូលរួមក្នុងការស្រាវជ្រាវមានចំនួន៨១១នាក់ ដែលត្រូវបានគេជ្រើសរើសពីក្នុងខេត្តចំនួន ៥ និងរាជធានីភ្នំពេញ ព្រមទាំងសមាជិកបុគ្គលិករបស់ NGOs ចំនួន១៥នាក់ ត្រូវបានគេសម្ភាសន៍។ ជាដំបូងគេមានបំណងដាក់បញ្ចូលសមាជិក SSC ចំនួន5នាក់ ដោយរួមមាន ឪពុកម្ដាយ សមាជិកផ្នែកសាសនា សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ អ្នកតំណាងមកពីផ្នែកឯកជន និងគ្រូបង្រៀនមកពីសាលានីមួយៗនៅក្នុងការសម្ភាសន៍ដែលមានរៀបចំជារចនាសម្ព័ន្ធ ដើម្បីពិនិត្យមើលពីកម្រិតនៃការចូលរួមរបស់គាត់នៅក្នុងភារកិច្ច ផ្នែកគណនេយ្យភាពរបស់សាលារៀន និងដើម្បីស្វែងរកមើលការប្រឈមមុខនានាដែលទប់ស្កាត់ពួកគាត់ មិនឲ្យ

ចូលរួមឲ្យបានពេញលេញនៅក្នុងដំណើរការនៃការបំពេញការងាររបស់សាលារៀន។ ទោះជាយ៉ាងនេះក្តី តាមតថភាពជាក់ស្តែង ចំនួនសមាជិក SSC ដែលគេបានជួបសម្ភាសន៍មានចំនួនតិចជាងចំនួនដែលគេរំពឹងទុក។ ដើម្បីកំណត់ពីអ្នកចូលរួមនៅក្នុងការស្រាវជ្រាវនេះ នាយកសាលាត្រូវបានគេស្នើសុំឲ្យកំណត់ ពីសមាជិក SSC នៅក្នុងសាលារៀនរបស់ពួកគាត់។ ទោះជាយ៉ាងនេះក្តី នាយកសាលាមួយចំនួនមិនអាចកំណត់ពីសមាជិក SSC ណាមួយទេ ហើយនាយកសាលាមួយចំនួនកំណត់បានតែសមាជិកមួយ ឬពីរនាក់ប៉ុណ្ណោះ ដែលធ្វើឲ្យគេពិបាកក្នុងការសម្រេចបាននូវចំនួនសំណាកដែលគេចង់បាន។ នៅតាមសាលារៀនមួយចំនួនតូច ចំនួនសមាជិក SSC គ្រប់គ្រាន់ត្រូវបានគេរកឃើញ ប៉ុន្តែគេពុំមានលទ្ធភាពសម្ភាសន៍សមាជិក SSC ចំនួន៥នាក់ ដូចដែលបានកំណត់ទេ ដោយសារកម្មវិធី និងការមានពេលទំនេររបស់ពួកគាត់។ តាមផែនការ សមាជិក SSC ចំនួន៤៤០នាក់នឹងត្រូវបានគេដាក់បញ្ចូល ប៉ុន្តែជាក់ស្តែងគឺបានតែ៣៦៦នាក់ ប៉ុណ្ណោះ (ដូចដែលបានបង្ហាញនៅក្នុងតារាងទី២)។ ទោះជាយ៉ាងនេះក្តី ចំនួនឪពុកម្តាយដែលមិនមែនជាសមាជិក SSC ដែលត្រូវបានគេសម្ភាសន៍បានកើនឡើងលើសពីចំនួនដែលគេបានកំណត់ គឺពីចំនួន២២០នាក់ រហូតដល់២៦៥នាក់។ ចំនួននាយកសាលាមានចំនួនស្មើគ្នានឹងចំនួនដែលគេកំណត់។

**តារាងទី ២ ៖** *ចំនួនសំណាកនៅតាមខេត្តនីមួយៗទៅតាមស្ថានភាពរបស់សាលារៀន*

| ខេត្ត | ចំនួនសាលារៀន | ចំនួននាយកសាលា | ចំនួនសិស្ស | ចំនួនសមាជិក SSC | ចំនួនសមាជិកមិនមែន SSC | សរុបរង |
|---|---|---|---|---|---|---|
| ភ្នំពេញ | ១៨ | ១៨ | ១២ | ៦៨ | ៤០ | ១៣៨ |
| កំពង់ចាម | ១៨ | ១៨ | ១២ | ៦៥ | ៣៧ | ១៣២ |
| សៀមរាប | ១៨ | ១៨ | ១២ | ៦៤ | ៤៧ | ១៤១ |
| កំពត | ១៨ | ១៨ | ១២ | ៦៣ | ៤៥ | ១៣៨ |
| ព្រៃវែង | ១៨ | ១៨ | ១២ | ៦០ | ៤៦ | ១៣៦ |
| រតនៈគីរី | ១៨ | ១៨ | ១២ | ៤៦ | ៥០ | ១២៦ |
| សរុប | ១០៨ | ១០៨ | ៧២ | ៣៦៦ | ២៦៥ | ៨១១ |

*ចំណាំ៖ នៅក្នុងខេត្តរតនៈគីរី អ្នកបកប្រែតាមសហគមន៍ម្នាក់ដែលចេះភាសាជនជាតិដើមភាគតិច និងភាសាខ្មែរយ៉ាងស្ទាត់ជំនាញត្រូវបានគេស្នើឲ្យជួយក្នុងការបកប្រែ និងការពិភាក្សាតាមក្រុម។*

ដើម្បីកំណត់ពីសំណាកនៃការស្រាវជ្រាវ អ្នកស្រាវជ្រាវជាបឋមកំណត់ពីសាលាគោលដៅ។ នៅពេលដែល សាលារៀនត្រូវបានគេជ្រើសរើសរួចហើយ ក្រុមការងារមួយត្រូវបានគេបញ្ជូនឲ្យទៅកាន់សាលារៀនដើម្បីកំណត់ពីចំនួនសមាជិក SSC នៅតាមសាលារៀននីមួយៗ ស្ថានភាពរបស់សមាជិកនោះនៅក្នុងសាលារៀន និងការងារបច្ចុប្បន្នរបស់ពួកគាត់ដោយផ្អែកលើព័ត៌មានដែលទទួលបានពីនាយកសាលា។ ដោយសារការសិក្សានេះព្យាយាមក្តាប់ឲ្យបាននូវស្ថានភាពគណនេយ្យភាពផ្នែកសង្គម និងសាលារៀននៅក្នុងពេលតែមួយ អ្នកចូលរួមដែលមានប្រវត្តិខុសៗគ្នាត្រូវបានគេពេញចិត្ត។ ហេតុដូច្នេះហើយ ការជ្រើសរើសសមាជិក SSC ដើម្បីសម្ភាសន៍គឺមានលក្ខណៈសម្រាំង និងមានចេតនាជាក់លាក់ដើម្បីធានាថា កាសម្ភាសន៍នានាត្រូវបានគេធ្វើឡើងជាមួយសមាជិក SSC ដែលមានប្រវត្តិខុសៗគ្នា។ សមាជិកសហគមន៍ដែលមានប្រវត្តិការងារខុសៗគ្នាដែលមិនមែនជាផ្នែកមួយនៃសមាជិកភាពរបស់ SSC ត្រូវបានកំណត់យកដោយនាយកសាលា។ គោលការណ៍ដូចគ្នានៃ

ការជ្រើសរើសអ្នកទាំងឡាយណាដែលមានប្រវត្តិខុសៗគ្នា ក៏ត្រូវបានគេអនុវត្តដែរនៅពេលជ្រើសរើសសមាជិកដែលមិនមែនជា SSC ដែលលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសដំបូង និងសំខាន់ជាងគេបំផុតរបស់ពួកគាត់គឺថា ពួកគាត់ត្រូវមានកូនៗរបស់គាត់រៀននៅសាលានោះក្នុងពេលធ្វើការសម្ភាសន៍។ ការជ្រើសរើសតំណាងរបស់ NGO ត្រូវធ្វើឡើងដោយផ្អែកលើកម្រិតនៃភាពសកម្មរបស់ខ្លួននៅក្នុងការធ្វើការតាមសាលារៀន ជាពិសេសនៅក្នុងវិស័យគណនេយ្យភាពរបស់សាលារៀន។ ជាចុងក្រោយ នៅតាមតំបន់នីមួយៗ សិស្សចំនួន៦នាក់ដែលកំពុងសិក្សានៅសាលាបឋមសិក្សា និង៦នាក់ នៅសាលាមធ្យមសិក្សាបឋមភូមិបានចូលរួមនៅក្នុងការពិភាក្សាជាក្រុមចំនួន២ក្រុមខុសៗគ្នា (សូមមើលចំណុចបន្ថែម "ច" សម្រាប់សំណួរដែលបានរៀបចំសម្រាប់ការពិភាក្សាជាក្រុម)។ ការជ្រើសរើសសិស្សគឺផ្អែកលើមូលដ្ឋាននៃការស្ម័គ្រចិត្ត។ ជាសរុប សិស្សចំនួន៧២នាក់បានចូលរួមនៅក្នុងការសិក្សានេះ។ មុនពេលក្រុមស្រាវជ្រាវប្រមូលព័ត៌មានពីអ្នកចូលរួម ក្រុមអ្នកស្រាវជ្រាវបានអានសេចក្តីយល់ព្រមឲ្យអ្នកចូលរួមម្នាក់ៗស្តាប់ ហើយបានស្នើសុំឲ្យពួកគាត់ចុះហត្ថលេខានៅលើសេចក្តីយល់ព្រមនោះ។ ចំពោះសិស្សដែលមានវ័យក្មេង សេចក្តីយល់ព្រមនេះត្រូវបានគេបញ្ជូនទៅឲ្យឪពុកម្តាយរបស់កុមារទាំងនោះ ហើយសេចក្តីយល់ព្រមនេះ ត្រូវបានចុះហត្ថលេខាដោយឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេ។ អ្នកចូលរួមត្រូវបានគេធានាចំពោះអនាមិកភាព។

***ការប្រើប្រាស់ឧបករណ៍***

មានវិធីសាស្ត្រនៃការប្រមូលព័ត៌មានចំនួនពីរប្រភេទខុសគ្នា ដែលគេអនុវត្តនៅក្នុងការសិក្សានេះ។ ដើម្បីទទួលបានទិន្នន័យបែបបរិមាណសម្រាប់ការវិភាគ ដើម្បីយល់ពីការអនុវត្តជាក់ស្តែងក្នុងពេលបច្ចុប្បន្នរបស់ SSC នៅក្នុងការលើកស្ទួយគណនេយ្យភាពរបស់សាលារៀន ការសម្ភាសន៍ ដែលមានរៀបចំជារចនាសម្ព័ន្ធ ត្រូវបានគេធ្វើឡើងជាមួយនាយកសាលា សមាជិករបស់ SSC និងសមាជិកមិនមែន SSC។ កម្រងសំណួរខុសៗគ្នាចំនួន៣ ត្រូវបានគេរៀបចំឡើង ដើម្បីឲ្យស្របជាមួយនឹងក្រុមរបស់ភាគីដែលពាក់ព័ន្ធនីមួយៗ (មានភ្ជាប់ជូនជាចំណុចបន្ថែម ក ខ និងគ)។ ពិធីសារនានារាប់បញ្ចូលទាំងភាពប្រែប្រួល ដែលមិនទាន់លេចជារូបរាងដើម្បីពិនិត្យមើលពីកម្រិតនៃការចូលរួមនៅក្នុងការបំពេញការងារនៅក្នុងសាលារៀន ដែលជាធាតុចូល និងសំណួរបើក-បិទ (Open-end) ដើម្បីមើលឲ្យឃើញនូវការប្រឈមមុខក្នុងពេលបច្ចុប្បន្ន និងដើម្បីសួរបញ្ជាក់បន្ថែមទៅលើសំណូមពរនានា ដែលអាចកើតមានក្នុងគោលបំណងកែលម្អការអនុវត្តជាក់ស្តែង និងគោលនយោបាយនានាផ្នែកគណនេយ្យភាពរបស់សាលារៀននៅក្នុងប្រទេសកម្ពុជា។ ការសម្ភាសន៍ជាលក្ខណៈបុគ្គលម្នាក់ៗ ត្រូវបានធ្វើឡើងជាមួយភាគីដែលពាក់ព័ន្ធនីមួយៗ ដើម្បីទទួលបាននូវទស្សនទានដែលមិនលំអៀងពីពួកគាត់។ បញ្ជីសំណួរសម្រាប់ការសម្ភាសន៍ត្រូវបានគេរៀបចំឡើងដោយប្រើប្រាស់នូវសេចក្តីណែនាំស្តីពី SSC ដែល MoEYS បានបង្កើតឡើងនៅក្នុងឆ្នាំ២០១២ ដែលមាន៨ផ្នែក នៃតួនាទី និងការទទួលខុសត្រូវរបស់SSC៖ (១) កសាង និងអនុវត្តផែនការអភិវឌ្ឍសាលារៀន (២) ប្រមូល និងជម្រុញកុមារចូលរៀន (៣) ការតាមដានការសិក្សារៀនសូត្ររបស់សិស្ស (៤) ស្វែងរកចំណូល និងការគ្រប់គ្រងថវិកា (៥) ចូលរួមក្នុងការសាងសង់ ជួសជុល និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន (៦) ការចែករំលែកបទពិសោធន៍ និងបំណិនជីវិត (៧) ការទប់ស្កាត់ភាពមិនប្រក្រតីក្នុង និងក្រៅសាលា និង (៨) ពង្រឹង និងពង្រីកសមត្ថភាពគណៈកម្មការ (សូមមើលតារាងទី២)។ ហេតុផលនានានៅពីក្រោយការដាក់បញ្ចូលសេចក្តីណែនាំនេះនៅក្នុងបញ្ជីសំណួរគឺថា សេចក្តីណែនាំធ្វើឲ្យអ្នកស្រាវជ្រាវអាចពិនិត្យមើលតើសកម្មភាពណាខ្លះដែលសហគមន៍បានចូលរួមច្រើនបំផុត និងផ្នែកណាខ្លះដែលគេចាំបាច់ត្រូវកែលម្អដោយប្រៀបធៀបជាមួយគោលនយោបាយជាផ្លូវ

ការដែលជាចំណុចដៅដែលគេកំណត់ទុក។ សេចក្តីណែនាំត្រូវបានគេបង្កើតឡើង ដើម្បីលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃដំណើរការរបស់សាលារៀន។ សេចក្តីណែនាំនេះកំណត់យ៉ាងច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវសម្រាប់សហគមន៍ក្នុងការជួយត្រួតពិនិត្យ និងវាយតម្លៃស្នាដៃបំពេញការងាររបស់សាលារៀន។ ចំណុចបន្ទាប់នៃបញ្ជីសំណួរសម្រាប់ការសម្ភាសន៍ត្រូវបានគេរៀបចំឡើង ដើម្បីវាស់វែងពីការយល់ឃើញចំពោះស្នាដៃបំពេញការងាររបស់សាលារៀនតាមរយៈទស្សនៈទានរបស់អ្នកចូលរួម។ នៅក្នុងករណីរបស់នាយកសាលា សំណួរច្រើនថែមទៀតត្រូវបានគេសួរនៅក្នុងផ្នែកទាំងនេះដោយសន្មត់ថា ពួកគាត់មានចំណេះដឹងកាន់តែច្រើនឡើងពីវិធានការនៃការបំពេញការងារ។

ចំពោះទិន្នន័យផ្នែកគុណភាព ការសិក្សានេះប្រើប្រាស់ការពិភាក្សាជាក្រុម និងការសម្ភាសន៍ស៊ីជម្រៅ។ ការពិភាក្សាជាក្រុមត្រូវបានគេរៀបចំជាមួយសិស្សសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ គោលបំណងសំខាន់នៃការពិភាក្សា គឺដើម្បីស្វែងយល់នូវការយល់ឃើញរបស់សិស្សពីកម្រិតនៃការបំពេញការងាររបស់សាលារៀនរបស់ខ្លួន និងដើម្បីពិនិត្យមើលថា តើសហគមន៍បានចូលរួមនៅក្នុងសកម្មភាពរបស់សាលារៀនយ៉ាងដូចម្តេចដោយផ្អែកលើបទពិសោធន៍ និងការយល់ដឹងរបស់ពួកគេ។ ការពិភាក្សាជាក្រុមត្រូវបានគេរៀបចំផែនការសម្រាប់ធ្វើជាមួយសមាជិកបុគ្គលិករបស់ NGO ដើម្បីស្វែងយល់ឲ្យបានកាន់តែប្រសើរពីគណនេយ្យភាពរបស់សាលារៀន និងសង្គមនៅថ្នាក់មូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយអ្នកស្រាវជ្រាវ មិនមានលទ្ធភាពប្រមូលបុគ្គលិក NGO ទាំងនោះឲ្យមកជុំគ្នាសម្រាប់ការពិភាក្សាបានទេ។ ហេតុដូច្នេះហើយ អ្នកស្រាវជ្រាវបានរៀបចំការសម្ភាសន៍ដាច់ដោយឡែកជាលក្ខណៈបុគ្គលជាមួយសមាជិកបុគ្គលិក NGO ដែលបានកំណត់ជំនួសវិញ។ ការសម្ភាសន៍នានាមានរយៈពេលប្រហែលមួយម៉ោង។ អ្នកស្រាវជ្រាវបានសម្ភាសន៍អ្នកតំណាងចំនួន១០ នាក់ ហើយបានរកឃើញថា ក្រុមអ្នកស្រាវជ្រាវសម្រេចបានការយល់ដឹងយ៉ាងពេញលេញ ដោយសារសមាជិកបុគ្គលិក NGO ម្នាក់ៗបានលើកឡើងនូវកង្វល់ និងការប្រឈមមុខដូចៗគ្នាចំពោះការលើកកម្ពស់ការងាររបស់SSCs និងគណនេយ្យភាពរបស់សាលារៀននៅថ្នាក់មូលដ្ឋាន។

### *ការវិភាគទិន្នន័យ*

គម្រោងនៃការស្រាវជ្រាវនេះ អនុវត្តទាំងវិធីសាស្ត្របែបបរិមាណ និងគុណភាពដើម្បីពិនិត្យមើលការអនុវត្តជាក់ស្តែងក្នុងពេលបច្ចុប្បន្នពីការចូលរួមរបស់សហគមន៍នៅក្នុងការអនុវត្តការងាររបស់សាលារៀន ដើម្បីកំណត់ពីការប្រឈមមុខនានា ដែលទប់ស្កាត់ពួកគាត់មិនឲ្យចូលរួមឲ្យបានពេញលេញ នៅក្នុងការបំពេញការងាររបស់សាលារៀន និងដើម្បីផ្តល់អនុសាសន៍នានាដែលស្របនឹងបរិបទនៃការអប់រំបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា។ ទិន្នន័យដែលបានមកពីភាគីដែលពាក់ព័ន្ធនីមួយៗ ជាដំបូងត្រូវបានគេវិភាគដាច់ដោយឡែកពីគ្នា និងត្រូវបានគេធ្វើសំយោគជាបន្តបន្ទាប់ ដើម្បីទាញយកនូវរូបភាពកាន់តែទូលំទូលាយឡើងពីរបៀបដែលគណនេយ្យ-ភាពរបស់សាលារៀន និងសហគមន៍ដំណើរការនៅក្នុងប្រទេសកម្ពុជា។ ក្នុងការធ្វើដូច្នេះ ជាដំបូងការវិភាគទៅលើការអនុវត្តជាក់ស្តែងក្នុងពេលបច្ចុប្បន្នស្តីពីការចូលរួមរបស់សហគមន៍នៅក្នុងការលើកកម្ពស់គណនេយ្យភាពរបស់សាលារៀនត្រូវបានគេធ្វើឡើងតាមរយៈការប្រើប្រាស់ទិន្នន័យដែលបានពីនាយកសាលា សមាជិក SSCs និងសមាជិកសហគមន៍ដែលមិនមែនជា SSCs។ ការវិភាគពីពិន្ទុតាមដោយពិនិត្យមើលពីចំនួនដង និងមធ្យមភាគត្រូវបានគេប្រើប្រាស់ដើម្បីក្តាប់ឲ្យបាននូវអ្វីដែលគេចាត់ទុកថា កំពុងដំណើរការយ៉ាងល្អ និងទិដ្ឋភាពអ្វីនៃសកម្មភាពរបស់ SSC ដែលគេចាំបាច់ត្រូវធ្វើការកែលម្អ។ នៅក្នុងដំណាក់កាលនេះ ការវិភាគទៅលើការបំពេញ

ការងាររបស់សាលារៀន ព្រមទាំងការពេញចិត្ត និងការរំពឹងទុករបស់សាធារណៈជន និងសហគមន៍ចំពោះសាលារៀនក៏ត្រូវបានគេធ្វើឡើងផងដែរ។

ខ្លឹមសារសំខាន់ៗដែលបានមកពីសំណួរបើក ត្រូវបានគេថតទុកក្នុងពេលធ្វើសម្ភាសន៍។ អ្នកស្រាវជ្រាវបានអានដោយប្រុងប្រយ័ត្ននូវខ្លឹមសារនៃការសម្ភាសន៍ទាំងអស់ និងចងក្រងការសម្ភាសន៍ទាំងនេះជាក្រុមទៅតាមខ្លឹមសារសំខាន់ៗមួយចំនួន។ ការវិភាគពីខ្លឹមសារត្រូវបានគេប្រើប្រាស់ ដើម្បីវិភាគទិន្នន័យដែលបានមកពីការសម្ភាសន៍ស៊ីជម្រៅជាមួយបុគ្គលិក NGO និងការពិភាក្សាជាក្រុមជាមួយសិស្ស។ អ្នកស្រាវជ្រាវបានស្តាប់ការសម្ភាសន៍ និងការពិភាក្សាជាក្រុមដែលបានថតទុកចំនួន២ដង បានវិភាគពីខ្លឹមសារនៃការសម្ភាសន៍នីមួយៗ និងបានរៀបចំខ្លឹមសារសំខាន់ៗដោយផ្អែកលើការឆ្លើយតបរបស់អ្នកចូលរួម។

***ដែនកំណត់នៃការសិក្សា***

ទិន្នន័យមានលក្ខណៈសំបូរបែបនៅក្នុងការសិក្សានេះ។ ថ្វីបើដូចនេះក្តី មានដែនកំណត់មួយចំនួនដែលគេ គួរតែយកចិត្តទុកដាក់ដើម្បីឲ្យយល់ពីគម្រោងនៃការស្រាវជ្រាវនេះ។ ឧទាហរណ៍ នៅពេលដែលអ្នកចូលរួមដែលមានប្រវត្តិខុសៗគ្នាដូចជា នាយកសាលា SSCs និងសមាជិកសហគមន៍ដែលមិនមែន SSCs ត្រូវបានគេដាក់បញ្ចូលនៅក្នុងការសិក្សានេះដើម្បីធានាបាននូវភាពច្បាស់លាស់ និងភាពសំបូរបែបនៃការឆ្លើយតបទាក់ទងនឹងការចូលរួមរបស់សហគមន៍ និងស្នាដៃបំពេញការងាររបស់សាលារៀន។ ជាសំខាន់ ការសិក្សានេះគឺជាការសិក្សាដែលមានមូលដ្ឋានលើការយល់ឃើញ។ អ្នកចូលរួមម្នាក់ៗ ត្រូវបានគេស្នើសុំឲ្យវាយតម្លៃពីវិសាលភាពដែល SSCs បំពេញតួនាទី និងការទទួលខុសត្រូវរបស់ពួកគាត់ ដែលជាយន្តការមួយសម្រាប់ឆ្លុះបញ្ចាំងទៅលើកម្រិតនៃការចូលរួមរបស់សហគមន៍នៅក្នុងសកម្មភាពដែលទាក់ទងនឹងសាលារៀន។ វិធីសាស្ត្រដែលផ្អែកលើការយល់ឃើញនេះ ក៏ត្រូវបានគេអនុវត្តដែរចំពោះការប្រមូលទិន្នន័យស្តីពីស្នាដៃបំពេញការងាររបស់សាលារៀន។ វិសាលភាពដែលសាលារៀនមានគណនេយ្យភាពចំពោះដំណើរការរបស់ខ្លួនសម្រាប់សិស្ស និងសម្រាប់សហគមន៍ត្រូវបានគេមើលឃើញជាសំខាន់តាមរយៈការយល់ឃើញរបស់នាយកសាលា SSCs និងអ្នកមិនមែន SSCs ដែលបានចូលរួមនៅក្នុងការសិក្សានេះ។ ជាងនេះទៅទៀត គណនេយ្យភាពរបស់សាលារៀននៅក្នុងការសិក្សានេះត្រូវបានគេមើលឃើញតាមរយៈការពិនិត្យមើលពីការគ្រប់គ្រងសាលារៀន និងសូចនាករស្តីពីការបំពេញ ការងាររបស់សាលារៀនដែលអាចវាស់វែងបានដែលនៅមានកម្រិតច្រើនជាជាងតាមរយៈលទ្ធផលនៃការរៀនសូត្រនៅក្នុងផ្នែកខ្លះ ដោយសារពុំមានវិធានការដែលអាចប្រៀបធៀបគ្នាបាននៅថ្នាក់ជាតិ។ នៅក្នុងន័យនេះ គណនេយ្យភាពរបស់សាលារៀននៅក្នុងការសិក្សានេះ សំដៅទៅលើគណនេយ្យភាពនៃដំណើរការនៃការអប់រំជាជាងគណនេយ្យភាពនៃលទ្ធផលនៃការអប់រំ ហើយដែលនឹងត្រូវទទួលរងផលប៉ះពាល់ពីអ្វីដែលអ្នកឆ្លើយតបមានអារម្មណ៍ថា គឺជាកម្រិតប្រសើរបំផុតនៃការចូលរួមរបស់សហគមន៍ និងការបំពេញការងាររបស់សាលារៀន។ ជាងនេះទៅទៀត ការអះអាងទៅលើការប្រកាន់ខ្ជាប់តាមគោលនយោបាយ ដូចជាការបោះពុម្ពនូវផែនការអភិវឌ្ឍសាលារៀន ឬការបោះឆ្នោតជ្រើសសមាជិក SSC ត្រូវបានគេរាយការណ៍ថាមិនមានការបញ្ជាក់ច្បាស់លាស់ទេ។ ចំណុចនេះ វាមិនស្ថិតនៅក្នុងការរៀបចំសម្រាប់ការសិក្សានេះ ដើម្បីបញ្ជាក់ពីការអះអាងទាំងនេះជាមួយនឹងភស្តុតាងបន្ទាប់បន្សំទេ បើគិតពីទំហំនៃសំណាក។ ដោយសារការសិក្សានេះ បានប្រើប្រាស់នូវសេចក្តីណែនាំស្តីពីគោលនយោបាយថ្នាក់ជាតិសម្រាប់ដំណើរការរបស់គណៈកម្មការទ្រទ្រង់សាលារៀន ដូច្នេះវាក៏ជាករណីដែលការខ្វះការយល់ដឹងមួយចំពោះពាក្យនានាដែលគេប្រើ ឬការរំពឹងទុកផ្សេងៗ ដែល

សេចក្តីណែនាំនោះមានបាននាំទៅរកការមិនឆ្លើយតប។ តាមពិតការរំពឹងទុកជាលក្ខណៈបុគ្គលជាច្រើនរបស់ SSCs ដែលបានពិភាក្សាជាមួយអ្នកចូលរួមដែលមិនមែនជាសមាជិក SSC មិនត្រូវបានគេយល់ដោយងាយស្រួលនោះទេ ហេតុដូច្នេះហើយវាបានធ្វើឲ្យអ្នកចូលរួមពុំមានលទ្ធភាពក្នុងការផ្តល់យោបល់ទេ។ ការនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការរកឃើញនៅកន្លែងដែលជាប់ទាក់ទងគ្នា ដោយការឆ្លើយតបនានាពីសំណាក់សមាជិកសហគមន៍ដែលមិនមែនជា SSC ត្រូវបានគេដកចេញពីការវិភាគមួយចំនួន ដោយសារពុំមានចំនួនសមាជិកគ្រប់គ្រាន់ដែលមានអារម្មណ៍ថា មានលទ្ធភាពផ្តល់យោបល់បាន។

## ៤. លទ្ធផលរកឃើញ និងការវិភាគ

ការសិក្សាស្រាវជ្រាវនេះ ពិនិត្យមើលពីគុណភាពរបស់សាលារៀននៅក្នុងប្រទេសកម្ពុជា តាមរយៈការចូលរួមរបស់សហគមន៍នៅក្នុងការបំពេញការងាររបស់សាលារៀននៅកម្រិតសាលារៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ ដើម្បីសម្រេចបាននូវទិសដៅដ៏សំខាន់នេះ ក្រុមការងារស្រាវជ្រាវបានរៀបចំសំណួរសម្រាប់ការស្រាវជ្រាវចំនួន៤ប្រភេទ ដែលពិនិត្យមើលទៅលើ (១) ស្ថានភាពនៃការចូលរួមរបស់សហគមន៍ និងការបំពេញការងាររបស់សាលារៀន (២) ការប្រឈមមុខនានាចំពោះការចូលរួមរបស់សហគមន៍នៅក្នុងការបំពេញការងាររបស់សាលារៀន (៣) ការយល់ឃើញខុសៗគ្នារវាងសមាជិក SSC និងសមាជិកសហគមន៍ដែលមិនមែនជា SSC ចំពោះការអនុវត្តជាក់ស្តែង និងការប្រឈមមុខនានាទាក់ទងនឹងការចូលរួមរបស់សហគមន៍ នៅក្នុងសកម្មភាពរបស់សាលារៀន និង (៤) ការប្រតិបត្តិល្អចំពោះការចូលរួមរបស់សហគមន៍ ដើម្បីលើកកម្ពស់គុណភាពរបស់សាលារៀន និងសង្គម។ ហេតុដូច្នេះហើយ ការរកឃើញនានារបស់ការស្រាវជ្រាវនេះត្រូវបានគេរៀបចំរចនាសម្ព័ន្ធដើម្បីឆ្លើយតបទៅតាមសំណួរទាំង៤នេះ។ ការរកឃើញនានា ក៏ពិភាក្សាពីលក្ខណៈ និងសមាសភាពរបស់គណៈកម្មការទ្រទ្រង់សាលារៀនដែរ ហើយសំណាកបន្ទាប់បន្សំផ្សេងៗទៀត ត្រូវបានវិភាគជាធាតុចូលបន្ថែមមួយ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់យើងពីការអនុវត្តជាក់ស្តែងផ្នែកគុណភាពរបស់សាលារៀនតាមទីតាំងភូមិសាស្ត្រ កម្រិតសាលារៀន និងតំបន់របស់សាលារៀន។

### *លក្ខណៈ និងសមាសភាពរបស់គណៈកម្មការទ្រទ្រង់សាលារៀន*

ដោយផ្អែកទៅលើទិន្នន័យតាមមូលដ្ឋាននៃការសិក្សានេះ លទ្ធផលបានបង្ហាញនូវលក្ខណៈផ្សេងៗជាច្រើន និងសមាសភាពមួយរបស់ SSCs ដែលបង្ហាញនូវការប្រែប្រួលមួយចំនួនពីអ្វីដែលបានបញ្ជាក់នៅក្នុងសេចក្តីណែនាំរបស់ SSC នៅថ្នាក់ជាតិ។

សេចក្តីណែនាំសម្រាប់សាលាបឋមសិក្សា ដែលបានចេញផ្សាយនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២ បញ្ជាក់ពីសមាជិកភាពរបស់ SSC ដែលមានរហូតដល់៦នាក់ ឬលើសពីនេះដោយផ្អែកទៅលើទំហំរបស់សាលារៀន។

សមាសភាពជាទូទៅ និងភារកិច្ចរបស់បុគ្គលម្នាក់ៗរបស់ SSC មានដូចខាងក្រោម ៖

១. ប្រធានកិត្តិយស ៖ តំណាងរបស់អាជ្ញាធរដែនដី (មេឃុំ/ចៅសង្កាត់ ក្រុមប្រឹក្សាឃុំ/សង្កាត់) ឬចៅអធិការវត្ត ឬសប្បុរសជន (ចំនួន ១ នាក់)។

២. ទីប្រឹក្សា ៖ នាយកសាលា មន្ត្រីអប់រំដែលចូលនិវត្តន៍ ចាស់ព្រឹទ្ធាចារ្យ តំណាងសហគមន៍ អាជ្ញាធរមូលដ្ឋាន (ចំនួន១-៣នាក់)។

៣. ប្រធាន ៖ មន្ត្រីអប់រំដែលចូលនិវត្តន៍ គណៈកម្មការវត្ត ឧបាសក សប្បុរសជន តំណាងសហគមន៍ តំណាងរបស់ឪពុកម្តាយសិស្សដែលជាមនុស្សមានប្រជាប្រិយភាព។

៤. អនុប្រធាន ៖ មន្ត្រីអប់រំដែលចូលនិវត្តន៍ គណៈកម្មការវត្ត ឧបាសក សប្បុរសជន តំណាងសហគមន៍ តំណាងរបស់ឪពុកម្តាយសិស្សដែលជាមនុស្សមានប្រជាប្រិយភាព (ចំនួន១-៣នាក់)

៥. សមាជិក ៖ មន្ត្រីអប់រំដែលចូលនិវត្តន៍ គណៈកម្មាការវត្ត ឧបាសក សប្បុរសជន តំណាងសហគមន៍ តំណាងរបស់ឪពុកម្តាយសិស្សដែលជាមនុស្សមានប្រជាប្រិយភាព (ចំនួន២-៤នាក់)

សេចក្តីណែនាំរបស់ SSC បញ្ជាក់ថា ប្រធាន អនុប្រធាន និងសមាជិករបស់ SSC ត្រូវបានគេជ្រើសរើសតាមរយៈការបោះឆ្នោត ដោយតំណែងប្រធានត្រូវប្រគល់ជូនអ្នកដែលមានសំឡេងឆ្នោតច្រើនបំផុត អនុ-ប្រធានសម្រាប់អ្នកដែលមានសំឡេងច្រើនបំផុតទី២ និងសមាជិកផ្សេងៗទៀតដែលនៅសល់នឹងត្រូវបានគេជ្រើសរើសជាសមាជិក។

សេចក្តីណែនាំលើកឡើងថា សមាជិកដែលមានស្រាប់របស់គណៈកម្មការទ្រទ្រង់ថ្នាក់រៀន អ្នកដែលមាន ប្រជាប្រិយភាពក្នុងសហគមន៍ សប្បុរសជន និងសមាជិក SSC (ដែលមានស្រាប់) ជាចាស់ព្រឹទ្ធាចារ្យគួរត្រូវបានគេ ផ្តល់អទិភាពឲ្យនៅក្នុងការបោះឆ្នោតជ្រើសរើសទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ សេចក្តីណែនាំពុំបានពន្យល់ពីរបៀបដែលសមាជិក SSC ដែលមានលទ្ធភាពត្រូវបានគេបញ្ជូនឈ្មោះមកដូចម្តេចទេ តែបើតាមការសន្និដ្ឋានអ្នកណាម្នាក់នៅក្នុងសាលារៀន ឬ SSC ដែលមានស្រាប់ដែលមាននៅក្នុងបញ្ជីរបស់សមាជិក គឺជាអ្នកដែលមានលទ្ធ ភាព។

នាយកសាលាទទួលខុសត្រូវក្នុងការបង្កើតគណៈកម្មការសម្រាប់ការបោះឆ្នោតជ្រើសរើសគណៈកម្មការទ្រទ្រង់សាលារៀនដែលរាប់បញ្ចូលទាំងគ្រូបង្រៀន និងសមាជិក SSC បច្ចុប្បន្ន។ សេចក្តីណែនាំចង្អុលបង្ហាញថា អ្នកដែលមានសិទ្ធិក្នុងការបោះឆ្នោតជ្រើសរើស SSC ថ្មីគឺសមាជិក SSC បច្ចុប្បន្ន សមាជិក SSC ពីមុន និងម្ចាស់ជំនួយឯកជននៅក្នុងសហគមន៍។

ការជ្រើសរើសសមាជិករបស់ SSC ធ្វើឡើងដោយការបោះឆ្នោតមួយខែមុនឆ្នាំសិក្សាចាប់ផ្តើមនៅតាមសាលារៀននីមួយៗដោយមានអណត្តិសម្រាប់រយៈពេល១ឆ្នាំ។ ហេតុដូច្នេះហើយការបោះឆ្នោតជ្រើសរើសនេះត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ។

អ្នកឆ្លើយតបដែលជាសមាជិករបស់ SSC បានរាយការណ៍ថា ជាមធ្យមគណៈកម្មការទ្រទ្រង់សាលារៀននីមួយៗមានសមាជិកចំនួន៨នាក់ ដែលស្មើរតែស្មើគ្នានឹងសេចក្តីណែនាំស្តីពី SSC (ពោលគឺសមាជិក៦នាក់ ឬច្រើនជាងនេះដោយផ្អែកទៅលើទំហំរបស់សាលារៀន)។ ទោះជាយ៉ាងណាក៏ដោយ សមាជិកភាគច្រើនមានចំណេះដឹងតិចតួចអំពីសមាសភាពរបស់ SSC ដែលពួកគាត់បានចូលរួម។ ចំណុចនេះអាចឆ្លុះបញ្ចាំងនូវការប្រឈមមុខមួយចំនួនថា តើក្រុមនេះដំណើរការបានល្អដែរឬទេ និងថាតើក្រុមនេះជាក្រុមដែលត្រឹមត្រូវមួយនៅក្នុងការគាំទ្រសាលារៀនរបស់ខ្លួនដែរឬអត់។ សមាជិក SSC ភាគច្រើនរាយការណ៍ពីចំនួនខុសៗគ្នានៃសមាជិកដែលពួកគាត់បានគិតថាពួកគាត់បានធ្វើការជាមួយ (ដូចដែលបានបង្ហាញសមាជិកមានពី១-២០នាក់ត្រូវបានគេរាយការណ៍) ដែលជាចំណុចបញ្ហាមួយបង្ហាញពីការខ្វះខាតធ្ងន់ធ្ងរនូវការចែករំលែកព័ត៌មានដែលច្បាស់លាស់ស្តីពីផ្នែកនានារបស់សាលារៀន ព្រមទាំងបញ្ជាក់ពីការខ្វះការប្រាស្រ័យទាក់ទងជាប់ជាប្រចាំ ឬការប្រជុំជាទៀងទាត់ក្នុងចំណោម SSCs។ អ្វីដែលកាន់តែភ្ញាក់ផ្អើលថែមទៀតគឺថា នាយកសាលាមួយចំនួន ជាពិសេសនៅរាជធានីភ្នំពេញគឺពុំបានដឹងតែម្តងពីការមានក្រុម SSC និង / ឬ ចំនួនពិតប្រាកដនៃសមាជិករបស់ SSC របស់ខ្លួនផ្ទាល់។

សេចក្ដីណែនាំស្ដីពី SSC ដាក់បញ្ចូលនូវការលើកទឹកចិត្តស្ត្រីឲ្យគេបោះឆ្នោតគាំទ្រធ្វើជាសមាជិករបស់ SSC។ នៅក្នុងការសិក្សានេះ ភាគច្រើននៃអ្នកចូលរួមរបស់ SSC គឺជាស្ត្រីដែលមានប្រមាណជា៧៤% នៃសំណាករបស់ SSC។ គេមិនអាចជួប SSC ជាបុរសបានទេ ឬទំនងជាថាសមភាគីរបស់ខ្លួនដែលជាស្ត្រីមានចំនួនលើសច្រើនពេក។

អ្នកចូលរួមដែលជាសមាជិករបស់ SSC ប្រមាណជា៦០% នៅក្នុងការសិក្សានេះគឺជាមនុស្សជាន់ខ្ពស់ដែលមានអាយុលើសពី៥០ឆ្នាំ ហើយស្ទើរតែពីរភាគបីនៃពួកគាត់បានរាយការណ៍ថាមានកម្រិតវប្បធម៌ទាបជាងកម្រិតវិទ្យាល័យ។ ការចូលរួមពីសំណាក់ប្រជាជនដែលមានវ័យក្មេង និងអ្នកទាំងឡាយណាដែលមានសញ្ញាប័ត្រសាកលវិទ្យាល័យនៅក្នុង SSCs នៅមានកម្រិតទាបបើយោងទៅលើសំណាកដែលបានសម្ភាសន៍។ ចំណុចនេះប្រហែលមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេបើពិចារណាទៅតាមសមាសភាពដែលបានកំណត់របស់ SSCs ដែលភាគច្រើនជាមន្ត្រីអប់រំចូលនិវត្តន៍ គណៈកម្មការវត្ត តាជី យាយជី តំណាងឪពុកម្ដាយ និងតំណាងសហគមន៍ដែលទំនងជាអ្នកដែលមានវ័យចំណាស់។ មនុស្សទាំងនេះតំណាងឲ្យសហគមន៍ដើម្បីឲ្យគេអាចលើកយកបញ្ហានានាទៅដាក់ក្នុងរបៀបវារៈរបស់សាលារៀន និងធ្វើការជាមួយសាលារៀនដើម្បីកែលម្អទំនាក់ទំនង និងការអភិវឌ្ឍរបស់សាលារៀន និងសហគមន៍។

នៅក្នុងសេចក្ដីណែនាំរបស់ SSC សមាជិកទាំងអស់ត្រូវជ្រើសរើសដោយផ្អែកលើការបោះឆ្នោតដែលត្រូវធ្វើឡើងនៅមុនពេលឆ្នាំសិក្សាថ្មីចាប់ផ្ដើម។ ទោះជាយ៉ាងនេះក្ដី ទិន្នន័យបានបង្ហាញនូវការខុសប្លែកគ្នាមួយ។ ស្ទើរតែពាក់កណ្ដាលនៃសមាជិក SSC បានរាយការណ៍ថា សមាជិកត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត ចំណែកឯ៤២%ទៀត បានអះអាងថា នាយកសាលាបានចាត់តាំងពួកគាត់ដោយពុំមានការបោះឆ្នោតទេ។ សមាមាត្រក្នុងចំនួនតូចរបស់សមាជិកបានលើកឡើងថា សមាជិក SSC បានស្ម័គ្រចិត្តធ្វើជាសមាជិក។

នៅពេលដែលគេសួរនាំអំពីភាពញឹកញាប់នៃការជ្រើសរើសសមាជិករបស់ SSC ការយល់ឃើញមានភាពខុសគ្នា ដោយ៣០% រាយការណ៍ថា ការជ្រើសរើសធ្វើឡើងជារៀងរាល់ឆ្នាំ ហើយ៣៦% អះអាងថា ការជ្រើសរើសធ្វើឡើងនៅពេលណាដែលសមាជិកចាស់បានចាកចេញពី SSC។ អ្នកដែលនៅសល់ផ្សេងៗទៀតបាននិយាយថា ការជ្រើសរើសសមាជិក SSC ត្រូវបានគេធ្វើឡើងរៀងរាល់២ ឬ៣ឆ្នាំម្ដង ឬមិនបានធ្វើឡើងតែម្ដង។ ទស្សនៈដែលមានភាពខុសគ្នាទាំងនេះបង្ហាញពីការអនុវត្តជាក់ស្ដែង ដែលភាពផ្ទុយគ្នានៃរបៀបដែលសមាជិករបស់ SSC ត្រូវបានគេជ្រើសរើសដោយប្រៀបធៀបទៅនឹងអ្វីដែលបានចែងនៅក្នុងសេចក្ដីណែនាំរបស់ SSC។

បើទោះបីជាមានតម្រូវការសម្រាប់ការបោះឆ្នោត និងការបោះឆ្នោតឡើងវិញសម្រាប់សមាជិក SSC ក៏ដោយ ក៏អ្នកចូលរួមដែលជា SSC ភាគច្រើនបានរាយការណ៍ថា សាលារៀនកម្រផ្លាស់ប្ដូរ ឬមិនដែលបានផ្លាស់ប្ដូរសមាសភាពសមាជិក SSC ទេសម្រាប់រយៈពេល៥ឆ្នាំកន្លងមកនេះ ដោយមានអ្នកចូលរួមតែ១៧% ប៉ុណ្ណោះបាននិយាយថា មានការផ្លាស់ប្ដូរមួយចំនួនចំពោះសមាជិករបស់ SSC។ លទ្ធផលនេះ ប្រហែលជាបង្ហាញទាំងការខ្វះការចាប់អារម្មណ៍ពីសំណាក់សហគមន៍ទូទៅ ឬចំណោទចំពោះការប្ដេជ្ញាចិត្តរបស់សាលារៀនក្នុងការធ្វើឲ្យមានការចាប់អារម្មណ៍ឡើងវិញក្នុងចំណោមសមាជិក SSC និងក្នុងការធ្វើឲ្យមានការចូលរួមពីសមាសភាពខុសៗគ្នាច្រើនថែមទៀតរបស់សមាជិក SSC ពីសហគមន៍ទូទៅ។ ជាថ្មីម្ដងទៀត ការជ្រើសរើសឡើងវិញដោយអកម្មនូវសមាសភាពរបស់ SSC គឺជាសញ្ញាមួយប្រកបដោយសក្ដានុពលភាពនៃការឲ្យតម្លៃទាបទៅលើតួនាទី

របស់ក្រុមនេះ ព្រមទាំងលើកឡើងនូវកង្វល់មួយដែលថា សាលារៀនប្រហែលជាពុំមានលទ្ធភាពប្រើប្រាស់ SSC ឲ្យបានល្អបំផុតនៅក្នុងការកែលម្អការបំពេញការងាររបស់សាលារៀនទេ។

នៅពេលគេសួរអំពីការធ្វើសេចក្ដីសម្រេចចិត្ត សមាជិក SSC ជាទូទៅបានរាយការណ៍ថា ប្រព័ន្ធដែលផ្អែកលើការបោះឆ្នោតគឺជាការអនុវត្តជាក់ស្ដែងទូទៅមួយ។ ទោះជាយ៉ាងនេះក្ដី អ្នកឆ្លើយតបដែលជា SSC ចំនួន ២៥% បានចង្អុលទៅរកប្រធានរបស់ SSC ដែលធ្វើការសម្រេចចិត្តជាចុងក្រោយ។ ដោយស្របជាមួយនឹងភស្តុតាងជាអន្តរជាតិ លទ្ធផលនេះហាក់ដូចជាបង្ហាញថា នៅក្នុងសមាមាត្រដ៏ច្រើនរបស់សាលារៀន ការសម្រេចចិត្តជាចុងក្រោយគឺស្ថិតនៅលើបុគ្គលតែពីរបីនាក់ប៉ុណ្ណោះ។

### *ការចូលរួមជាទូទៅរបស់សហគមន៍នៅក្នុងការគ្រប់គ្រងសាលារៀន*

នៅក្នុងប្រទេសកម្ពុជា ការលើកកម្ពស់ការចូលរួមរបស់សហគមន៍នៅក្នុងសកម្មភាពសាលារៀនគឺជាចំណុចសំខាន់នៃការយកចិត្តទុកដាក់របស់អ្នកតាក់តែងគោលនយោបាយ និងនាយកសាលាជាយូរមកហើយក្នុងគោលបំណងកែលម្អការបំពេញការងារ និងគណនេយ្យភាពរបស់សាលារៀន។ ការខិតខំប្រឹងប្រែងជាច្រើនត្រូវបានគេធ្វើឡើងក្នុងរយៈពេលប៉ុន្មានទសវត្សកន្លងមកនេះ តាមរយៈការពង្រឹងតួនាទី និងដំណើរការរបស់គណៈកម្មការទ្រទ្រង់សាលារៀន (SSC)។ គណៈកម្មការនេះត្រូវបានគេបង្កើតឡើងជាបណ្ដាញមួយសម្រាប់ការវិនិយោគដែលកាន់តែទូលំទូលាយឡើងពីសំណាក់សហគមន៍នៅក្នុងការយល់ដឹង និងការចែករំលែកទៅដល់អ្វីដែលកំពុងកើតមានឡើងនៅសាលារៀន ចាប់ពីការរៀបចំផែនការរហូតដល់ការអនុវត្ត ដល់ការវាយតម្លៃ និងដល់ការធ្វើរបាយការណ៍។ ការសិក្សានេះបំពេញនូវគម្លាតមួយនៅក្នុងការស្រាវជ្រាវដែលផ្ដោតលើការយកចិត្តទុកដាក់ថែមទៀតទៅលើដំណើរការរបស់ SSCs។ ប្រភពទិន្នន័យទាំង៣ ដែលបានមកពីនាយកសាលា សមាជិក SSC និងសមាជិកសហគមន៍ដែលមិនមែនជា SSC បង្ហាញថា ការចូលរួមរបស់សហគមន៍នៅក្នុងសកម្មភាពរបស់សាលារៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅក្នុងប្រទេសកម្ពុជាជាទូទៅ នៅមានកម្រិតទាបមែនទែននៅឡើយ។ គណៈកម្មការទ្រទ្រង់សាលារៀនដែលគេរំពឹងទុកថា នឹងដើរតួនាទីដ៏សំខាន់មួយនៅក្នុងការលើកកម្ពស់ការចូលរួមរបស់សហគមន៍ មិនត្រូវបានគេមើលឃើញថាកំពុងដំណើរការនៅក្នុងកម្រិតមួយដែលគេចង់បាននៅឡើយទេ។ លទ្ធផលនានាបង្ហាញនូវការខ្វះខាតដ៏សំខាន់មួយពីកិច្ចសហប្រតិបត្តិការ និងភាពជិតស្និទ្ធរវាងសាលារៀន និងសហគមន៍នៅក្នុងការលើកកម្ពស់ការបំពេញការងាររបស់សាលារៀន។ ដូចដែលគេអាចមើលឃើញនៅក្នុងតួលេខទី១ នាយកសាលា សមាជិក SSC និងសមាជិកមិនមែន SSC បានរាយការណ៍ថា សាលារៀនមានទំនោរទៅរកការដំណើរការដោយឯករាជ្យដោយមានការចូលរួមតិចតួចពីសហគមន៍របស់ខ្លួន។ ទោះបីជាមានសូចនាករមួយចំនួននៃការកើនឡើងនូវការចូលរួមពីសំណាក់ SSCs នៅក្នុងសកម្មភាពសំខាន់ៗមួយចំនួនរបស់សាលារៀនក៏ដោយ បើប្រៀបធៀបជាមួយនឹងការសិក្សាកន្លងមក ក៏ការចូលរួមរបស់ពួកគាត់នៅតែត្រូវបានគេពិពណ៌នាជាទូទៅថា នៅមាន "កម្រិតទាប"ដដែល។

ទោះបីមានលទ្ធផលទាំងនេះក្ដី ភស្តុតាងសំខាន់ៗត្រូវបានគេចងក្រងជាឯកសារទាក់ទងនឹងទម្រង់នៃសកម្មភាពនានារបស់សាលារៀនដែលសមាជិករបស់SSCយកចិត្តទុកដាក់។ តួលេខទី១បង្ហាញថា សកម្មភាពមួយចំនួនរបស់សាលារៀនគឺទំនងណាស់ថាត្រូវបានគេយកចិត្តទុកដាក់ នេះបើតាមទស្សនៈរបស់អ្នកឆ្លើយតប ចំណែកឯសកម្មភាពមួយចំនួនទៀតត្រូវបានគេយកចិត្តទុកដាក់តិចតួច។ បើទោះបីជាកម្រិតនៃការចូលរួមរបស់សមាជិក SSC នៅមិនទាន់ដល់កម្រិតដែលអាចទទួលយកបានក៏ដោយ ក៏តាមសេចក្ដីរាយការណ៍ SSCs

បានចូលរួមកាន់តែច្រើនឡើងនៅក្នុងសកម្មភាពនានាដូចជា "ការរៀបចំផែនការអភិវឌ្ឍសាលារៀន" និង "ការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន" ជាងអ្វីដែលគេបានរកឃើញកន្លងមក។ ភស្តុតាងនេះបង្ហាញពីការចាប់អារម្មណ៍ដែលកំពុងកើនឡើងមួយពីសំណាក់សហគមន៍នៅក្នុងការរៀបចំផែនការ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន។ ប៉ុន្តែនៅក្នុងពេលជាមួយគ្នានេះដែរ ភស្តុតាងបានឆ្លុះបញ្ចាំងពីកិច្ចសហប្រតិបត្តិការដែលកាន់តែមានលក្ខណៈវិជ្ជមានមួយរវាងសាលារៀន និងសហគមន៍នៅក្នុងសកម្មភាពផ្សេងៗទៀតដែលទាក់ទងនឹងសាលារៀន។ ការសិក្សានេះ បានរកឃើញថា ភាគច្រើននៃសមាជិក SSC បានចូលរួមតិចតួចនៅក្នុងសកម្មភាពនានារបស់សាលារៀនដូចជា "ការពង្រឹងការចុះឈ្មោះចូលរៀន" "ការត្រួតពិនិត្យការរៀនសូត្ររបស់សិស្ស" "ការប្រមូល និងការគ្រប់គ្រងមូលនិធិ" ព្រមទាំង "ការទប់ស្កាត់ភាពមិនប្រក្រតីនានា"។ បើតាមសេចក្តីរាយការណ៍ មានសមាមាត្ររបស់សមាជិក SSC មួយចំនួនតូចប៉ុណ្ណោះដែលបានចូលរួមយ៉ាងសកម្មនៅក្នុងការពង្រឹងការចុះឈ្មោះចូលរៀន ការត្រួតពិនិត្យលទ្ធផលនៃការសិក្សារបស់សិស្ស ព្រមទាំងការប្រមូល និងការគ្រប់គ្រងមូលនិធិ។ អ្វីដែលកាន់តែអាក្រក់នោះគឺការខ្វះការចូលរួមរបស់ពួកគាត់នៅក្នុង "ការចែករំលែកបទពិសោធន៍ និងបំណិនជីវិត" និង "ការកសាងសមត្ថភាពនៅតាមសាលារៀន"។ បើតាមសេចក្តីរាយការណ៍សមាជិក SSC ស្ទើរតែទាំងអស់ពុំបានចូលរួមនៅក្នុងសកម្មភាពទាំង២នេះទេ។ បើពិចារណាជារួម ទាំងនាយកសាលា ទាំងសមាជិក SSC និងសមាជិកមិនមែន SSC មានទស្សនៈស្រដៀងគ្នាមែនទែនទៅលើកម្រិត និងលក្ខណៈនៃការចូលរួមរបស់សហគមន៍នៅក្នុងការបំពេញការងាររបស់សាលារៀនក្នុងចំណោមតំបន់ទាំង៦នៅក្នុងការសិក្សានេះ។ ដោយសារសមាជិកមិនមែន SSC ពុំមានភាពជិតស្និទ្ធជាមួយសាលារៀនដូចនាយកសាលា និងសមភាគី SSC របស់ខ្លួន ជាទូទៅពួកគាត់យល់ឃើញថាមានការចូលរួមកាន់តែច្រើនសម្រាប់សកម្មភាពរបស់ SSC ជាងសមាជិករបស់ SSC ខ្លួនឯងផ្ទាល់។ ទោះជាយ៉ាងនេះក្តី គេគួរកត់សម្គាល់ថាជាងពាក់កណ្តាលនៃសមាជិកមិនមែន SSC បានរាយការណ៍ពីការពុំមានចំណេះដឹងអំពីសកម្មភាព និងការចូលរួមរបស់ SSC នៅក្នុងការគ្រប់គ្រង និងដំណើរការរបស់សាលារៀន ហេតុដូច្នេះហើយ ពួកគាត់ពុំមានលទ្ធភាពផ្តល់នូវទស្សនៈមួយស្តីពីសកម្មភាពជាក់លាក់បានទេ។ ហេតុដូច្នេះហើយ ការសិក្សានេះបន្ថែមនូវភស្តុតាងដ៏សំខាន់ថា ទោះបីជានាយកសាលា សមាជិក SSC និងសមាជិកមិនមែន SSC ទំនងជាមានទស្សនៈដូចគ្នាស្តីពីកម្រិត និងលក្ខណៈនៃការចូលរួមរបស់សហគមន៍នៅក្នុងការបំពេញការងាររបស់សាលារៀនក៏ដោយ ក៏ការអនុវត្តជាក់ ស្តែងនូវគណនេយ្យភាពរបស់សាលារៀននៅមិនទាន់បានយល់ជ្រួតជ្រាបពីសហគមន៍ទូទៅទេ ជាពិសេសក្នុងករណីរបស់អ្នកដែលមិនមែនជា SSC។




| | ការរៀបចំផែនការអភិវឌ្ឍសាលា | អនុវត្តការចុះឈ្មោះចូលរៀនរបស់សិស្ស | តាមដានការសិក្សារបស់សិស្សានុសិស្ស | រៃអង្គាស និងគ្រប់គ្រងថវិកាសាលា | ថែរក្សា ជួសជុល និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលា | ការផ្លាស់ប្តូរបទពិសោធន៍ និងបំនិនជីវិត | ទប់ស្កាត់ភាពមិនប្រក្រតីក្នុងសាលា | ការកសាងសមត្ថភាព |
|---|---|---|---|---|---|---|---|---|
| នាយកសាលា | ១.៣៧ | ១.២៦ | ១.២៧ | ១.២៦ | ១.៣១ | ០.២៦ | ១.១៤ | ០.៧ |
| គណៈកម្មការទ្រទ្រង់សាលា | ១.៣ | ១.២៥ | ១.២៥ | ១.១១ | ១.២៣ | ០.២៧ | ១.០៨ | ០.៦៧ |
| សហគមន៍ | ១.៨ | ១.២៩ | ១.៣៥ | ១.២ | ១.២៨ | ០.៤៤ | ១.៣៣ | ០.៧៣ |

តួលេខទី១ ៖ *ការចូលរួមរបស់SSCនៅក្នុងសកម្មភាពនានារបស់សាលារៀន*

*សំគាល់ ៖ ការចូលរួមរបស់ SSC ត្រូវបានគេវាស់ដោយផ្អែកលើកម្រិត Likert មួយដែលមាន៣ពិន្ទុ ដោយពិន្ទុ ០ មានន័យថាពុំមានការចូលរួម  ពិន្ទុ ១ មានន័យថាចូលរួមតិចតួច និងពិន្ទុ ២ មានន័យថាចូលរួមច្រើន។*

ការរកឃើញតាមរយៈការសម្ភាសន៍ដែលបានរៀបចំជារចនាសម្ព័ន្ធគឺមានសង្គតភាពជាមួយនឹងលទ្ធផលនៃការពិភាក្សាជាក្រុមចំនួន១២ក្រុម ជាមួយសិស្ស និងការសម្ភាសន៍ជាមួយតំណាងរបស់ NGO។ អ្នកចូលរួមដែលជាសិស្សសាលាចំនួនជាង៥០% ពុំមានគំនិតអ្វីទេទាក់ទងនឹងអ្នកដែលចូលរួមនៅក្នុងសកម្មភាព និងដំណើរការរបស់សាលារៀន ឬពីតួនាទីរបស់ SSCs។ អ្នកចូលរួមដែលជាសិស្សមួយចំនួនបានដឹងថា មានគណៈប្រតិភូ ឬសមាជិកសហគមន៍មួយចំនួនបានមកសាលារៀនរបស់ខ្លួន ប៉ុន្តែជាទូទៅពួកគេមិនអាចកំណត់បានទេថាតើពួកគាត់ជាអ្នកណា ឬតើតួនាទីរបស់ពួកគាត់មានអ្វីខ្លះ។ ពួកគេប្រហែលជា៤០% ស្គាល់ក្រុមខ្លះក្នុងចំណោមក្រុមនានាដែលម្តងម្កាលមកធ្វើការជាមួយសាលារៀន។ អ្នកទាំងនោះរួមមានបុគ្គលិក របស់ NGO ឪពុកម្តាយ សមាជិកគណៈកម្មការវត្ត អាជ្ញាធរ ដែនដី (ប្រធានភូមិ ក្រុមប្រឹក្សាឃុំ នគរបាល) និងមន្ទីរអប់រំខេត្ត ព្រមទាំងបុគ្គិលរបស់ MoEYS។ តាមធម្មតា សមាជិកក្រុមទាំងនេះមកក្នុងកាលៈទេសៈខុសៗគ្នា។ ឪពុកម្តាយមកសាលារៀននៅពេលដែលការសិក្សារបស់កូនៗមានបញ្ហា ឬនៅពេលដែលពួកគាត់ចង់ដឹងពីការរីកចំរើននៃការសិក្សារបស់កូនៗគាត់ពីគ្រូបង្រៀន ឬសាលារៀន។ ពេលខ្លះគេបានរាយការណ៍ថា ឪពុកម្តាយពេញចិត្តនៅក្នុងការពិភាក្សាតាមទូរស័ព្ទជាជាងការមកសាលារៀន។ បុគ្គលិករបស់ NGO មកសាលារៀនដើម្បីពិនិត្យមើលស្ថានភាពនៃការរៀនសូត្ររបស់សិស្ស ឬដើម្បីពិនិត្យ មើលការសិក្សារៀនសូត្ររបស់សិស្សដែលទទួលអាហារូបករណ៍របស់ខ្លួន។ ពួកគេមានអារម្មណ៍ថា ក្រុមប្រឹក្សាសាសនាតាមមូលដ្ឋាន សហគមន៍ និងអាជ្ញាធរដែនដីមកទស្សនៈកិច្ចសាលារៀនតែនៅពេលដែលសាលារៀនត្រូវការពួកគាត់ ដើម្បីប្រមូលលុយសម្រាប់ផែនការអភិវឌ្ឍសាលារៀន ដូចជាហេដ្ឋារចនាសម្ព័ន្ធរូបវន្តប៉ុណ្ណោះ។ បុគ្គលិកមកពី POE និង MoEYS ត្រូវបានគេយល់ថាមកទស្សនៈកិច្ចសាលារៀនសម្រាប់គោលបំណងអធិការកិច្ចសាលារៀន។ ផ្ទុយទៅវិញ នគរបាលមកសាលារៀននៅពេលដែលមានការវាយតប់គ្នា ឬចំណុចបញ្ហាណាមួយទាក់ទងនឹងសន្តិសុខប៉ុណ្ណោះ។ ពេលវេលាតែ

មួយគត់ដែលសមាជិកក្រុមទាំងនេះ ភាគច្រើនមកសាលារៀនទាំងអស់គ្នាគឺនៅថ្ងៃដែលមានការណែនាំនៅសាលារៀន ពិធីផ្តល់រង្វាន់ដល់សិស្សពូកែ ការប្រជុំប្រចាំឆ្នាំរបស់សាលារៀន។

តាមរយៈការសម្ភាសន៍ជាមួយតំណាង NGO ចំណុចបញ្ហាស្រដៀងគ្នានេះមែនទែនត្រូវបានគេរាយការណ៍។ អ្នកឆ្លើយតបចំនួន១៤នាក់ ក្នុងចំណោម១៥នាក់ បានបញ្ជាក់ថា សហគមន៍បានចូលរួមតែនៅក្នុងសកម្មភាពរៃអង្គាសមូលនិធិសម្រាប់សាងសង់ ឬថែទាំបន្ទប់រៀនថ្មី ខ្លោងទ្វារ ឬរបង ទិញឧបករណ៍ថ្មី ឬសម្ភារៈការិយាល័យសម្រាប់សាលារៀន និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនប៉ុណ្ណោះ។ នៅក្នុងសាលារៀនមួយចំនួនដែល NGO របស់ខ្លួនធ្វើការ ពួកគាត់ក៏បានផ្សព្វផ្សាយពីយុទ្ធនាការចុះឈ្មោះចូលរៀនតាមរយៈការចុះទៅតាមផ្ទះ ដែលកុមារគ្រប់អាយុចូលរៀនរស់នៅ និងស្នើសុំឲ្យឪពុកម្តាយចុះឈ្មោះកូនៗរបស់ពួកគាត់នៅសាលារៀន។ ទោះជាយ៉ាងនេះក្តី ពួកគាត់ពុំយល់ឃើញថា សហគមន៍បានចូលរួមនៅក្នុងភារកិច្ចសំខាន់ៗជាច្រើនរបស់សាលារៀនទេ ដូចជាការរៀបចំផែនការអភិវឌ្ឍសាលារៀន ការត្រួតពិនិត្យមើលថវិការបស់សាលារៀន ការត្រួតពិនិត្យដំណើរការនៃការបង្រៀន និងការរៀន ការរៀបចំការប្រជុំជាទៀងទាត់ជាមួយសាលារៀន ការកំណត់បញ្ហារបស់សាលារៀន និងការផ្តល់អនុសាសន៍លើដំណោះស្រាយ ព្រមទាំងការផ្តល់ព័ត៌មានត្រឡប់ទៅឲ្យសាលារៀនសម្រាប់ការកែលម្អបន្ថែមទៀត។

### *ការចូលរួមរបស់សហគមន៍នៅតាមតំបន់*

ការវិភាគទៅលើលទ្ធផលនានានៃការប្រមូលទិន្នន័យដោយផ្អែកទៅលើតំបន់ផ្តល់នូវភស្តុតាងមួយចំនួនដែលការចូលរួមរបស់សហគមន៍គឺទំនងជាយល់ឃើញ និងឬកំពុងដំណើរការខុសៗគ្នានៅតាមតំបន់ភូមិសាស្ត្រផ្សេងៗគ្នា។ ការធ្វើតេស្តពីសារៈសំខាន់ (significance) ដោយប្រើប្រាស់ *t*-test មួយទៅលើកម្រងទិន្នន័យរបស់នាយកសាលា និង SSC[2] បង្ហាញថា មានភាពខុសគ្នាជាដុំកំភួនមួយផ្នែកស្ថិតិចំពោះកម្រិតនៃការចូលរួមរបស់សហគមន៍ដែលគេយល់ឃើញនៅក្នុងការគ្រប់គ្រង និងដំណើរការរបស់សាលារៀនរវាងសាលារៀននៅភ្នំពេញ និងសាលារៀននៅក្រៅទីក្រុង ($p < 0.05$)។ ជារួម ការរកឃើញនានាបង្ហាញថា ការចូលរួមរបស់សហគមន៍ដែលគេយល់ឃើញមានកម្រិតទាបជាងខ្លាំងនៅក្នុងតំបន់ទីក្រុង។ ទិន្នន័យនៃការឆ្លើយតបរបស់នាយកសាលា និងសមាជិក SSC គាំទ្រដូចគ្នាទៅលើភស្តុតាងដែលថា សមាជិក SSC នៅតាមបណ្តាខេត្តផ្សេងៗទៀត មានកម្រិតនៃការចូលរួមខ្ពស់ជាងនៅក្នុង "ការប្រមូល និងការគ្រប់គ្រងមូលនិធិ" និង "ការកសាងសមត្ថភាព"។ ទិន្នន័យនៃការឆ្លើយតបរបស់សមាជិក SSC បានបង្ហាញថែមទៀតថា SSCs នៅតាមសាលារៀនតាមជនបទ ហាក់ដូចជាមានកម្រិតនៃការចូលរួមខ្ពស់ជាងនៅក្នុង "ការត្រួតពិនិត្យការរៀនសូត្ររបស់សិស្ស" "ការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន" និង "ការចែករំលែកបទពិសោធន៍ និងបំណិនជីវិត" បើប្រៀបធៀបជាមួយនឹងសមាភាគីរបស់ខ្លួននៅតាមទីក្រុង។ ទោះជាយ៉ាងនេះក្តី ពុំមានភាពខុសគ្នាច្រើនទេត្រូវបានគេរកឃើញទាក់ទងនឹងកម្រិតនៃការចូលរួមរបស់ហគមន៍នៅក្នុងការគ្រប់គ្រង និងសកម្មភាពរបស់សាលារៀនទេ ($p > 0.05$) ដែលរាប់បញ្ចូលទាំង "ការរៀបចំផែនការអភិវឌ្ឍសាលារៀន" "ការពង្រឹងការចុះ

---

[2] ទិន្នន័យរបស់អ្នកមិនមែន SSC មិនត្រូវបានគេប្រើប្រាស់សម្រាប់ការវិភាគនេះទេ ដោយសារការខ្វះចំណេះដឹងរបស់អ្នកដែលមិនមែន SSC អំពីការចូលរួមរបស់ SSC នៅក្នុងការគ្រប់គ្រង និងសកម្មភាពរបស់សាលារៀនដែលបណ្តាលឲ្យមានការខ្វះទិន្នន័យយ៉ាងច្រើនចំពោះការវាយតម្លៃរបស់ខ្លួនទៅលើការចូលរួមរបស់ SSC នៅក្នុងចំណុចទាំង ៨ ស្តីពីការចូលរួមរបស់សហគមន៍ដែលមានចែងនៅក្នុងសេចក្តីណែនាំឆ្នាំ២០១២ ស្តីពីការបង្កើត SSC

ឈ្មោះចូលរៀន” និង “ការទប់ស្កាត់ភាពមិនប្រក្រតី”។ ភាពខុសគ្នាប្រកបដោយសក្តានុពលទាំងនេះ បង្ហាញពីការភ្ជាប់ទំនាក់ទំនងកាន់តែច្រើនឡើងរបស់សហគមន៍ជាមួយសាលារៀននៅតំបន់ជនបទ និងទំនាក់ទំនងដែលកាន់តែទន់ខ្សោយមួយនៅក្នុងទីក្រុង។

ដើម្បីពិនិត្យមើលពីភាពខុសគ្នាផ្សេងៗទៀតទៅតាមទីតាំងភូមិសាស្ត្រ ក្រុមស្រាវជ្រាវបានប្រមូលផ្តុំគ្នានូវពល់តួនាទី និងការទទួលខុសត្រូវទាំងអស់របស់សមាជិក SSC ដែលគេចង់ស៊ើបអង្កេតមើលនៅក្នុងការសិក្សានេះ ហើយត្រូវបានគេរៀបចំធ្វើតេស្តខ្លឹមសារទៅតាមតំបន់ដោយប្រើប្រាស់ការវិភាគមួយពីការប្រែប្រួល (ANOVA)។ ការវិភាគបង្ហាញថា ការចូលរួមរបស់ SSC ដែលគេយល់ឃើញនៅក្នុងសកម្មភាពរបស់សាលារៀនមានភាពខុសគ្នាច្រើនទៅតាមតំបន់ ($p$< .05)។ ភស្តុតាងបញ្ជាក់ថា ខេត្តរតនៈគីរី សៀមរាប និងរាជធានីភ្នំពេញ ការយល់ឃើញពីការចូលរួមរបស់សមាជិក SSC នៅក្នុងសកម្មភាពដែលទាក់ទងនឹងសាលារៀនមានកម្រិតទាបបំផុត (សូមមើលតួលេខទី២)។ មានការកែលម្អតិចតួចចំពោះការចូលរួមរបស់ SSC នៅក្នុងសាលារៀននៅក្នុងខេត្តកំពត និងខេត្តព្រៃវែង។ ខេត្តកំពង់ចាម មានការយល់ឃើញពីការចូលរួមរបស់ SSCs ខ្ពស់ជាងគេបំផុតនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់សាលារៀន។ ការរកឃើញទាំងនេះផ្តល់នូវភស្តុតាងមួយចំនួនដែលការអនុវត្តជាក់ស្តែងនៃការចូលរួមរបស់សហគមន៍ទំនងជាមិនជាប់ទាក់ទងគ្នាច្រើនទេទៅនឹងការបែងចែកតំបន់ទីក្រុង និងជនបទ ដោយសារការយល់ឃើញ និងបទពិសោធន៍មានលក្ខណៈស្រដៀងគ្នារវាងនៅរាជធានីភ្នំពេញ និងខេត្តរតនៈគីរីដែលជាខេត្តនៅជនបទជាងគេ។ ទោះបីជាភាពខុសគ្នាផ្នែកសេដ្ឋកិច្ចសង្គមមួយត្រូវបានគេកត់សំគាល់ក៏ដោយតំបន់ទាំងពីរនេះ ពុំបានមើលឃើញការប្រែប្រួលយ៉ាងធំមួយចំពោះការចូលរួមរបស់ SSC ទេសម្រាប់តួនាទីដែលបានចែងរបស់ខ្លួន។ ការរកឃើញនេះផ្តល់នូវរូបភាពនៃការចូលរួមរបស់សហគមន៍កាន់តែល្អិតល្អន់ថែមទៀត ដែលផ្ទុយនឹងលទ្ធផលកាន់តែទូលំទូលាយឡើងចំពោះការប្រៀបធៀបតំបន់ទីក្រុង និងខេត្ត។




តួលេខទី២ ៖ *ការចូលរួមរបស់ SSC នៅក្នុងសកម្មភាពរបស់សាលារៀនទៅតាមតំបន់*

*សំគាល់ ៖ ការចូលរួមរបស់ SSC ត្រូវបានគេវាស់ដោយផ្អែកលើកម្រិត Likert មួយដែលមាន៣ពិន្ទុ ដោយពិន្ទុ 0 មានន័យថា ពុំមានការចូលរួម ពិន្ទុ ១ មានន័យថា ចូលរួមតិចតួច និងពិន្ទុ ២ មានន័យថា ចូលរួមច្រើន។ ទិន្នន័យរបស់ SSC ត្រូវបានគេប្រើប្រាស់សម្រាប់ការវិភាគនេះ.*

ទិន្នន័យរបស់នាយកសាលាត្រូវបានគេពិនិត្យមើលដើម្បីស្វែងយល់ថា តើមានភាពខុសគ្នាសំខាន់ណាមួយដែរឬទេរវាងសំណាកនានានៅតាមផ្នែកនីមួយៗ។ ផ្នែកមួយដែលប្រហែលជាដើរតួនាទី ១គឺកម្រិតនៃការអប់រំរបស់នាយកសាលា។ ទិន្នន័យបង្ហាញថា សាលារៀននៅក្នុងខេត្តកំពង់ចាមទំនងជាមានចំនួននាយកសាលាច្រើនដែលមានសញ្ញាប័ត្រសាកលវិទ្យាល័យដែលបន្ទាប់មកគឺខេត្តកំពត។ នៅតាមតំបន់ផ្សេងទៀត ដោយរាប់បញ្ចូលទាំងរាជធានីភ្នំពេញ នាយកសាលាជាច្រើនទទួលបានការអប់រំត្រឹមកម្រិតមធ្យមសិក្សាទុតិយ-ភូមិ ឬទាបជាងនេះ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលគឺក្នុងចំណោមនាយកសាលាចំនួន ១៨ នាក់ នៅរាជធានីភ្នំពេញដែលត្រូវបានគេជ្រើសរើសសម្រាប់ការសិក្សានេះមានតែ៤នាក់ប៉ុណ្ណោះ ដែលគេរាយការណ៍ថាមានសញ្ញាប័ត្រថ្នាក់សាកលវិទ្យាល័យ។




តួលេខទី៣ ៖ *កម្រិតនៃការអប់រំរបស់នាយកសាលានៅតាមតំបន់*

នៅក្នុងការវិភាគបន្ថែមទៀតទៅលើទិន្នន័យផ្នែកគុណភាព កត្តាផ្សេងៗត្រូវបានគេរកឃើញថា អាចពន្យល់ពីភាពខុសគ្នាយ៉ាងទូលំទូលាយចំពោះការចូលរួមរបស់ SSCs នៅខេត្តកំពង់ចាម។ កត្តាទាំងនេះជាចំណុចស្នូលសម្រាប់សមាសភាពនៃសមាជិកភាពរបស់ SSC ភាពជាអ្នកដឹកនាំរបស់នាយកសាលា និងការលើកទឹកចិត្តដែលនាយកសាលាផ្តល់ឲ្យសមាជិក SSC។ ការវិភាគពីសមាសភាពនៃសមាជិករបស់ SSC បានបង្ហាញថា សាលារៀនជាច្រើនក្នុងចំណោមសាលារៀនសំណាកនៅក្នុងខេត្តកំពង់ចាមមានគ្រូបង្រៀន នាយករងសាលា និងនាយកសាលាបច្ចុប្បន្នធ្វើជាសមាជិក ឬជាប្រធានរបស់ SSCs។ ឧទាហរណ៍ នៅក្នុងសាលារៀនមួយមានគ្រូបង្រៀនចំនួន២នាក់ ដែលកំពុងបំរើការជាសមាជិករបស់ SSC ទទួលបន្ទុកផ្នែកជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ចំណែកឯនាយកសាលាខ្លួនឯងផ្ទាល់មានតួនាទីជាប្រធាន។ ដោយសារសមាជិកទាំងនេះមាននៅក្នុងសាលារៀនរួចស្រាប់ទៅហើយ ពួកគាត់បានត្រៀមខ្លួនរួចជាស្រេចក្នុងការចូលរួមនៅក្នុងការងាររបស់សាលារៀន ហើយត្រូវបានគេជូនដំណឹងយ៉ាងច្បាស់លាស់នូវអ្វីដែលនឹងបន្តកើតមាននៅក្នុងសាលារៀន។ ទោះជាយ៉ាងណាក៏ដោយ ការរៀបចំ SSC ដែលបានកំណត់នៅក្នុងសេចក្តីណែនាំថ្នាក់ជាតិពុំបានអនុញ្ញាតិឲ្យមានការរៀបចំតាមគំរូនេះទេ ហើយបានសង្កត់ធ្ងន់ថា ប្រធាន SSC គួរតែជាសមាជិកសហគមន៍ផ្សេងទៀត ដោយជ្រើសរើសបុគ្គលិកបង្រៀនធ្វើជាទីប្រឹក្សា។ ទី២ សមាជិក SSC ភាគច្រើននៅក្នុងខេត្តកំពង់ចាមបានរាយការណ៍ថា ជាទូទៅនាយកសាលាបានដឹកនាំ SSCs ហើយអញ្ជើញ SSCs មកចូលរួមប្រជុំ ឬព្រឹត្តិការណ៍ផ្សេងៗរបស់សាលារៀន។ ចំពោះចំណុចនេះ នាយកសាលាដើរតួនាទីកាន់តែសកម្មមួយក្នុងការអនុញ្ញាតិឲ្យ SSCs ចូលរួម

នៅក្នុងការងារអភិវឌ្ឍសាលារៀន។ ជាចុងក្រោយ គេកត់សំគាល់ថា នាយកសាលាផ្តល់ឲ្យសមាជិក SSC នូវគ្រឿងលើកទឹកចិត្តតាមរយៈការបញ្ជូនឈ្មោះពួកគាត់ឲ្យទៅចូលរួមនៅក្នុងសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ។ សមាជិក SSCs មួយចំនួនសាទរចំពោះឱកាសនានាដូចនេះដែលជាគ្រឿងលើកទឹកចិត្ត និងការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់ការងាររបស់ពួកគាត់ និងការទទួលស្គាល់នូវការងាររបស់ពួកគាត់។

### *ការចូលរួមរបស់សហគមន៍តាមកម្រិតសាលារៀន*

ការវិភាគនូវទិន្នន័យដែលបានញែកឲ្យដាច់ពីគ្នាត្រូវបានគេធ្វើឡើងដើម្បីពិនិត្យមើលថា តើការចូលរួមរបស់សហគមន៍ដែលគេយល់ឃើញខុសគ្នាដែរឬទេរវាងសាលារៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ លទ្ធផលនៃការប្រើប្រាស់ទិន្នន័យរបស់នាយកសាលា និង SSC បញ្ជាក់ថា នៅក្នុងករណីជាច្រើនពុំមានភាពខុសគ្នាច្រើនទេចំពោះកម្រិតនៃការចូលរួមរបស់សហគមន៍ដែលគេយល់ឃើញនៅក្នុងសកម្មភាពរបស់សាលារៀនរវាងសាលារៀនក្នុងកម្រិតទាំង២នេះ($p$>0.05)។ កម្រងទិន្នន័យទាំង២ បានបង្ហាញពីការវាយតម្លៃស្ទើរតែដូចគ្នាទាំងអស់ពីសំណាក់អ្នកចូលរួម។ ភាពខុសគ្នាដែលគួរឲ្យកត់សំគាល់ត្រូវបានគេចងក្រងជាឯកសារមានតែទៅលើ “ការពង្រឹងការចុះឈ្មោះចូលរៀន” និង “ការទប់ស្កាត់ភាពមិនប្រក្រតី” ប៉ុណ្ណោះ។ ទិន្នន័យនេះបញ្ជាក់ថា ជារួមសាលារៀនបឋមសិក្សាបានបង្ហាញឲ្យឃើញនូវកម្រិតខ្ពស់ជាងមួយ ចំពោះការចូលរួមរបស់សហគមន៍នៅក្នុងសកម្មភាពនានាដែលលើកកម្ពស់ការចុះឈ្មោះចូលរៀន ចំណែកឯនៅសាលាមធ្យមសិក្សាបឋមភូមិវិញ ការចូលរួមមានកម្រិតខ្ពស់ជាងនៅក្នុងសកម្មភាពដែលទាក់ទងនឹងការទប់ស្កាត់ភាពមិនប្រក្រតី ($p$<0.05)។ លទ្ធផលទាំងនេះចង្អុលបង្ហាញពីការផ្តល់អាទិភាពខុសគ្នារវាងចំណុចបញ្ហានានានៅក្នុងសាលារៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិដោយបញ្ជាក់ថា សហគមន៍ហាក់ដូចជាមើលឃើញថា លទ្ធភាពនៃការចុះឈ្មោះចូលរៀននៅថ្នាក់ដំបូងមានសារៈសំខាន់ជាង។ នៅក្នុងពេលជាមួយគ្នានេះដែរ ការយកចិត្តទុកដាក់ច្រើនថែមទៀតត្រូវបានគេផ្តល់ទៅលើការទប់ស្កាត់ភាពមិនប្រក្រតីនៅសាលារៀនមធ្យមសិក្សា។

### *ការចូលរួមរបស់សហគមន៍ ៖ ការវិភាគលម្អិតមួយ*

ដើម្បីផ្តល់នូវការវិភាគលម្អិតមួយទៅលើការចូលរួមរបស់ SSC នៅក្នុងសកម្មភាពរបស់សាលារៀន ការវិភាគពីមួយចំណុចទៅមួយចំណុចត្រូវបានគេធ្វើឡើងដោយផ្អែកទៅលើការឆ្លើយតបនានាចំពោះតួនាទី ដែលបានបញ្ជាក់នីមួយៗរបស់ SSCs។

### *ការរៀបចំផែនការអភិវឌ្ឍសាលារៀន*

ការវិភាគចង្អុលបង្ហាញថា សមាជិក SSC ជាទូទៅបានចូលរួមនៅក្នុងសកម្មភាពជាស្នូលចំនួន២ នៅពេលដែលគេសួរអំពីសកម្មភាពនានាដែលពាក់ព័ន្ធនឹងការរៀបចំផែនការអភិវឌ្ឍសាលារៀន ៖ (១) ការរៀបចំ និងការបង្កើតផែនការអភិវឌ្ឍសាលារៀន និង (២) ការត្រួតពិនិត្យការអនុវត្តន៍ផែនការ (សូមមើលតួលេខទី ៤)។ សកម្មភាពផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការបង្កើតទស្សនៈវិស័យ និងបេសកកម្មរបស់សាលារៀន ការវាយតម្លៃការអនុវត្តផែនការ និងការជួយបញ្ចូលផែនការអភិវឌ្ឍសាលារៀនទៅក្នុងផែនការអភិវឌ្ឍឃុំត្រូវបានសមាជិក SSC យកចិត្តទុកដាក់តិចតួចបំផុត។ ចំណុចនេះអាចបញ្ជាក់ថា ការយល់ដឹងស៊ីជម្រៅផ្នែក ផែនការអភិវឌ្ឍសាលារៀនមិនត្រូវបានគេផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់សហគមន៍ទេ។




| | រៀបចំផែនការអភិវឌ្ឍសាលា | បង្កើតចក្ខុវិស័យ និងបេសកកម្មសាលា | តាមដានការអនុវត្តន៍ផែនការអភិវឌ្ឍសាលា | វាយតម្លៃការអនុវត្តន៍ផែនការអភិវឌ្ឍសាលា | ជួយដាក់បញ្ចូលផែនការអភិវឌ្ឍសាលាចូលក្នុងផែនការអភិវឌ្ឍ ឃុំ/សង្កាត់ |
|---|---|---|---|---|---|
| នាយកសាលា | ១.៦៦ | ១.២៧ | ១.៥ | ១.២៩ | ១.១៣ |
| ខណៈកម្មការទ្រទ្រង់សាលា | ១.៥៣ | ១.១៧ | ១.៤ | ១.២៦ | ១.១៦ |
| សហគមន៍ | ១.៨ | | | | |

តួលេខទី៤ ៖ *ការចូលរួមរបស់ SSC នៅក្នុងការរៀបចំផែនការអភិវឌ្ឍសាលារៀន*

*សំគាល់ ៖ ការចូលរួមរបស់ SSC ត្រូវបានគេវាស់ដោយផ្អែកលើកម្រិត Likert មួយដែលមាន៣ពិន្ទុ ដោយពិន្ទុ ០ មានន័យថាពុំមានការចូលរួម ពិន្ទុ ១ មានន័យថាចូលរួមតិចតួច និងពិន្ទុ ២ មានន័យថាចូលរួមច្រើន។*

### ការពង្រឹងការចុះឈ្មោះចូលរៀន

ជាទូទៅ នាយកសាលា សមាជិក SSC និងសមាជិកមិនមែន SSC បានរាយការណ៍ថា សមាជិក SSC បាន ចូលរួមតិចតួចនៅក្នុងការពង្រឹងការចុះឈ្មោះចូលរៀន ជាពិសេសនៅក្នុងការបង្កើតកម្មវិធីដ៏រឹងមាំនានាដើម្បីជួយសិស្សឲ្យមានលទ្ធភាពទទួលបានការអប់រំ ទោះបីជាមានឧបសគ្គផ្នែកហិរញ្ញវត្ថុ ការលំបាកផ្នែករាងកាយ ឬស្ថានភាពជនជាតិភាគតិចក៏ដោយ (សូមមើលតួលេខទី៥)។ ទោះជាយ៉ាងនេះក្តី ទិន្នន័យបានបញ្ជាក់ថា ពួកគាត់បានជួយសាលារៀននៅក្នុងវិសាលភាពដ៏ធំមួយនៅក្នុងសកម្មភាពនានាដូចជា ការគាំទ្រដាក់ស្តែងទៅលើយុទ្ធនាការចុះឈ្មោះកុមារគ្រប់អាយុឲ្យចូលរៀន ("ការប្រមូលកុមារដែលគ្រប់អាយុចូលរៀនឲ្យមកសាលារៀន") ព្រមទាំងអប់រំប្រជាជនតាមមូលដ្ឋានឲ្យបញ្ជូនកូនៗរបស់គាត់មកសាលារៀននៅពេលដែលគ្រប់អាយុ។ ជាងនេះទៅទៀត លទ្ធផលនានាបង្ហាញថា ពួកគាត់មានចូលរួមច្រើនមែនទែននៅក្នុងការបើកឆ្នាំសិក្សាថ្មីជារៀងរាល់ឆ្នាំ។ ហេតុដូច្នេះហើយ ការសិក្សានេះបង្ហាញថា សាលារៀនទំនងជាធ្វើការយ៉ាងស្អិតរមួតជាមួយសហគមន៍ក្នុងការទាក់ទាញសិស្សឲ្យមកចុះឈ្មោះចូលរៀន។ ទោះជាយ៉ាងនេះក្តី ពួកគាត់នៅមិនទាន់មានភាពសកម្មគ្រប់គ្រាន់នៅឡើយនៅក្នុងការលើកកម្ពស់ការអប់រំសម្រាប់ទាំងអស់គ្នា និងការឲ្យសហគមន៍ចូលរួមនៅក្នុងការចូលឲ្យដល់កុមារដែលងាយរងគ្រោះបំផុត។ ចំណុចនេះគឺ ជាផ្នែកមួយនៃតួនាទីរបស់ SSC ដែលសមាជិកសហគមន៍មិនមែន SSC មានអារម្មណ៍ថា មានលទ្ធភាពច្រើនក្នុងការផ្តល់យោបល់ប្រហែលដោយសារការគាំទ្រសាលារៀននៅក្នុងមធ្យោបាយទាំងនេះអាចងាយមើលឃើញជាង ហើយហេតុដូច្នេះហើយទំនងជាត្រូវបានទទួលស្គាល់ពីឳពុកម្តាយនៅតាមសហគមន៍។




| | ប្រមូលក្មេងដែលគ្រប់អាយុមកចុះឈ្មោះចូលរៀន | បង្កើតកម្មវិធីផ្សេងៗដើម្បីជួយកុមារក្រីក្រឱ្យអាចចូលរៀនបាន | បង្កើតកម្មវិធីផ្សេងៗដើម្បីជួយកុមារពិការឱ្យអាចចូលរៀនបាន(ខថ្លង់ ពិការភ្នែក...) | បង្កើតកម្មវិធីផ្សេងៗដើម្បីជួយកុមារជនជាតិភាគតិចឱ្យអាចចូលរៀនបាន | អប់រំប្រជាពលរដ្ឋក្នុងសហគមន៍ឱ្យបញ្ជូនកុមារមកចូលរៀនឱ្យបានទាន់ពេលវេលា | ចូលរួមបើកបវេសនកាលជារៀងរាល់ឆ្នាំ |
|---|---|---|---|---|---|---|
| នាយកសាលា | ១.៧៦ | ១.១៩ | 0.៤៥ | 0.៤១ | ១.៧៩ | ១.៩២ |
| ខណកម្មាការទ្រទ្រង់សាលា | ១.៧៩ | ១.២៣ | 0.៥៥ | 0.៣៣ | ១.៧៣ | ១.៨៣ |
| សហគមន៍ | ១.៦៧ | ១.២៦ | 0.៧២ | 0.៣៧ | ១.៦៨ | ១.៨៨ |

តួលេខទី៥ ៖ *ការចូលរួមនៅក្នុងការពង្រឹងការចុះឈ្មោះចូលរៀន*

*សំគាល់ ៖ ការចូលរួមរបស់ SSC ត្រូវបានគេវាស់ដោយផ្អែកលើកម្រិត Likert មួយដែលមាន៣ពិន្ទុ ដោយពិន្ទុ ០ មានន័យថាពុំមានការចូលរួម ពិន្ទុ ១ មានន័យថាចូលរួមតិចតួច និងពិន្ទុ ២ មានន័យថាចូលរួមច្រើន។*

### ***ការត្រួតពិនិត្យការរៀនសូត្ររបស់សិស្ស***

ដូចដែលបានរាយការណ៍ពីខាងដើម ការចូលរួមរបស់ SSC នៅក្នុងការត្រួតពិនិត្យការរៀនសូត្ររបស់សិស្ស ជាទូទៅត្រូវបានគេរាយការណ៍ថា មានកម្រិតទាបនៅក្នុងការសិក្សានេះ។ ការវិភាគជាច់ដោយឡែកមួយដូចដែលបានបង្ហាញនៅក្នុងតួលេខទី៦ បានបង្ហាញថា SSCs ពិតជាបានចូលរួមតិចតួចមែននៅក្នុងការត្រួត-ពិនិត្យដំណើរការនៃការបង្រៀននៅក្នុងសាលារៀន ការស្វែងរកយុទ្ធសាស្ត្រដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា ការពិភាក្សាពីចំណុចបញ្ហានៃអវត្តមានរបស់នាយកសាលា គ្រូបង្រៀន ឬសិស្ស ព្រមទាំងការបង្កើតនូវយុទ្ធសាស្ត្រនានា ដើម្បីទប់ស្កាត់ជំងឺរីករាលដាល ឬគ្រោះមហន្តរាយ។ លទ្ធផលទាំងនេះបង្ហាញពីការចូលរួមដែលនៅមានកម្រិតមួយនៅក្នុងដំណើរការត្រួតពិនិត្យសាលារៀន ក៏ដូចជាយុទ្ធសាស្ត្រកែលម្អការបំពេញការងាររបស់សាលារៀនក្នុងចំណោមសមាជិក SSC។ ហេតុដូច្នេះហើយ ប្រសិទ្ធិភាពនៃយន្តការគណនេយ្យភាពរបស់សាលារៀនអាចជាចំណោទមួយទាក់ទងនឹងការរៀនសូត្ររបស់សិស្ស។ ទោះជាយ៉ាងនេះក្តី លទ្ធផលប្រកបដោយជោគជ័យត្រូវបានគេចងក្រងជាឯកសារ ស្តីពីការចូលរួមរបស់ពួកគាត់នៅក្នុងការចុះទស្សនៈកិច្ចនៅតាមសាលារៀនដើម្បីត្រួតពិនិត្យមើលការសិក្សារៀនសូត្ររបស់សិស្ស។ លទ្ធផលនានាក៏បានចង្អុលបង្ហាញបន្ថែមទៀតថា សាលារៀន និង SSCs បានរួមសហការគ្នាយ៉ាងស្អិតរមួតក្នុងការអប់រំឪពុកម្តាយឲ្យវិនិយោគច្រើនថែមទៀតទៅលើការរៀនសូត្ររបស់កូនៗរបស់គាត់ និងផ្សព្វផ្សាយពីបរិស្ថានសុខភាពរបស់សាលារៀន។ ការរកឃើញនានាដូចនេះ ចង្អុលបង្ហាញការពិតថា ការចូលរួមរបស់សហគមន៍គឺជាកង្វល់ច្រើន

ថែមទៀតទាក់ទងនឹងចំណុចបញ្ហាទូទៅនៃការរៀនសូត្ររបស់សិស្ស ព្រមទាំងបរិស្ថានសាលារៀនដែលត្រូវការការយកចិត្តទុកដាក់ និងដំណោះស្រាយបន្ទាន់ជាជាងទិដ្ឋភាពផ្នែកបច្ចេកទេសនៃការត្រួតពិនិត្យការបង្រៀន និងការរៀន។




| | អប់រំមាតាបិតាសិស្សឱ្យយកចិត្តទុកដាក់លើការសិក្សារៀនសូត្ររបស់កូន | ជួបជាមួយនាយកសាលាជាប្រចាំដើម្បីតាមដានការសិក្សារបស់សិស្ស | តាមដានដំណើរការណ៍បង្រៀនក្នុងសាលា | ស្វែងរកយុទ្ធសាស្ត្រក្នុងការកាត់បន្ថយអត្រាត្រួតថ្នាក់ | ស្វែងរកយុទ្ធសាស្ត្រក្នុងការកាត់បន្ថយអត្រាបោះបង់ | ពិភាក្សាជាមួយសាលាពីបញ្ហាអវត្តមានរបស់នាយក គ្រូ និងសិស្ស | ជំរុញឱ្យមានបរិដ្ឋានសាលាល្អសម្រាប់ការរៀនសូត្រ | ស្វែងរកយុទ្ធសាស្ត្រក្នុងទប់ស្កាត់ជំងឺឆ្លង និងបាតុភូតផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| នាយកសាលា | ១.៦ | ១.៤៤ | ១.១១ | ០.៩៥ | ១.១១ | ១.១៣ | ១.៧៣ | ១.០៧ |
| ខណកម្មាការទ្រទ្រង់សាលា | ១.៦ | ១.៣៦ | ១.១៤ | ០.៩៩ | ១.១៨ | ១.០៦ | ១.៦៣ | ១.០៩ |
| សហគមន៍ | ១.៦៣ | ១.៥៥ | ១.២៧ | ១.១៩ | | ១.១៦ | | |

តួលេខទី៦ ៖ *ការចូលរួមរបស់ SSC ក្នុងការត្រួតពិនិត្យការរៀនសូត្ររបស់សិស្ស*

*សំគាល់ ៖ ការចូលរួមរបស់ SSC ត្រូវបានគេវាស់ដោយផ្អែកលើកម្រិត Likert មួយដែលមាន៣ពិន្ទុ ដោយពិន្ទុ 0 មានន័យថា ពុំមានការចូលរួម ពិន្ទុ ១ មានន័យថា ចូលរួមតិចតួច និងពិន្ទុ ២ មានន័យថា ចូលរួមច្រើន។*

## ការប្រមូល និងការគ្រប់គ្រងមូលនិធិ

នៅពេលដែលគេសួរអំពីការប្រមូល និងការគ្រប់គ្រងមូលនិធិ ក្រុមភាគីដែលពាក់ព័ន្ធទាំង៣នេះឯកភាពថា ដំណើរការរបស់សមាជិក SSCs នៅមានកម្រិតចំពោះបុព្វហេតុនោះ។ ការរៃអង្គាសមូលនិធិសម្រាប់ផែនការអភិវឌ្ឍសាលារៀន ការជូនដំណឹងដល់សាលារៀនថា តើសាលារៀនកំពុងតែដើរលើផ្លូវត្រូវដែរឬអត់ និងការរៀបចំការណែនាំឡើងវិញនូវសកម្មភាពនានារបស់ខ្លួន ដោយផ្អែកលើការស្នើសុំគឺជាឧទាហរណ៍ចំបង (សូមមើលតួលេខទី៧)។ សមាជិក SSC ទំនងជាមានចំណេះដឹង ឬការចូលរួមតិចតួចនៅក្នុងសកម្មភាពទាំងនោះ ដោយធ្វើឲ្យសហគមន៍ពុំបានដឹងពីប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ ឬសកម្មភាពស្វែងរកមូលនិធិទេ។ ការរំពឹងទុកនានាគឺមានតែការចូលរួមរបស់ពួកគាត់នៅក្នុងផ្សព្វផ្សាយពីថវិកាដែលសាលារៀន ត្រូវការជាមួយសហគមន៍តាមមូលដ្ឋានម្ចាស់ជំនួយ ឬ NGO ក្នុងស្រុកប៉ុណ្ណោះក្នុងគោលបំណងរៃអង្គាសមូលនិធិឲ្យបានច្រើនថែមទៀតនៅតាមមូលដ្ឋាន។ ជាងនេះទៅទៀត នាយកសាលាបានរាយការណ៍ពីកម្រិតនៃការចូលរួមដ៏ខ្ពស់នៅក្នុងការត្រួតពិនិត្យពីរបៀបដែលសាលារៀនចំណាយមូលនិធិដែលមានកម្រិតនេះ (ភាគច្រើនទំនងជាមូលនិធិដែលរៃអង្គាសបានពីសហគមន៍)។ ទោះជាយ៉ាងណាក៏ដោយ ទស្សនៈនេះមិនមាននៅក្នុងចំណោមសមាជិក SSC ខ្លួនឯងផ្ទាល់ទេ។ ជារួមសមាជិក SSC ហាក់ដូចជាត្រូវបានគេទប់ស្កាត់មិនឲ្យចូលរួមនៅក្នុងការរៃអង្គាសមូលនិធិសម្រាប់ផែនការអភិវឌ្ឍសាលារៀន និងការពិភាក្សាថា តើសាលារៀនដើរលើផ្លូវត្រូវដែរឬទេចំពោះការគ្រប់គ្រងមូលនិធិ។




| | ផ្សព្វផ្សាយតម្រូវការថវិកាសាលាដល់សហគមន៍ អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយជាដើម | រៃអង្គាសមូលនិធិសម្រាប់ការអនុវត្តន៍ផែនការអភិវឌ្ឍសាលា | តាមដានលើការចាយវាយរបស់សាលា | ផ្តល់ព័ត៌មានត្រឡប់ដល់សាលាស្តីពីការចាយវាយថវិកាដែលមាន | តម្រង់ទិសការចាយវាយរបស់សាលាទៅតាមលទ្ធផលនៃការតាមដាននិងវាយតម្លៃ |
|---|---|---|---|---|---|
| នាយកសាលា | ១.៤៤ | ០.៩៦ | ១.៦៥ | ១.១៨ | ១.០៧ |
| ខណៈកម្មការទ្រទ្រង់សាលា | ១.២៨ | ១.០៧ | ១.២១ | ០.៩៨ | ១.០៤ |
| សហគមន៍ | | ១.២ | ១.២៣ | | |

តួលេខទី៧ ៖ *ការចូលរួមរបស់ SSC នៅក្នុងការប្រមូល និងគ្រប់គ្រងមូលនិធិ*

*សំគាល់ ៖ ការចូលរួមរបស់ SSC ត្រូវបានគេវាស់ដោយផ្អែកលើកម្រិត Likert មួយដែលមាន៣ពិន្ទុ ដោយពិន្ទុ ០ មានន័យថា ពុំមានការចូលរួម ពិន្ទុ ១ មានន័យថា ចូលរួមតិចតួច និងពិន្ទុ ២ មានន័យថា ចូលរួមច្រើន។*

## *ការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន*

យោងទៅតាមតួលេខទី៨ សមាជិក SSC មានការចូលរួមតិចតួចនៅក្នុងការរៃអង្គាសមូលនិធិដើម្បីសាងសង់ បន្ទប់រៀនឲ្យបានច្រើនថែមទៀតសម្រាប់សម្រួលដល់ការរៀនសូត្ររបស់សិស្ស និងការគៀងគរកំលាំងពលកម្មតាមមូលដ្ឋានដោយពុំមានការបង់ថ្លៃសម្រាប់ការសាងសង់ ឬការថែរក្សាសាលារៀន។ ប៉ុន្តែទិន្នន័យបញ្ជាក់ថា ពួកគាត់បានបង្ហាញនូវជំនួយមួយចំនួនដល់សាលារៀនចំពោះការត្រួតពិនិត្យដំណើរការនៃការសាងសង់សាលារៀនដើម្បីធានាថា ការងារកំពុងត្រូវបានគេអនុវត្តបានយ៉ាងត្រឹមត្រូវ ព្រមទាំងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធដែលមាន។ ភស្តុតាងដូចនេះបញ្ជាក់ពីការពិតថា សហគមន៍ពុំបានដើរតួនាទីដ៏សំខាន់មួយនៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនទេ ប៉ុន្តែមានតែការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនប៉ុណ្ណោះ។ ការរកឃើញទាំងនេះបញ្ជាក់ថា ទំនាក់ទំនងរបស់សហគមន៍ និងសាលារៀន ចំពោះចំណុចនេះមិនត្រូវបានបង្កើតឡើងយ៉ាងល្អទេ។




| | គៀរគរមូលនិធិជាសាច់ប្រាក់ ឬជាសម្ភារៈផ្សេងៗដើម្បីកសាងបន្ទប់រៀនបន្ថែមសម្រាប់សម្រួលដល់ការរៀនសូត្ររបស់សិស្សានុសិស្ស | គៀរគរកម្លាំងសហគមន៍ដើម្បីជួសជុល និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលា | តាមដានដំណើរការសាងសង់សាលា | ចូលរួមថែរក្សាអ ý រដែលមានស្រាប់ |
|---|---|---|---|---|
| នាយកសាលា | ១.0៩ | ១.១៧ | ១.៤១ | ១.៥៧ |
| ខណកម្មាការទ្រទ្រង់សាលា | ១.១៤ | ១.0៥ | ១.២៤ | ១.៥១ |
| សហខមន៏ | ១.២២ | ១.១៥ | | ១.៥៥ |

តួលេខទី៨ ៖ *ការចូលរួមរបស់ SSC នៅក្នុងការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន*

*សំគាល់ ៖ ការចូលរួមរបស់ SSC ត្រូវបានគេវាស់ដោយផ្អែកលើកម្រិត Likert មួយដែលមាន៣ពិន្ទុ ដោយពិន្ទុ 0 មានន័យថា ពុំមានការចូលរួម  ពិន្ទុ ១ មានន័យថា ចូលរួមតិចតួច និងពិន្ទុ ២ មានន័យថា ចូលរួមច្រើន។*

## ការចែករំលែកបទពិសោធន៍ និងបំណិនជីវិត

នៅពេលដែលគេសួរអំពីការចូលរួមរបស់ខ្លួននៅក្នុងការចែករំលែកបទពិសោធន៍ និងបំណិនជីវិត អ្នកចូលរួមទាំង៣ក្រុមនេះបានលើកឡើងនូវចម្លើយដូចគ្នាថា សាលារៀន និងសមាជិក SSC ហាក់ដូចជាមានភាពព្រងើយកន្តើយចំពោះសកម្មភាពនៃការពង្រឹងចំណេះដឹងទាំងនេះ។ ដោយផ្អែកលើតួលេខទី៩ លទ្ធផលបានបង្ហាញថាសមាជិក SSC ស្ទើរតែទាំងអស់ពុំបានចូលរួមនៅក្នុងសកម្មភាពដូចនេះរបស់សាលារៀនទេ។ ការរកមើលភាគីដែលពាក់ព័ន្ធនានាសម្រាប់កម្មវិធីបំណិនជីវិត និងបច្ចេកទេសនៅតាមសាលារៀន ការផ្តល់ការបណ្តុះបណ្តាលពីបំណិនជីវិតដល់សិស្ស និងការចងក្រងនូវការប្រតិបត្តិល្អស្តីពីបំណិនជីវិត និងបច្ចេកទេសតាមមូលដ្ឋានសម្រាប់សាលារៀន ជាទូទៅមិនត្រូវបានអនុវត្ត និងចូលរួមច្រើនពីសំណាក់សហគមន៍ឡើយ។ ការខ្វះការអនុវត្តនេះបញ្ជាក់ថា សកម្មភាពស្នូលទាំងនេះទំនងជាគោលគំនិតថ្មី ឬតួនាទីដែលមានការយល់ដឹងតិចរបស់ SSC ទាំងក្នុងចំណោមនាយកសាលា និងសហគមន៍ទូទៅ។ ការសម្ភាសន៍ជាមួយតំណាង NGO ដែលបាន និងកំពុងធ្វើការនៅកម្រិតសាលារៀនបង្ហាញថា ទោះបីជាសហគមន៍ត្រូវបានគេផ្តល់ឲ្យនូវតួនាទីក្នុងការចែករំលែកបទពិសោធន៍ផ្នែកបំណិនជីវិតដល់សិស្ស និងបុគ្គលិករបស់សាលារៀនក៏ដោយ ក៏សាលារៀនស្ទើរតែទាំងអស់ពុំ

បានទទួលនូវគាំទ្រស្តីពីការចែករំលែកបទពិសោធន៍ និងបំណិនជីវិតពីសហគមន៍ដែរ។ អ្នកឆ្លើយតបម្នាក់របស់ NGOមានយោបល់ដូចខាងក្រោម ៖

> *ជាទូទៅ សហគមន៍មើលឃើញកម្មវិធីចែករំលែកបទពិសោធន៍ និងបំណិនជីវិតថាជាបន្ទុករបស់ខ្លួន ដោយសារពួកគាត់ត្រូវចំណាយពេលវេលាមកសាលារៀន និងផ្តល់នូវការពិភាក្សា និងបបក់ថាស្តីពីការចែករំលែកបទពិសោធន៍មួយចំនួន ហើយពួកគាត់ជឿជាក់ថា សកម្មភាពដូចនេះគឺជាតួនាទី និងការទទួលខុសត្រូវដាច់មុខរបស់សាលារៀន និងគ្រូបង្រៀន។ ដូច្នេះការវិនិយោគរបស់ពួកគាត់គឺមិនចាំបាច់ទេ។*




| | ស្វែងរកគ្រូបង្រៀនបំនិនជីវិត និងជំនាញបច្ចេកទេសជូនសាលា | ផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ | ចងក្រងបទពិសោធន៍ល្អៗស្តីពីបំនិនជីវិត និងជំនាញបច្ចេកទេសជូនសាលា |
|---|---|---|---|
| នាយកសាលា | 0.៣ | 0.២១ | 0.២៧ |
| ឋណៈកម្មការទ្រទ្រង់សាលា | 0.២៨ | 0.២៨ | 0.២៥ |
| សហគមន៍ | 0.៤៤ | | |

តួលេខទី៩ ៖ *ការចូលរួមរបស់ SSC នៅក្នុងការចែករំលែកបទពិសោធន៍ និងបំណិនជីវិត*

*សំគាល់ ៖ ការចូលរួមរបស់ SSC ត្រូវបានគេវាស់ដោយផ្អែកលើកម្រិត Likert មួយដែលមាន៣ពិន្ទុ ដោយពិន្ទុ 0 មានន័យថា ពុំមានការចូលរួម ពិន្ទុ ១ មានន័យថា ចូលរួមតិចតួច និងពិន្ទុ ២ មានន័យថា ចូលរួមច្រើន។*

## ***ការទប់ស្កាត់ភាពមិនប្រក្រតី***

ជាទូទៅ សហគមន៍បានរាយការណ៍ពីការចូលរួមតិចតួចនៅក្នុងការទប់ស្កាត់ភាពមិនប្រក្រតីនៅតាមសាលារៀន។ លទ្ធផលដែលបានបង្ហាញពីមុនៗមកបញ្ជាក់ថា សមាជិក SSC ដែលជាក្រុមស្នូលតំណាងឲ្យសហគមន៍ពុំបានចូលរួមឲ្យបានសកម្មនៅក្នុងការកែលម្អការទប់ស្កាត់ភាពមិនប្រក្រតីនៅតាមសាលារៀនទេ។ ប៉ុន្តែគេគួរកត់សំគាល់ថា សមាជិក SSC ទំនងជារួមចំណែកដល់ការទប់ស្កាត់ភាពមិនប្រក្រតីរបស់សាលារៀននៅក្នុងចំណុចជាក់លាក់មួយ។ តួលេខទី១០ចង្អុលបង្ហាញថា សមាជិក SSC មានការចូលរួមតិចតួចក្នុងសកម្មភាពទប់ស្កាត់ភាពមិនប្រក្រតីដូចជាការដោះស្រាយបញ្ហារបស់សិស្សដែលបានប្រព្រឹត្តខុស និងការដោះ-ស្រាយបញ្ហានៅខាងក្នុង និងខាងក្រៅសាលារៀនដូចជាបញ្ហានៃការសំឡុតបំពាន អំពើហិង្សា។ល។ ទោះជាយ៉ាងនេះក្តី នៅពេលមកដល់ចំណុចនៃការធានាសុវត្ថិភាព និងបរិស្ថានដែលមានលក្ខណៈមេត្រីសម្រាប់អ្នក

សិក្សា ការចូលរួមរបស់ពួកគាត់ពិតជាមានកម្រិតខ្ពស់មែនទែនដែលបញ្ជាក់បានថា នៅក្នុងវិសាលភាពខ្លះ សមាជិក SSC មានទំនោរទៅរកការយល់ដឹងកាន់តែច្រើនពីទិដ្ឋភាពទូទៅនៃបរិស្ថាននៃការរៀនសូត្រជាងការជួយសាលារៀន នៅក្នុងការដោះស្រាយបញ្ហាដែលសង្គមមិនត្រូវការ ដូចជាការសំឡុតបំពាន បទព្រហ្មទន្ឌ ការលែងល្បែងក្នុងវីដេអូ។ល។




| | ធានាឱ្យមានបរិស្ថានល្អសម្រាប់ការរៀនសូត្រ | ដោះស្រាយបញ្ហាសិស្សដែលមិន ɩ ý រពវិន័យ | ដោះស្រាយបាតុភាពមិនល្អក្នុងសាលា ដូចជាអំពើហឹង្សា ការសម្លុតជាដើម | ដោះស្រាយបាតុភាពមិនល្អក្រៅសាលា ដូចជាទូរហោ៩ ហឹង្សាជាដើម |
|---|---|---|---|---|
| នាយកសាលា | ១.៦១ | ១.0៨ | 0.៩៧ | 0.៨៧ |
| ខណកម្មាការទ្រទ្រង់សាលា | ១.៥៨ | ១.១២ | 0.៨៩ | 0.៧៥ |
| សហខមន៍ | ១.៥២ | | ១.១៣ | ១.១៣ |

*តួលេខទី១០ ៖ ការចូលរួមរបស់ SSC ក្នុងការទប់ស្កាត់ភាពមិនប្រក្រតី*

*សំគាល់ ៖ ការចូលរួមរបស់ SSC ត្រូវបានគេវាស់ដោយផ្អែកលើកម្រិត Likert មួយដែលមាន៣ពិន្ទុ ដោយពិន្ទុ 0 មានន័យថា ពុំមានការចូលរួម ពិន្ទុ ១ មានន័យថា ចូលរួមតិចតួច និងពិន្ទុ ២ មានន័យថា ចូលរួមច្រើន។*

### ***ការកសាងសមត្ថភាព***

ការសិក្សាស្រាវជ្រាវក្នុងពេលបច្ចុប្បន្នរកឃើញថា ការចូលរួមរបស់សហគមន៍នៅក្នុងការកសាងសមត្ថភាពគឺមានកម្រិតទាបមែនទែន។ ការវិភាគពីមួយចំណុចទៅមួយចំណុចគាំទ្រលទ្ធផលទាំងនេះដូចៗគ្នា។ ដូចដែលតួលេខទី១១បានបង្ហាញថា សមាជិក SSC មានការចូលរួមតិចតួចជាមួយសាលារៀននៅក្នុងការបង្កើតវេទិកាសម្រាប់សាលារៀន និងសហគមន៍ក្នុងការចែករំលែកបទពិសោធន៍ជាមួយគ្នា ព្រមទាំងនៅក្នុងការវាយតម្លៃការរៀនសូត្រ និងការបង្រៀននៅតាមសាលារៀនដើម្បីស្វែងរកមធ្យោបាយកែលម្អចំណុចទាំងនេះ។ ការរកឃើញនេះបញ្ជាក់ថា កិច្ចសហប្រតិបត្តិការរវាងសាលារៀន និងសហគមន៍ដែលមានគោលបំណងកសាងសមត្ថភាពមិនត្រូវបានគេអនុវត្តជាក់ស្តែងឲ្យបានខ្ពស់ទេនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ។




| | បង្កើតវេទិកាសម្រាប់ផ្លាស់ប្តូរបទពិសោធន៍ ទៅវិញទៅមក | វាយតម្លៃការរៀន និងបង្រៀនដើម្បីរកវិធីសាស្ត្រកែលម្អ |
|---|---|---|
| នាយកសាលា | 0.៦ | 0.៧៩ |
| គណកម្មាការទ្រទ្រង់សាលា | 0.៦១ | 0.៧៤ |
| សហគមន៍ | 0.៧២ | 0.៧៤ |

តួលេខទី១១ ៖ *ការចូលរួមរបស់ SSC ក្នុងការកសាងសមត្ថភាព*

*សំគាល់ ៖ ការចូលរួមរបស់ SSC ត្រូវបានគេវាស់ដោយផ្អែកលើកម្រិត Likert មួយដែលមាន៣ពិន្ទុ ដោយពិន្ទុ 0 មានន័យថា ពុំមានការចូលរួម  ពិន្ទុ ១ មានន័យថា ចូលរួមតិចតួច និងពិន្ទុ ២ មានន័យថា ចូលរួមច្រើន។*

## ***ការបំពេញការងាររបស់សាលារៀន***

ដោយសារវាជាផ្នែកមួយនៃការស្រាវជ្រាវពីគណនេយ្យភាពរបស់សាលារៀននេះ ទិន្នន័យស្តីពីការបំពេញការងាររបស់សាលារៀនក៏ត្រូវបានគេប្រមូលសម្រាប់ធ្វើជាធាតុចូលក្នុងការពិនិត្យពីវិសាលភាព ដែលភាគីរបស់សាលារៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅក្នុងការសិក្សាបច្ចុប្បន្ននេះមានអារម្មណ៍ថា ពួកគាត់មានគណនេយ្យភាពចំពោះការបំពេញការងាររបស់សាលារៀនរបស់ខ្លួន និងការរៀនសូត្ររបស់សិស្ស។ បច្ចុប្បន្ននេះពុំមានការចាត់ចំណាត់ថ្នាក់ជាទូទៅទៅលើការបំពេញការងាររបស់សាលារៀនទេនៅក្នុងប្រទេសកម្ពុជា ហើយហេតុដូច្នេះហើយ លំដាប់ថ្នាក់នៃការវាស់វែងជាលក្ខណៈតំណាងត្រូវបានគេប្រើប្រាស់ ដើម្បីពិភាក្សាពីការបំពេញការងាររបស់សាលារៀនជាមួយអ្នកទាំងឡាយណាដែលបានចូលរួមនៅក្នុងការសិក្សានេះ។ ចំណាត់ថ្នាក់នានាមាននៅតាមថ្នាក់ខេត្ត ទោះជាយ៉ាងនេះក្តី ពុំមានប្រភពដែលអាចជឿជាក់បាន ឬដែលមានរួចជាស្រេចទេ។

ផ្នែកនេះបង្ហាញពីស្ថានភាព ឬសភាពនៃការបំពេញការងាររបស់សាលារៀនពីសំណាក់អ្នកតំណាងទាំង ៣ ៖ នាយកសាលា សមាជិក SSC និងសមាជិកសហគមន៍ដែលមិនមែនជា SSC។

### ការប្រមូល និងការប្រើប្រាស់ទិន្នន័យរបស់កុមារដែលគ្រប់អាយុចូលរៀន

ដោយយោងទៅតាមនាយកសាលា សាលារៀនទំនងជាចូលរួមក្នុងការប្រមូលទិន្នន័យរបស់កុមារដែលគ្រប់អាយុចូលរៀនយ៉ាងស្អិតរមួតបំផុត។ នេះគឺជាសកម្មភាពដ៏សំខាន់មួយចំពោះការលើកកម្ពស់ការចុះឈ្មោះចូលរៀន និងវត្តមានក្នុងពេលរៀន។ ដូចដែលតួលេខទី១២បានបង្ហាញ នាយកសាលាស្ទើរតែ៨០% បញ្ជាក់ថាសាលារៀនរបស់ពួកគាត់បានប្រមូលព័ត៌មានស្តីពីកុមារដែលគ្រប់អាយុចូលរៀនជារៀងរាល់ឆ្នាំ។ នាយកសាលាមានតែ១២%ប៉ុណ្ណោះ ដែលបានរាយការណ៍ថា ពួកគាត់ពុំដែលបានរៀបចំការប្រមូលទិន្នន័យណាមួយស្តីពីចំនួនសិស្សដែលគេសន្មត់ថាត្រូវចុះឈ្មោះចូលរៀនទេ។ ជាងនេះទៅទៀត ពួកគាត់ក៏បានប្រើប្រាស់ទិន្នន័យទាំងនោះដើម្បីរកមើលកុមារដែលគ្រប់អាយុចូលរៀនឲ្យមកចុះឈ្មោះចូលរៀនក្នុងពេលដែលនាយកសាលាតែ១៣%ប៉ុណ្ណោះ ដែលត្រូវបានគេរាយការណ៍ថាពុំបានប្រើប្រាស់ទិន្នន័យដែលមានដើម្បីឲ្យសិស្សទាំងនោះមកចុះឈ្មោះចូលរៀន។




តួលេខទី១២ ៖ ការប្រមូលទិន្នន័យកុមារគ្រប់អាយុចូលរៀន




តួលេខទី១៣ ៖ ការប្រើប្រាស់ទិន្នន័យរបស់សាលារៀន

### អត្រាបោះបង់ការសិក្សា និងអត្រាឡើងថ្នាក់

នៅពេលដែលគេសួរអំពីអត្រាបោះបង់ការសិក្សា អត្រាត្រួតថ្នាក់ និងអត្រាឡើងថ្នាក់ តាមរបាយការណ៍នាយកសាលាចំនួន២៩នាក់ ពុំបានដឹងពីទិន្នន័យនេះសម្រាប់សាលារៀនរបស់ខ្លួនឡើយ។ ចំណុចនេះគឺជារឿងគួរឲ្យភ្ញាក់ផ្អើលនៅពេលគិតគូរពិចារណាពីតួនាទីដ៏សំខាន់របស់នាយកសាលានៅក្នុងការគ្រប់គ្រងការសិក្សារៀនសូត្ររបស់សិស្ស និងក្នុងការធានាថា សិស្សស្ថិតនៅក្នុងសាលារៀន។ នាយកសាលាផ្សេងៗទៀតហាក់បីដូចជាដឹងពីការបោះបង់ការសិក្សា ការត្រួតថ្នាក់ និងការឡើងថ្នាក់ ដោយទិន្នន័យបញ្ជាក់ថា អត្រាជារួមគឺ ៥.៧%, ៦.៤៦% និង៨៨.៣៧%រៀងគ្នា។ ទោះជាយ៉ាងនេះក្តី គេពុំបានដឹងច្បាស់ទេពីរបៀបដែលគេប្រើប្រាស់ព័ត៌មាននេះសម្រាប់ការគ្រប់គ្រងរបស់សាលារៀន ឬគោលបំណងនៃការអប់រំផ្សេងៗទៀត។ ការរកឃើញនេះលើកឡើងពីការអនុវត្តជាក់ស្តែងនូវកម្រិតស្តង់ដាររងក្នុងចំណោមនាយកសាលាចំពោះការគ្រប់គ្រងទិន្នន័យរបស់សិស្ស។

### *ពេលវេលាដែលចំណាយទៅលើភារកិច្ចនៃការគ្រប់គ្រងសាលារៀន*

ពេលវេលាដែលគេចំណាយទៅលើភារកិច្ចនៃការគ្រប់គ្រងសាលារៀន ក៏ត្រូវបានគេប្រមូលដែរដើម្បីបង្ហាញពីរបៀបដែលនាយកសាលាប្រើប្រាស់ពេលវេលារបស់ខ្លួនក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។ លទ្ធផលនានាបានបង្ហាញថា នាយកសាលាបានចំណាយពេលវេលាភាគច្រើនរបស់ខ្លួនទៅលើការងាររដ្ឋបាល និងកិច្ចការផ្នែកកម្មវិធីសិក្សា និងការបង្រៀន។ តួលេខទី១៤បង្ហាញថា ពេលវេលាជាច្រើន ត្រូវបានគេលៃបំរុងទុកសម្រាប់ភារកិច្ចដ៏សំខាន់ទាំង២នេះ។ ម្យ៉ាងវិញទៀត ពួកគាត់បានចំណាយពេលវេលាធ្វើការទៅលើការឆ្លើយតបទៅនឹងការស្នើសុំ ឬបញ្ជាពី DoE, PoE និង MoEYS ជាការអនុវត្តជាក់ស្តែងមួយដែលឆ្លុះបញ្ចាំងពីលក្ខណៈតាមបែបឋានានុក្រមមួយនៃការគ្រប់គ្រង និងភាពជាអ្នកដឹកនាំរបស់សាលារៀន ព្រមទាំងការទទួលខុសត្រូវរបស់នាយកសាលាចំពោះអង្គភាពអភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា។ នាយកសាលាទំនង ជាចំណាយពេលវេលាតិចតួចក្នុងការជួបប្រជុំជាមួយសហគមន៍ និងការកសាងបណ្តាញរបស់សាលារៀន ឬការចូលរួមនៅក្នុងព្រឹត្តិការណ៍សង្គមផ្សេងៗទៀតដែលតភ្ជាប់ទំនាក់ទំនងសហគមន៍ទៅសាលារៀន ដែលជាហេតុធ្វើឲ្យចំណុចបញ្ហានៃគណនេយ្យភាពរបស់សហគមន៍ចំពោះសាលារៀននៅតែជាចំណោទដដែល។




*តួលេខទី១៤ ៖ ពេលវេលាដែលគេចំណាយទៅលើភារកិច្ចគ្រប់គ្រងសាលារៀន*

### *គណនេយ្យភាពរបស់សាលារៀនដែលគេយល់ឃើញ*

នៅពេលដែលគេសួរអំពីគណនេយ្យភាពរបស់សាលារៀន នាយកសាលានៅក្នុងគម្រោងនៃការសិក្សានេះហាក់ដូចជាមានការយល់ដឹងយ៉ាងពេញលេញពីតួនាទីរបស់សាលារៀនចំពោះភាគីដែលពាក់ព័ន្ធខុសៗគ្នា។ នាយកសាលាស្ទើរតែទាំងអស់ចង្អុលបង្ហាញថា សាលារៀនរបស់ខ្លួនដើរតួនាទីដ៏សំខាន់មួយ នៅក្នុងការលើកកម្ពស់ការបង្រៀន និងការរៀន។ ទោះជាយ៉ាងនេះក្តី ការឆ្លើយតបនេះផ្ទុយទៅនឹងអ្វីដែលគេបានរាយការណ៍ពីមុនមកទាក់ទងនឹងពេលវេលាដែលគេចំណាយទៅលើភារកិច្ចនៃការគ្រប់គ្រងសាលារៀន។ ខណៈពេលដែលពួកគាត់យកចិត្តទុកដាក់ចំពោះដំណើរការរបស់សាលារៀនចំពោះសហគមន៍ និងសង្គម ការងាររបស់ពួកគាត់គឺមានគណនេយ្យភាពច្រើនលើសលប់ចំពោះអង្គភាពអភិបាលកិច្ចរបស់ពួកគាត់ជាងសហគមន៍ និងសង្គម។

ហេតុដូច្នេះហើយ ការរកឃើញនេះហាក់ដូចជាបង្ហាញឲ្យឃើញនូវគម្លាតដ៏ធំមួយរវាងការយល់ពីដំណើរការ និងការទទួលខុសត្រូវរបស់សាលារៀនក្នុងចំណោមនាយកសាលា និងការអនុវត្តជាក់ស្តែងពិតប្រាកដរបស់ពួកគាត់។

តារាងទី៣ ៖ គណនេយ្យភាពរបស់សាលារៀន

| តើសាលារៀនរបស់អ្នកមានគណនេយ្យភាពចំពោះអ្នកណា? | ទេ | បាទ / ចាំ |
|---|---|---|
| ចំពោះ MOEYS | ៧% | ៩៣% |
| ចំពោះ DOE / POE | ៧% | ៩៣% |
| ចំពោះគ្រូបង្រៀន | ៧% | ៩៣% |
| ចំពោះការសិក្សារៀនសូត្រ | ២% | ៩៨% |
| ចំពោះការអភិវឌ្ឍសមត្ថភាព | ៦% | ៩៤% |
| ចំពោះឪពុកម្តាយ និងសហគមន៍ | ៥% | ៩៥% |

*ចំណាំ ៖ នៅក្នុងសំណួរនេះ គេអនុញ្ញាតឲ្យឆ្លើយចំឡើយលើសពីមួយ*

លទ្ធផលដែលបានពីការសម្ភាសន៍តំណាង NGO បង្ហាញថា អ្នកផ្តល់បទសម្ភាសន៍ចំនួន១២នាក់ ក្នុងចំណោម១៥នាក់ បានបញ្ជាក់អះអាងថា នាយកសាលាបានយល់ដឹងយ៉ាងច្បាស់លាស់ពីអត្ថន័យនៃគណនេយ្យ-ភាពរបស់សាលារៀន ព្រមទាំងដឹងពីតួនាទី និងការទទួលខុសត្រូវរបស់គាត់ ចំណែកឯអ្នកតំណាងផ្សេងទៀតបានបញ្ជាក់ថា មានតែសាលារៀនទាំងឡាយណាដែលធ្វើការជាមួយ NGO ទេដែលមានការយល់ដឹងយ៉ាងទូលំទូលាយពីអត្ថន័យ និងទិដ្ឋភាពផ្សេងៗនៃគណនេយ្យភាពរបស់សាលារៀន។ យោងតាមអ្នកផ្តល់បទសម្ភាសន៍ចំនួន២នាក់ ផ្សេងទៀត នាយកសាលាពុំបានដឹងទេថាតើគណនេយ្យភាពរបស់សាលារៀនមានអ្វីខ្លះ ហើយភាគច្រើនបានអនុវត្តនូវសកម្មភាពដដែលៗតាមទំលាប់ និងសកម្មភាពនានាដែលមានលក្ខណៈងាយស្រួលសម្រាប់ពួកគាត់ ហើយគណៈកម្មការទ្រទ្រង់សាលារៀន និងសហគមន៍ដែលតួនាទីរបស់ខ្លួន ត្រូវធ្វើឲ្យសាលារៀនមានគណនេយ្យភាពចំពោះភារកិច្ចដែលគេចាត់តាំងពុំបានបំពេញតួនាទីរបស់ខ្លួនតែម្តង។ ការយល់ឃើញដែលគេបង្ហាញនេះគឺថា ពួកគាត់ជឿជាក់ថាការចូលរួមនៅក្នុងសកម្មភាពនានា ដែលគាំទ្រសាលារៀនធ្វើឲ្យមានការរំខានដល់ដំណើរការរបស់សាលារៀន។ SSC អនុវត្តតែភារកិច្ចណាដែលនាយកសាលាចង់ឲ្យពួកគាត់ធ្វើប៉ុណ្ណោះ ហើយពួកគាត់មិនដែលមានគំនិតផ្តួចផ្តើមលើសពីដែនកំណត់នេះទេក្នុងការបំពេញភារកិច្ចរបស់ខ្លួនឲ្យបានពេញលេញ។

### *សកម្មភាពវាយតម្លៃសាលារៀន*

ទាក់ទងនឹងការវាយតម្លៃសាលារៀន ទិន្នន័យដែលបានបង្ហាញនៅក្នុងតួលេខទី១៥ បញ្ជាក់ថា សាលារៀនមានការចូលរួមតិចតួចនៅក្នុងដំណើរការវាយតម្លៃសាលារៀន ឬការបោះពុម្ពផ្សាយនូវរបាយការណ៍នានាជាសាធារណៈលើសពីអ្វីដែលគេអាចរំពឹងទុកទេ។ នាយកសាលាចំនួន៣២% បានរាយការណ៍ថា ពួកគាត់ពុំដែលបានបោះពុម្ពរបាយការណ៍ស្វ័យវាយតម្លៃណាមួយទេ។ ការវាយតម្លៃពីខាងក្រៅមិនត្រូវបានគេធ្វើឡើងជាញឹកញាប់ទេ ដោយមានសាលារៀនតែប្រមាណ៣០%ប៉ុណ្ណោះ ដែលត្រូវបានគេវាយតម្លៃពីខាងក្រៅជារៀងរាល់ឆ្នាំ។ សាលារៀនស្ទើរតែ៧០% ពុំដែលបានបោះពុម្ពផ្សាយនូវរបាយការណ៍វាយតម្លៃរបស់សាលារៀនណា

មួយទេ។ ការខ្វះនូវ (របាយការណ៍) ស្វ័យវាយតម្លៃនេះអាចទាក់ទងនឹងការខ្វះនូវព័ត៌មានគ្រប់ដែលគេទទួលបាន ស្តីពីការបំពេញការងាររបស់សាលារៀននៅក្នុងមូលដ្ឋានជាទៀងទាត់មួយ។




តួលេខទី១៥ ៖ *សកម្មភាពវាយតម្លៃរបស់សាលារៀន*

### ***បញ្ហារបស់សាលារៀន ៖ ការយល់ឃើញរបស់នាយកសាលា***

ចំពោះបញ្ហារបស់សិស្សនៅឯសាលារៀន ជាទូទៅនាយកសាលាបានបញ្ជាក់ថា បញ្ហាដែលកើតឡើងញឹកញាប់បំផុតគឺទាក់ទងនឹងការមកយឺត និងអវត្តមានរបស់សិស្ស។ បញ្ហាផ្សេងៗទៀតរាប់បញ្ចូលការលួចចំឡងរបស់សិស្សក្នុងពេលប្រឡង ការជេរគ្នានៅក្នុងថ្នាក់ និងការរំខាននៅក្នុងថ្នាក់ ទោះបីជាចំណុចបញ្ហាទាំងអស់នេះមិនត្រូវបានគេចាត់ទុកថាជាបញ្ហាចំបងដែលកើតមានឡើងជាទៀងទាត់នៅតាមសាលារៀនក៏ដោយ។ យោងតាមតួលេខទី១៦ បញ្ហាដ៏ទៃទៀតដែលសិស្សបានបង្កឡើងមានដូចជា ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ការប្រមាថជាពាក្យសំដី អំពើហិង្សា ឬការប្រើប្រាស់គ្រឿងញៀនមិនមែនជារឿងទូទៅនៅតាមសាលារៀនទេ។




តួលេខទី១៦ ៖ *បញ្ហារបស់សិស្សនៅតាមសាលារៀន*

នាយកសាលានៅក្នុងការសិក្សានេះមានទំនោរទៅរកការឯកភាពថា សាលារៀនរបស់ពួកគាត់កំពុងជួបប្រទះបញ្ហានានាទាក់ទងនឹងការមកយឺត និងអវត្តមានរបស់គ្រូបង្រៀន។ យោងតាមតួលេខទី១៧ អវត្តមានរបស់គ្រូបង្រៀនគឺជាបញ្ហាដែលបានកើតឡើងដដែលៗជាញឹកញាប់បំផុត ទោះបីជាមានការរាយការណ៍តែពីរបីករណីប៉ុណ្ណោះកំពុងកើតមាននៅតាមសាលារៀនក៏ដោយ។ ការរកឃើញនេះឆ្លុះបញ្ចាំងពីការរកឃើញនានាតាមរយៈការសិក្សាផ្សេងៗទៀតស្តីពីស្ថានភាពបច្ចុប្បន្ននៃការសិក្សានៅសាលារៀននៅប្រទេសកម្ពុជា ដែលរកឃើញថា អវត្តមានរបស់គ្រូបង្រៀនគឺជាចំណុចបញ្ហាដ៏សំខាន់មួយដែលបណ្តាលឲ្យមានការបាត់ម៉ោងបង្រៀន។ បើយោងតាមនាយកសាលា ការខ្វះខាតវិធីសាស្ត្របង្រៀនដែលសមស្របក៏ត្រូវបានគេចាត់ទុកថា ជាបញ្ហាមួយដែរ។ ទិន្នន័យបង្ហាញថា នាយកសាលាចំនួន៦១% បានមើលឃើញពីការខ្វះខាតមួយនូវវិធីសាស្ត្របង្រៀនល្អក្នុងចំណោមគ្រូបង្រៀន ហើយនាយកសាលាចំនួន១២% មើលឃើញចំណុចបញ្ហានេះ ថាជាបញ្ហាទូទៅបំផុតមួយនៅឯសាលារៀនរបស់ពួកគាត់ ដោយលើកឡើងថានៅក្នុងវិសាលភាពមួយចំនួននាយកសាលាបានដឹងនូវវិធីសាស្ត្របង្រៀនមិនគ្រប់គ្រាន់។




តួលេខទី១៧ ៖ *បញ្ហារបស់គ្រូបង្រៀននៅតាមសាលារៀន*

### ***បញ្ហារបស់សាលារៀន ៖ ការយល់ឃើញរបស់សិស្ស***

សិស្សក៏បានរកឃើញនូវបញ្ហាមួយចំនួនដែរនៅខាងក្នុងសាលារៀនរបស់ខ្លួន។ បញ្ហាទាំងនោះត្រូវបានគេ ចាត់ចំណាត់ថ្នាក់ថាខ្ពស់ (លើសពី៨ក្រុម បានបញ្ជាក់) មធ្យម (រវាង៥ និង៨ក្រុម បានបញ្ជាក់) និងទាប (៤ ក្រុម ឬតិចជាងនេះបានបញ្ជាក់) ដោយផ្អែកទៅលើភាពញឹកញាប់ដែលគេបញ្ជាក់ពីបញ្ហាទាំងនោះ។ ការព្រួយបារម្ភធំជាងគេបំផុតចំពោះបញ្ហាទាំងនោះគឺអវត្តមានខ្ពស់របស់គ្រូបង្រៀន និងសិស្សនៅក្នុងសាលារៀន ព្រមទាំងការផ្គត់ផ្គង់សម្ភារៈបង្រៀន និងរៀនមានកម្រិតទាប។ អត្រាបោះបង់ការសិក្សា និងត្រួតថ្នាក់ខ្ពស់ ការសំឡុតបំពាន និងការវាយតប់គ្នា ការចោលសំរាមពាសវាលពាសកាល និងបង្គន់អនាម័យមិនស្អាតត្រូវបានគេចាត់ទុកថា ជាបញ្ហាដែលមានកម្រិតមធ្យមនៅក្នុងសាលារៀនរបស់ពួកគេ។ ពេលខ្លះពួកគេមានអារម្មណ៍ព្រួយបារម្ភអំពីការលួចចំឡងគ្នាក្នុងពេលប្រឡង ការវាយបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ការលួច និងការសេពគ្រឿងស្រវឹងនៅក្នុងបរិវេណសាលារៀន។ ទោះជាយ៉ាងណាក៏ដោយ ការសេពសុរាគឺមានសិស្សតែមួយក្រុមប៉ុណ្ណោះបានរាយការណ៍។ បើយោងតាមពួកគេ ពេលខ្លះពួកគេមើលឃើញគេសេពសុរានៅក្នុងសាលារៀននៅ

ថ្ងៃឈប់សម្រាកជាសាធារណៈ ហើយពួកគេបាននិយាយថា ទង្វើរបៀបនេះពុំគួរត្រូវបានគេអនុញ្ញាតិឲ្យកើតមាននៅក្នុងបរិវេណសាលារៀនទាល់តែសោះ។

តារាងទី៤៖ *បញ្ហារបស់សាលារៀនដោយផ្អែកលើការពិភាក្សាជាក្រុមជាមួយសិស្សចំនួន១២ក្រុម មកពីខេត្តចំនួន៥ និងរាជធានីភ្នំពេញ*

| បញ្ហារបស់សាលារៀន | ចំនួនដងដែលគេបញ្ជាក់ |
|---|---|
| ក. អវត្តមានខ្ពស់របស់សិស្ស និងគ្រូបង្រៀន | ខ្ពស់ |
| ខ. ការផ្គត់ផ្គង់សម្ភារៈបង្រៀន និងរៀនមានកម្រិតទាប | ខ្ពស់ |
| គ. អត្រាការបោះបង់ការសិក្សា និងត្រួតថ្នាក់ខ្ពស់ | មធ្យម |
| ឃ. ការវាយតប់គ្នា និងការសំឡុតបំពាននៅក្នុងសាលារៀន | មធ្យម |
| ង. សំរាម | មធ្យម |
| ច. បង្គន់អនាម័យមិនស្អាត | មធ្យម |
| ឆ. ការខ្វះបន្ទប់រៀន (ថ្នាក់គួប) | ទាប |
| ជ. ការលួចចំឡងពេលធ្វើតេស្ត ឬការប្រឡង | ទាប |
| ឈ. ការវាយបំផ្លាញទ្រព្យសម្បត្តិសាធារណៈ | ទាប |
| ញ. ការលួចសម្ភារៈគ្នា (តាមធម្មតា សម្ភារៈការិយាល័យ) | ទាប |
| ដ. ការសេពគ្រឿងស្រវឹង | ទាប |

***បញ្ហារបស់សាលារៀន ៖ បទពិសោធន៍របស់តំណាង NGO***

ដោយផ្អែកលើបទពិសោធន៍របស់ពួកគាត់ដែលធ្វើការជាមួយសាលារៀន តំណាង NGO បានរាយ-ការណ៍ថា មានបញ្ហាជាច្រើននៅក្នុងសាលារៀនដែលថ្នាក់ដឹកនាំរបស់សាលារៀន ត្រូវមានអំណាចក្នុងការដោះ-ស្រាយ ប៉ុន្តែជារឿយៗតែងតែជួបបរាជ័យក្នុងការធ្វើដូច្នោះ។ បញ្ហាទី១ និងសំខាន់បំផុតដែលគេបញ្ជាក់នោះគឺការបាត់ម៉ោងបង្រៀនតាមរយៈអវត្តមានរបស់គ្រូបង្រៀន និងសិស្ស។ អ្នកឆ្លើយតបមានអារម្មណ៍ថា សាលារៀនត្រូវមានគណនេយ្យភាពច្រើនថែមទៀតចំពោះការដោះស្រាយបញ្ហាដ៏សំខាន់នេះ។ ការបាត់ម៉ោងបង្រៀនបណ្តាលឲ្យពេលវេលានៃការរៀនសូត្រមានរយៈពេលកាន់តែខ្លីសម្រាប់សិស្ស ដែលបន្ទាប់មកនឹងមានផលប៉ះ-ពាល់មិនល្អទៅលើលទ្ធផលនៃការសិក្សារបស់ពួកគេ។ ទោះជាយ៉ាងនេះក្តី អ្នកចូលរួមពុំបានសង្កេតមើលពីវិធានការនានាក្នុងការដាក់ពិន័យផ្នែកការសិក្សា ឬវិជ្ជាជីវៈប្រឆាំងនឹងអវត្តមានរបស់គ្រូបង្រៀនទេ។ ពួកគាត់ក៏បានរាយការណ៍ផងដែរថា គ្រូបង្រៀនមួយចំនួនពុំបានយកចិត្តទុកដាក់ចំពោះម៉ោងបង្រៀននៅក្នុងសាលារៀនរបស់រដ្ឋទេ ប៉ុន្តែផ្តោតការយកចិត្តទុកដាក់ទៅលើការបង្រៀនថ្នាក់ក្រៅម៉ោងទៅវិញ ដើម្បីទទួលបានប្រាក់ចំណូលបន្ថែម។ ដោយសារប្រាក់បៀវត្សរ៍ទាប គ្រូបង្រៀនមួយចំនួនមានការងារក្រៅម៉ោង ឬគិតថ្លៃក្រៅផ្លូវការពីសិស្ស។ ចំពោះបញ្ហារបស់សិស្សវិញ តំណាង NGO បានរាយការណ៍ថា សិស្សមួយចំនួនបានអវត្តមាន ឬគេចសាលារៀនដោយសារសិស្សខ្លះត្រូវជួយក្រុមគ្រួសាររបស់ខ្លួន ដើម្បីកេប្រាក់ចំណូលបន្ថែមទៀតសម្រាប់ការរស់នៅ។ គុណភាពអប់រំគឺជាបញ្ហាទូទៅមួយផ្សេងទៀតរបស់អ្នកឆ្លើយតបរបស់ NGO ដែលមានអារម្មណ៍ថា សិស្សជាច្រើនពុំចេះអាន ឬធ្វើលំហាត់គណិតវិជ្ជាសាមញ្ញឲ្យបានត្រឹមត្រូវទេ។ ជាងនេះទៅទៀត អ្នកឆ្លើយតបបានបញ្ជាក់ជារឿយៗថា សាលារៀនពុំមានគណនេយ្យភាពចំពោះភារកិច្ចរបស់ខ្លួន ពួកគាត់ពុំឲ្យសហគមន៍ចូលរួម

នៅក្នុងការជួយរៀបចំផែនការសកម្មភាពរបស់សាលារៀន និងត្រួតពិនិត្យមើលការចំណាយរបស់សាលារៀនទេ។ ហេតុដូច្នេះហើយ សហគមន៍បានបាត់បង់ការប្រាស្រ័យទាក់ទងជាមួយសាលារៀន។

***ការទទួលខុសត្រូវចំពោះនាទីកិច្ចនៃការបំពេញការងាររបស់សាលារៀន***

នៅពេលគេសួរអំពីទស្សនៈរបស់ពួកគាត់ថា តើអ្នកណាជាភាគីដែលពាក់ព័ន្ធសំខាន់ដែលទទួលខុសត្រូវ ចំពោះភារកិច្ចនៃការបំពេញការងារជាក់លាក់របស់សាលារៀន នាយកសាលាបានផ្តល់នូវការយល់ឃើញខុសៗគ្នា។ នាយកសាលាដូចដែលបានបង្ហាញនៅក្នុងតួលេខទី១៨ បានរាយការណ៍ថា មន្ទីរអប់រំខេត្ត (PoE) និងការិយាល័យអប់រំស្រុក (DoE) គឺជាអ្នកទទួលខុសត្រូវចំបងចំពោះភារកិច្ចនានាដូចជា ការជ្រើសរើសគ្រូបង្រៀនថ្មី ការបណ្តេញគ្រូបង្រៀនចេញការកំណត់ប្រាក់បៀវត្សរ៍របស់គ្រូបង្រៀន និងការកំណត់គម្រោងប្រាក់បៀវត្សរ៍របស់គ្រូបង្រៀន។ សាលារៀនពុំមានគណនេយ្យភាពចំពោះភារកិច្ចទាំងនោះទេ។ ទិន្នន័យបង្ហាញថា នាយកសាលា និងសមាជិក SSC មានគណនេយ្យភាពចំពោះការរៀបចំផែនការហិរញ្ញវត្ថុ ការសម្រេចចិត្តលើការចំណាយរបស់សាលារៀន ការកំណត់ពីទស្សនៈវិស័យ និងបេសកកម្មរបស់សាលារៀន ព្រមទាំងការបង្កើតផែនការសកម្មភាពប្រចាំឆ្នាំរបស់សាលារៀន។ ភារកិច្ចចំបងៗដែល នាយកសាលាត្រូវចងចាំក្នុងចិត្តសម្រាប់ការទទួលខុសត្រូវច្រើនថែមទៀតគឺទាក់ទងនឹងការចុះឈ្មោះចូលរៀនរបស់សិស្ស និងការរៀបចំរបាយការណ៍ស្តីពីការបំពេញការងាររបស់សាលារៀន។ នៅពេលដែលគេសួរអំពីភារកិច្ចនានាទាក់ទងនឹងការបង្កើតបទបញ្ជាផ្ទៃក្នុងរបស់សាលារៀន គោលនយោបាយនៃការវាយតម្លៃសាលារៀន និងការត្រួតពិនិត្យការរៀនសូត្ររបស់សិស្ស នាយកសាលាបានចង្អុលទៅរកតួនាទីរបស់ខ្លួន ដោយមានការគាំទ្រពីគ្រូបង្រៀនក្នុងការពិភាក្សាពីអ្វីដែលគេចាំបាច់ត្រូវធ្វើដើម្បីជួយដល់ការរៀនសូត្ររបស់សិស្ស។ តាមការរាយការណ៍ MoEYS មានគណនេយ្យភាពចំពោះការជ្រើសរើសសៀវភៅបង្រៀនជាមូលដ្ឋាន ការរៀបចំបង្កើតខ្លឹមសារបង្រៀនសម្រាប់ថ្នាក់នីមួយៗ ការសម្រេចចិត្តទៅលើប្រធានបទនានាដែលគេត្រូវបង្រៀន និងការកំណត់ថវិកាសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន។ ជារួមការពិតដែលថា ភាគីដែលពាក់ព័ន្ធខុសៗគ្នា ត្រូវបានគេយល់ឃើញថា ជាអង្គភាពដែលមានការទទួលខុសត្រូវចំពោះការបំពេញការងាររបស់សាលារៀនទំនងជាចង្អុលបង្ហាញថា សាលារៀនគ្រាន់តែមានគណនេយ្យភាពភារកិច្ចដែលមានកម្រិតប៉ុណ្ណោះ។ ដោយផ្អែកទៅលើលក្ខណៈនៃការទទួលខុសត្រូវរបស់ពួកគាត់ សាលារៀនដើរតួនាទីច្រើនថែមទៀតនៅក្នុងការអនុវត្តន៍ជាជាងការធ្វើជាអ្នកផ្តួចផ្តើមគំនិតទៅលើការបំពេញការងារផ្ទាល់របស់ខ្លួន។




*តួលេខទី១៨ ៖ ការទទួលខុសត្រូវចំពោះភារកិច្ចនៃការបំពេញការងាររបស់សាលារៀន*

## ការបោះពុម្ពផ្សាយរបាយការណ៍របស់សាលារៀន

សំណួរជាច្រើនត្រូវបានគេសួរទៅដល់សមាជិក SSC ដើម្បីសិក្សាស្វែងយល់ពីរបៀបដែលសាលារៀននានា បំពេញការងារក្នុងការធានាបាននូវគណនេយ្យភាពរបស់សាលារៀន និងសង្គម។ លទ្ធផលដែលបានពីការសម្ភាសន៍បង្ហាញថា តាមរបាយការណ៍សាលារៀនបានបោះពុម្ពផ្សាយនូវរបាយការណ៍ស្តីពីការបំពេញការងាររបស់សាលារៀនសម្រាប់សាធារណៈជន ខណៈដែលសមាជិក SSC ប្រហែល២០% ហាក់ដូចជាពុំបានដឹងអំពីរបាយការណ៍របស់សាលារៀនទេ ដោយចង្អុលបង្ហាញថា សាលារៀនពុំបានចេញផ្សាយរបាយការណ៍ស្តីពីការបំពេញការងាររបស់សាលារៀនជាសាធារណៈឡើយ។ ចំណុចនេះបញ្ជាក់ថា ទំនាក់ទំនងសាលារៀនសហគមន៍នៅតាមសាលារៀនមួយចំនួនអាចជាបញ្ហាមួយ។ ចំណុចនេះមានសង្គតភាពជាមួយលទ្ធផលដែលបានពីការសម្ភាសន៍ជាមួយតំណាង NGO និងការពិភាក្សាជាក្រុមជាមួយសិស្ស។ តំណាង NGO បានពន្យល់បន្ថែមទៀតថា ជាទូទៅរបាយការណ៍ត្រូវបានគេរៀបចំឡើងសម្រាប់ PoE និង DoE ដែលតម្រូវឲ្យសាលារៀនផ្ញើរបាយការណ៍ទៅតាមកាលបរិច្ឆេទជាក់លាក់។ ឪពុកម្តាយ និងសហគមន៍ ពុំដែលបានដឹងថា តើមានអ្វីកំពុងកើតឡើងនៅក្នុងសាលារៀនទេ ជាពិសេសថា តើសាលារៀនសម្រេចបានផែនការដែលជាចំណុចដៅរបស់ខ្លួនដែរឬអត់ និងថា តើមានការប្រឈមមុខអ្វីខ្លះនៅក្នុងការអនុវត្តផែនការនោះ។




តួលេខទី១៩ ៖ *ការបោះពុម្ពផ្សាយនូវរបាយការណ៍ស្តីពីការបំពេញការងាររបស់សាលារៀនតាមការយល់ឃើញរបស់ SSCs*

អ្នកចូលរួមមួយចំនួននៅខាងក្រៅក្រុម SSC ក៏ត្រូវបានគេបញ្ចូលនៅក្នុងការសិក្សានេះដែរ។ លទ្ធផលបានផ្តល់នូវការចាប់អារម្មណ៍ខ្លះៗទាក់ទងនឹងបទពិសោធន៍ និងការយល់ឃើញទាក់ទងនឹងចំណេះដឹងរបស់ពួកគាត់អំពីការបំពេញការងាររបស់សាលារៀន។ អ្នកចូលរួមដែលជាសហគមន៍ស្ទើរតែពាក់កណ្តាលដែលត្រូវបានគេដាក់បញ្ចូលនៅក្នុងគម្រោងនៃការស្រាវជ្រាវនេះ បានរាយការណ៍ថា ពួកគាត់ពុំមានព័ត៌មានស្តីពីសកម្ម-ភាពរបស់សាលារៀនទេ (សូមមើលតួលេខទី២០)។ បើតាមសេចក្តីរាយការណ៍សាលារៀនពុំបានរាយការណ៍ឲ្យបានទូលំទូលាយដល់សហគមន៍របស់ខ្លួនឡើយ។ ការរកឃើញនេះហាក់ដូចជាផ្ទុយពីអ្វីដែលពិពណ៌នាដោយសមាជិក SSC ដែល៧៧% នៃពួកគាត់បានរាយការណ៍ថា សាលារៀនមានគណនេយ្យភាពចំពោះការងាររបស់ខ្លួនតាមរយៈការចេញផ្សាយនូវរបាយការណ៍នានា ស្តីពីការបំពេញការងាររបស់សាលារៀនដល់សាធារណៈជនទូទៅ (សូមមើលតួលេខទី១៩)។ ភាពខុសគ្នាមួយដូចនេះបញ្ជាក់ថាមានគម្លាតមួយផ្នែកព័ត៌មាន និងការទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ទាំងមូល ចំណែកឯការប្រាស្រ័យទាក់ទងគ្នាវិញហាក់ដូចជានៅមានកម្រិតនៅឡើយនៅក្នុងផ្នែកនៃការប្រាស្រ័យទាក់ទងរបស់សាលារៀន និង SSC។




តួលេខទី២០៖ *ការបោះពុម្ពផ្សាយរបាយការណ៍ស្តីពីការបំពេញការងាររបស់សាលារៀនសម្រាប់សាធារណជនទូទៅ តាមការយល់ឃើញរបស់សមាជិកមិនមែន SSC*

### *ការបំពេញការងាររបស់សាលារៀនតាមការយល់ឃើញរបស់ SSC និងអ្នកដែលមិនមែន SSC*

នៅពេលដែលគេសាកសួរអំពីការបំពេញការងាររបស់សាលារៀន សមាជិក SSC បានបង្ហាញនូវការបំពេញ ការងារជាវិជ្ជមានក្នុងចំណោមសាលារៀន និងនាយកសាលា។ ដូចដែលបានបង្ហាញនៅក្នុងតួលេខទី ២១ គេបានរាយការណ៍ថា ទោះបីជាមិនជានិច្ចកាលក៏ដោយ នាយកសាលា និងគណៈគ្រប់គ្រងសាលារៀនជារឿយៗយល់ពីតួនាទី និងភារកិច្ចរបស់ខ្លួនចំពោះដំណើរការនៅក្នុងសហគមន៍ និងសង្គមរបស់ខ្លួន។ សមាជិក SSC ក៏បានបញ្ជាក់ផងដែរថា ជារឿយៗសាលារៀនបានរៀបចំយុទ្ធសាស្ត្រនានាដើម្បីជួយសិស្សក្រីក្រ ឬ រៀនខ្សោយ និងបានខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ការរៀនសូត្ររបស់សិស្ស។ ពួកគាត់ ក៏បានរាយការណ៍ផងដែរថា សាលារៀនមានការសប្បាយចិត្តក្នុងការធ្វើការជាមួយសហគមន៍ និងទទួលសំណូមពរពីសហគមន៍ ជាពិសេសពីឪពុកម្តាយរបស់សិស្ស។ នេះជាការចង្អុលបង្ហាញល្អមួយថា ការតភ្ជាប់សាលារៀន-សហគមន៍នឹងជួយកែលម្អការបំពេញការងាររបស់សាលារៀនឲ្យដល់កម្រិតល្អមួយ។




តួលេខទី២១ ៖ *អំពីការបំពេញការងាររបស់សាលារៀន តាមការយល់ឃើញរបស់SSC*

ទស្សនៈរបស់អ្នកមិនមែនជាសមាជិក SSC ចំពោះការបំពេញការងាររបស់សាលារៀនហាក់ដូចជាមានចម្រុះគ្នា។ ដូចដែលតួលេខទី២២ បង្ហាញ អ្នកចូលរួមដែលមិនមែនជាសមាជិក SSC ប្រមាណ២ភាគ៣បានរាយការណ៍ថា សាលារៀនតែងតែដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនចំពោះសហគមន៍ និងសង្គមជានិច្ច។ ក្នុងពេលទន្ទឹមគ្នានោះដែរ សហគមន៍បានឲ្យតម្លៃជាវិជ្ជមានចំពោះការខិតខំប្រឹងប្រែងរបស់សាលារៀនក្នុងការលើកកម្ពស់ការរៀនសូត្ររបស់សិស្ស។ ទោះជាយ៉ាងណាក៏ដោយ ពួកគាត់ហាក់ដូចជាមានការយល់ឃើញខុសគ្នាខ្លះៗចំពោះសាលារៀនទាក់ទងនឹងការខិតខំប្រឹងប្រែងរបស់សាលារៀន ក្នុងការទទួលយកសំណូមពរនានាពីសហគមន៍ និងក្នុងការបង្កើតយុទ្ធសាស្ត្រផ្សេងៗ ដើម្បីជួយដល់សិស្សក្រីក្រក្នុងសហគមន៍។ លទ្ធផលទាំងនេះឆ្លុះបញ្ចាំងឲ្យឃើញនូវដំណើរការដែលមានកម្រិតរបស់សាលារៀននៅក្នុងសហគមន៍ តាមរយៈការបញ្ជាក់ថាសាលារៀនដើរតួនាទីមួយដែលស្ថិតនៅក្នុងដែនកំណត់នៃបញ្ហា ដែលមានស្រាប់នៅក្នុងបរិវេណរបស់សាលារៀនប៉ុណ្ណោះដែលក្នុងវិសាលភាពមួយចំនួនកាត់ផ្តាច់ខ្លួនឯងចេញពីក្រុមសិស្ស ឬកុមារដែលងាយរងគ្រោះនៅក្នុងសហគមន៍ជាទូទៅ។ ទស្សនៈរបស់អ្នកមិនមែនជា SSC ហាក់ដូចជាមានភាពខុសគ្នាពីអ្វីដែលសមាជិក SSC បានរាយការណ៍ជាទូទៅពីខាងដើមចំពោះការពិតដែលថា សាលារៀនបានដើរតួនាទីយ៉ាងសកម្មមួយនៅក្នុងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ក្នុងការទទួលយកសំណូមពរ ឬព័ត៌មានត្រលប់ស្តីពីការបំពេញការងាររបស់សាលារៀន និងការជួយសិស្សក្រីក្រ ទោះបីជាភាពខុសគ្នានេះមិនមានវិសាលភាពធំធេង

ក៏ដោយ។ ភាពខុសគ្នាទាំងនេះចំពោះការឲ្យតម្លៃនេះអាច បញ្ជាក់ថាអ្នកដែលមិនមែនជា SSC ពុំមានការយល់ដឹងដ៏ប្រសើរមួយពីការបំពេញការងាររបស់សាលារៀន នៅក្នុងសហគមន៍ដូចក្រុម SSC ទេ ដែលជាការរកឃើញមួយដែលធ្វើឲ្យការអនុវត្តជាក់ស្តែងចំពោះការលើកកម្ពស់ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ស្ថិតនៅក្នុងចំណោទមួយ។




តួលេខទី២២ ៖ *អំពីការបំពេញការងាររបស់សាលារៀន តាមរយៈការយល់ឃើញរបស់អ្នកមិនមែនSSC*

### *ការពេញចិត្តចំពោះការបំពេញការងាររបស់សាលារៀន*

SSCs ក៏ត្រូវបានគេស្នើសុំឲ្យកំណត់អត្រានៃការពេញចិត្តរបស់ខ្លួនចំពោះភារកិច្ចបំពេញការងារមួយចំនួន។ លទ្ធផលនានាបង្ហាញថា ជាទូទៅ SSCs ពេញចិត្តចំពោះការបំពេញការងាររបស់សាលារៀននៅក្នុងសហគមន៍របស់ខ្លួន(សូមមើលតួលេខទី២៣)។ ទោះជាយ៉ាងណាក៏ដោយ កម្រិតនៃការពេញចិត្តរបស់ពួកគាត់មានកម្រិតខ្ពស់ទៅលើការចំណាយរបស់សាលារៀន និងការខិតខំប្រឹងប្រែងក្នុងការប្រមូលកុមារដែលគ្រប់អាយុចូលរៀនឲ្យមកចុះឈ្មោះចូលរៀន។ វាហាក់ដូចជាថា ភារកិច្ចចំបងទាំងពីរនេះមានការចាប់អារម្មណ៍ និងឲ្យតម្លៃយ៉ាងខ្លាំងពីសំណាក់សហគមន៍បើប្រៀបធៀបជាមួយនឹងសកម្មភាពផ្សេងៗទៀតរបស់សាលារៀន នេះគឺជាភស្តុតាងមួយដោយសារការកាត់បន្ថយការបោះបង់ការរៀនសូត្ររបស់សិស្ស ក៏ត្រូវបានគេកំណត់អត្រាខ្ពស់ដែរនៅក្នុងចំណោមសកម្មភាពផ្សេងៗទៀត។




តួលេខទី២៣ ៖ *ការពេញចិត្តចំពោះការបំពេញការងាររបស់សាលារៀន តាមការយល់ឃើញរបស់ SSC*

នៅពេលដែលគេសួរអំពីការពេញចិត្តរបស់ខ្លួនចំពោះការបំពេញការងាររបស់សាលារៀននៅក្នុងសហគមន៍ របស់ពួកគាត់ អ្នកចូលរួមដែលមិនមែនជា SSC មានទស្សនៈដូចគ្នានឹងសមាជិក SSC ដែរថា ពួកគាត់មានការពេញចិត្តជាខ្លាំងជាមួយនឹងការចំណាយរបស់សាលារៀន ការខិតខំប្រឹងប្រែងរបស់សាលារៀនក្នុងការប្រមូលកុមារគ្រប់អាយុចូលរៀន និងការកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស។ ពួកគាត់ក៏បានលើកឡើងដែរថា ឪពុកម្តាយក៏បានបង្ហាញនូវការគាំទ្រយ៉ាងខ្លាំងក្លាចំពោះដំណើរការរបស់សាលារៀននៅក្នុងសហគមន៍ និងមានការពេញចិត្តជាមួយនឹងអត្តចរិករបស់កូនៗរបស់គាត់បន្ទាប់ពីពួកគាត់បានបញ្ជូនពួកគេទៅសាលារៀន(សូមមើលតួលេខទី២៤)។

នៅក្នុងការពិភាក្សាជាក្រុមជាមួយសិស្សមកពី១២សាលា ពួកគេក៏មានការពេញចិត្តចំពោះសាលារៀនរបស់ខ្លួនដែរ។ សិស្សទាំងអស់បានឯកភាពថា សាលារៀនរបស់ពួកគេបានជួយពួកគេក្នុងការរៀនសូត្រ។ ទោះជាយ៉ាងណាក៏ដោយ មធ្យោបាយដែលសាលារៀនបានជួយមានលក្ខណៈខុសគ្នាបន្តិចបន្តួចពីសាលារៀនមួយទៅសាលារៀនមួយទៀត។ យោងតាមសិស្សទាំងអស់នោះ សាលារៀនបង្រៀនពួកគេនូវចំណេះដឹង (បង្រៀនពួកគេឲ្យអាន សរសេរ គណនា របៀបរស់នៅក្នុងសង្គម) និងប្រកាន់ខ្ជាប់នូវវិន័យខ្ពស់សម្រាប់បរិស្ថានរៀនសូត្រល្អ (ដោះស្រាយជម្លោះរបស់សិស្ស ដាក់ទណ្ឌកម្មចំពោះអ្នកទាំងឡាយណាដែលល្មើសច្បាប់ ឬវិន័យរបស់សាលារៀន ពង្រឹងក្រុមទាក់ទងនឹងឯកសណ្ឋានរបស់សាលារៀន បង្កើតទំនាក់ទំនងយ៉ាងរឹងមាំក្នុងចំណោមសិស្ស បុគ្គលិករបស់សាលារៀន និងសហគមន៍ ទាក់ទងឪពុកម្តាយនៅពេលសិស្ស អវត្តមាន ផ្តល់បរិយាកាសដែលមានសុវត្ថិភាព ។ល។) ពួកគេគូសបញ្ជាក់ថា គ្រូបង្រៀនរបស់ពួកគេយកចិត្តទុកដាក់លើការរីកចម្រើននៃការសិក្សា ហើយពួកគាត់បានពន្យល់អ្វីដែលមិនច្បាស់ទៅដល់សិស្សដែលរៀនយឺត យកចិត្តទុកដាក់ចំពោះសិស្ស ព្រមទាំងរាយការណ៍ពីការរីកចម្រើននៃការរៀនសូត្ររបស់សិស្សទៅដល់ឪពុកម្តាយរបស់គេ ដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ និងពិនិត្យមើលការរៀនសូត្ររបស់ពួកគេ ទោះបីជាប្រាក់បៀវត្សរ៍របស់ពួកគាត់តិចក៏ដោយ។

ទោះជាយ៉ាងណាក៏ដោយ សិស្សទាំងនោះបានស្នើសុំឲ្យសាលារៀនកែលម្អបន្ថែមទៀតនូវដំណើរការរបស់ខ្លួនដើម្បីជួយសិស្សឲ្យរៀនបានកាន់តែប្រសើរថែមទៀត។ ទី១ សាលារៀនចាំបាច់ត្រូវរក្សាវិន័យសិស្សឲ្យបានតឹងរ៉ឹង។ សិស្សត្រូវការបរិស្ថានរៀនសូត្រដែលមានអនាម័យ និងសុវត្ថិភាព ពោលគឺកន្លែងដែលពុំមានការសំឡុតបំពាន និងការវាយតប់គ្នា។ គេគួរកត់សំគាល់ថា សិស្សជាច្រើនបានរាយការណ៍ថា ការសំឡុតបំពាន និងការវាយតប់គ្នាគឺជារឿងទូទៅមែនទែននៅតាមសាលារៀនក្នុងពេលបច្ចុប្បន្ននេះ។ សិស្សទាំងអស់នោះក៏ចង់ឲ្យគ្រូបង្រៀនរបស់ខ្លួនបំពេញភារកិច្ចរបស់គាត់ឲ្យបានត្រឹមត្រូវ និងជៀសវាងអវត្តមានច្រើន។ ពួកគេបាននិយាយថា គ្រូបង្រៀនមួយចំនួនមិនគួរផ្តោតការយកចិត្តទុកដាក់តែទៅលើសិស្សដែលជាអ្នកមាន ឬល្អ ដោយទុកចោលសិស្សក្រីក្រ និងខ្ជិលទេ។ សិស្សមួយចំនួនចង់ឲ្យសាលារៀនរបស់ខ្លួនបង្កើតកម្មវិធីមួយដើម្បីជួយអ្នករៀនយឺត។ ក្នុងពេលជាមួយគ្នានេះដែរ ពួកគេចង់ឲ្យសាលារៀនរបស់ពួកគេលើកទឹកចិត្តសិស្សឲ្យធ្វើស្វ័យសិក្សា និងស្រាវជ្រាវ ដូចជាការទៅបណ្ណាល័យជាដើម ដោយសារពួកគាត់ មិនចាប់អារម្មណ៍នឹងការអនុវត្តដាក់ស្តែងនូវវិធីសាស្ត្រក្នុងការបង្រៀន និងរៀនបច្ចុប្បន្ននេះទេ។ ធនធាន សម្រាប់បង្រៀន និងរៀនច្រើនថែមទៀត ដូចជាសៀវភៅអានសៀវភៅសម្រាប់បណ្ណាល័យ និងបន្ទប់ពិសោធន៍ចាំបាច់ត្រូវផ្គត់ផ្គង់ឲ្យដល់សាលារៀនដើម្បីឲ្យសិស្សបានរៀនសូត្រ។ ជាចុងក្រោយ សិស្សបានផ្តល់អនុសាសន៍ថា SSCs គួរមានដំណើរការប្រសើរជាងនេះនៅតាមសាលារៀនក្នុងគោលបំណងជួយឲ្យសាលារៀនមានដំណើរការល្អ លើកកម្ពស់សុវត្ថិភាពរបស់សាលា

រៀន និងលុបបំបាត់ការបំផ្លាញទ្រព្យសម្បត្តិសាធារណៈ។ នៅក្នុងន័យនេះ ពួកគាត់អាចមកសាលារៀន និងផ្តល់ដំបូន្មានដល់ពួកគេដើម្បីឲ្យការរៀនសូត្ររបស់សិស្សបានកាន់តែប្រសើរឡើង។




*តួលេខទី២៤៖ ការពេញចិត្តចំពោះការបំពេញការងាររបស់សាលារៀន តាមការយល់ឃើញរបស់សមាជិក សហគមន៍ដែលមិនមែនជាសមាជិក SSC*

ដោយផ្អែកលើបទពិសោធន៍នៃការធ្វើការងារជាមួយសាលារៀន អ្នកឆ្លើយតបរបស់ NGO បានឯកភាពថា មានសកម្មភាពមួយចំនួនដែលសាលារៀនបំពេញបានល្អ ព្រមទាំងមានតួនាទី និងការទទួលខុសត្រូវសំខាន់ៗមួយចំនួនដែលសាលារៀនខកខានមិនបានបំពេញដែរ។ ទី១ សាលារៀនមានលទ្ធភាពរៃអង្គាស មូលនិធិដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងថែរក្សាបន្ទប់រៀន ឬអគាររបស់សាលារៀន ត្រួតពិនិត្យតាមដានគ្រូបង្រៀន រៀបចំការប្រជុំរៀងរាល់២ខែ ឬត្រីមាសជាមួយឪពុកម្តាយរបស់សិស្ស សម្របសម្រួលជាមួយនគរបាលមូលដ្ឋាន និងក្រុមប្រឹក្សាឃុំដើម្បីទប់ស្កាត់អំពើហិង្សានៅក្នុងសាលារៀនអនុវត្តយុទ្ធនាការ ដើម្បីផ្សព្វផ្សាយពីការចុះឈ្មោះចូលរៀន និងកាត់បន្ថយអត្រាបោះបង់ការសិក្សា ធ្វើកិច្ចការរដ្ឋបាលមួយចំនួន រៀបចំព្រឹត្តិការណ៍ផ្សេងៗ ជម្រុះដំណើរការលទ្ធកម្ម និងរៀបចំផែនការការងារប្រចាំឆ្នាំ។ ទោះជាយ៉ាងនេះក្តី នាយកសាលាភាគច្រើនពុំបានដឹងពីមូលដ្ឋាននៃ *ការគ្រប់គ្រងសាលារៀន* និង *ភាពជាអ្នកដឹកនាំទេ*។ អ្នកផ្តល់បទសម្ភាសន៍ភាគច្រើនមានការព្រួយបារម្ភពីតម្លាភាពផ្នែកហិរញ្ញវត្ថុនៅក្នុងសាលារៀន។ នាយកសាលាពុំដែលបានរាយកាណ៍ពីថវិកាដែលមាន និងការចំណាយផ្សេងៗដល់បុគ្គលិក និងសហគមន៍ឡើយ។ ចំណុចបញ្ហាមួយផ្សេងទៀតគឺថាសាលារៀនពុំមានលទ្ធភាពគ្រប់គ្រងលើការងារគ្រប់គ្រងបុគ្គលិកទេ។ សាលារៀនពុំមានអំណាចក្នុងការចាត់វិធានការវិន័យប្រឆាំងនឹងគ្រូបង្រៀនដែលបំពេញការងារមិនបានល្អ គ្រូបង្រៀនទាំងឡាយណាដែលអវត្តមាន ឬមកយឺតជាញឹកញាប់ គ្រូបង្រៀនទាំងឡាយ ណាដែលយកកម្រៃសេវាកម្មក្រៅផ្លូវការពីសិស្ស និងគ្រូបង្រៀនទាំងឡាយណាដែលអនុវត្តផ្ទុយទៅនឹង ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជា។

ក្នុងគោលបំណងឲ្យសាលារៀនបំពេញការងារដោយឯករាជ្យ លទ្ធផលនានាបានបង្ហាញថា សាលារៀនចាំបាច់ត្រូវមានឯករាជ្យភាព និងស្វ័យភាពពេញលេញ ហើយសាលារៀនត្រូវបំពេញភារកិច្ចរបស់ខ្លួនឲ្យមានតម្លាភាព។ គេត្រូវការឯករាជ្យភាព និងស្វ័យភាពទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ការជ្រើសរើសនិងការគ្រប់គ្រងបុគ្គលិក ការសម្រេចចិត្តលើសកម្មភាព សម្ភារៈ និងដំណើរការបង្រៀន និងរៀន ផែនការអភិវឌ្ឍ

សាលារៀន និងកិច្ចការផ្សេងៗទៀត។ តម្លាភាពនឹងធ្វើឲ្យសហគមន៍ចូលរួមយ៉ាងសកម្មនៅក្នុងការងាររបស់សាលារៀនដូចជា ការចំណាយផ្សេងៗ ចំណូល ដំណើរការបង្រៀននិងរៀន និងសកម្មភាពផ្សេងៗទៀតរបស់សាលារៀន។ នៅក្នុងន័យនេះ សាលារៀនត្រូវទទួលបាននូវការជឿទុកចិត្តពីសហគមន៍ ហើយការប្រាស្រ័យទាក់ទងនឹងមានការកែលម្អរវាងសាលារៀន និងសហគមន៍។ ចំណុចនេះមានសំខាន់ណាស់ចំពោះជោគជ័យរបស់សាលារៀននៅក្នុងប្រទេសកម្ពុជា ហើយវាជាលក្ខណៈមួយក្នុង ចំណោមលក្ខណៈសម្បត្តិនានាដែលបានបាត់បង់នៅតាមសាលារៀនរបស់ប្រទេសកម្ពុជា។

*បញ្ហាប្រឈម*

ពុំមានការប្រកែកថា វត្តមានរបស់ SSC បង្ហាញនូវការវិវឌ្ឍមួយចំពោះប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជាឆ្ពោះ ទៅរកគណនេយ្យភាពរបស់សាលារៀន និងសង្គមទេ។ អង្គការគាំទ្រនេះពិតជាដើរតួនាទីជាមូលដ្ឋានមួយនៅក្នុងការតភ្ជាប់ទំនាក់ទំនងរបស់សាលារៀន និងសហគមន៍។ ការចូលរួមរបស់សហគមន៍ដែលមានការកើនឡើងគឺជាអ្វីដែលប្រព័ន្ធត្រូវការក្នុងគោលបំណងធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងការគ្រប់គ្រង ដោយផ្អែកលើសាលារៀន និងដើម្បីកែលម្អប្រសិទ្ធិភាព និងប្រសិទ្ធិផលនៃការបំពេញការងាររបស់សាលារៀន។ ទោះជាយ៉ាងណាក៏ដោយ ខណៈដែលរឿងប្រកបដោយជោគជ័យផ្សេងៗ ត្រូវបានគេទទួលស្គាល់តាមរយៈរបាយការណ៍ ក៏នៅមានការប្រឈមមុខយ៉ាងច្រើនមួយដែលគេចាំបាច់ត្រូវយកចិត្តទុកដាក់ទាំងនៅក្នុងគោលនយោបាយ និងការអនុវត្តជាក់ស្តែង។ ការឆ្លើយតបនានាពីសំណាក់ភាគីដែលពាក់ព័ន្ធទាំងអស់ (នាយកសាលា SSC អ្នកដែលមិនមែន SSC តំណាង NGO និងសិស្ស) តាមរយៈការសម្ភាសន៍ និងការពិភាក្សាជាក្រុមបង្ហាញថា ការលើកកម្ពស់ការចូលរួមរបស់សហគមន៍នៅតែជាឧបសគ្គដ៏ចំបងមួយ។ ការប្រឈមមុខជាច្រើនត្រូវបានគេចងក្រងជាឯកសារថាជាឧបសគ្គដែលរារាំង SSCs ក៏ដូចជាសហគមន៍ ទាំងមូលមិនឲ្យចូលរួមឲ្យបានសកម្ម និងមានប្រសិទ្ធិភាពនៅក្នុងដំណើរការអភិវឌ្ឍសាលារៀន។

*ការខ្វះការយល់ដឹងរបស់នាយកសាលាទៅលើតួនាទី និងការទទួលខុសត្រូវរបស់ SSC*

ទិន្នន័យដែលបានមកពីមូលដ្ឋានចង្អុលបង្ហាញជាចំបងថា ការខ្វះការចូលរួមរបស់សហគមន៍ ជាពិសេស SSCs គឺទាក់ទងទៅនឹងការខ្វះការយល់ដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ SSCs នៅក្នុងចំណោមនាយកសាលា។ គេបានរាយការណ៍ថា នៅក្នុងករណីភាគច្រើន នាយកសាលាហាក់ដូចជាមានចំណេះដឹងតិចតួចអំពីរបៀបដែល SSC ធ្វើការដើម្បីសាលារៀន និងសហគមន៍។ ការសម្ភាសន៍នានាបានបង្ហាញថា នាយកសាលាថែមទាំងពុំបានដឹងពីការទទួលខុសត្រូវច្បាស់លាស់របស់ SSCs ដែរ។ ជារួម សមាជិក SSC ត្រូវបានគេជ្រើសរើសសម្រាប់គោលបំណងនៃការជួយសាលារៀនឲ្យស្វែងរក ឬ ប្រមូលមូលនិធិដើម្បីគាំទ្រសាលារៀន។ ទោះបីជាតួនាទី និងការទទួលខុសត្រូវរបស់ SSC ត្រូវបានគេបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងសេចក្តីណែនាំសម្រាប់ការបង្កើត SSCs ដែលមានសកម្មភាពជាស្នូលចំនួន៨ចំណុចក៏ដោយ (ការរៀបចំផែនការអភិវឌ្ឍសាលារៀន ការប្រមូលកុមារគ្រប់អាយុឲ្យចូលរៀន ការត្រួតពិនិត្យការរៀនសូត្ររបស់សិស្ស ការរៃអង្គាសមូលនិធិ និងការគ្រប់គ្រងថវិកា ការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន ការចែករំលែកបទពិសោធន៍ និងបំណិនជីវិត ការទប់ស្កាត់ភាពមិនប្រក្រតី និងការកសាងសមត្ថភាព) នាយកសាលាមានទំនោរទៅរកការដាក់កម្រិតតួនាទី និងការទទួលខុសត្រូវរបស់ SSCs នៅក្នុងការអនុវត្តជាក់ស្តែង។ ឧទាហរណ៍តាមដែល SSCs បានរាយការណ៍ នៅក្នុងការអនុវត្តជាក់ស្តែង ការអនុម័តលើផែនការថវិកាគឺគេគ្រាន់តែបញ្ជូន

ទៅឲ្យ SSCs ចុះហត្ថលេខានៅលើរបាយការណ៍ និងផែនការប៉ុណ្ណោះ (ការងាររបស់ពួកគាត់គឺគ្រាន់តែចុះហត្ថលេខាលើឯកសារនានាប៉ុណ្ណោះ)។ ការអនុវត្តជាក់ស្តែងនេះមានផលប៉ះពាល់ទៅលើការចូលរួមរបស់សហគមន៍នៅក្នុងការអនុវត្តការងាររបស់សាលារៀនក្នុងកម្រិតដ៏ធំមួយ។ វិសាលភាពដែលកាន់តែធំទូលាយមួយនៃការចូលរួមពីសំណាក់សហគមន៍នៅក្នុងការជួយសាលារៀនឲ្យ ដំណើរការបានល្អគឺជាចំណោទដ៏ធំមួយ។

### *ការខ្វះការយល់ដឹងរបស់SSCsទៅលើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន*

ការប្រឈមមុខមួយផ្សេងទៀតគឺទាក់ទងនឹងការខ្វះការយល់ដឹងរបស់សមាជិកSSCចំពោះតួនាទី និងការ ទទួលខុសត្រូវរបស់ពួកគាត់។ សមាជិកSSCត្រូវបានគេរាយការណ៍ចំពោះការខ្វះចំណេះដឹងគ្រប់គ្រាន់អំពីថាតើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនទាំងមូល ឬដែលគេកំណត់ឲ្យមានអ្វីខ្លះ។ម្យ៉ាងការសម្ភាសន៍នៅតាមមូលដ្ឋានបានបង្ហាញឲ្យឃើញនូវការខ្វះខាតការបណ្តុះបណ្តាលពីសំណាក់សាលារៀន ឬនាយកសាលាដែលទទួលខុសត្រូវចំពោះគម្លាតដូចនេះនៅក្នុងការយល់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។ ឯម្យ៉ាងទៀត បើតាមសេចក្តីរាយការណ៍ សមត្ថភាពរបស់ពួកគាត់គឺជាចំណោទមួយ។ របៀបដែល SSCs ត្រូវបានគេជ្រើសរើសនឹងពន្យល់ពីចំណុចនេះ។ ជាទូទៅសមាជិក SSC ត្រូវបានគេជ្រើសរើសពីក្នុងចំណោមប្រជាជនដែលមានអំណាច និងសមត្ថភាពតិច ដូចជាកសិករ គ្រូបង្រៀន (ដែលចូលនិវត្តន៍) ក្រុមប្រឹក្សាឃុំ អ្នកបួស/ព្រះសង្ឃ នគរបាល ទាហ៊ាន និងប្រធានភូមិ។ សមាសភាពមួយដូចនេះបង្កឲ្យមានសំណួរដ៏សំខាន់ទៅលើសមត្ថភាពរបស់ពួកគាត់ នៅក្នុងការចូលរួមឲ្យបានសកម្មក្នុងសកម្មភាពអភិវឌ្ឍសាលារៀន។ ឧទាហរណ៍ នៅក្នុងខេត្តកំពង់ចាម សមាជិក SSC មួយចំនួនមិនទាំងចេះអាន និងសរសេរទៀតផង។ ការអប់រំទាបគឺជាឧបសគ្គដ៏ចំបងមួយសម្រាប់ពួកគាត់ក្នុងការផ្តួចផ្តើមគំនិតណាមួយក្នុងការជួយដល់ដំណើរការរបស់សាលារៀន។ ចំណុចនេះគឺជារឿងអកុសលនៅពេលដែលនាយកសាលាពុំបានដឹងឲ្យបានពេញលេញនូវតួនាទី និងការទទួលខុសត្រូវរបស់ SSCs ដែលគេចង់បានទាក់ទងនឹងដំណើរការរបស់សាលារៀន។ ដូចដែល SSC ម្នាក់បានលើកឡើងថា ៖

*“ការងាររបស់ SSC គឺត្រូវធ្វើតាមបញ្ជារបស់នាយកសាលា”។*

ការសម្ភាសន៍បានបង្ហាញបន្ថែមទៀតថា សមាជិក SSC ភាគច្រើនមានវ័យចំណាស់ និងរស់នៅក្នុងបន្ទុករបស់អ្នកដទៃ។ នាយកសាលាបញ្ជាក់ថា សាលារៀនចង់បានសមាជិកដែលមានអំណាច និងរឹងមាំ ប៉ុន្តែសាលារៀនពុំអាចរកបានមនុស្សដូចនោះបានទេ ដោយសារពួកគាត់ពុំបានទទួលនូវគ្រឿងលើកទឹកចិត្តណាមួយចំពោះការងាររបស់ពួកគាត់ឡើយ។ ហេតុដូច្នេះហើយ នាយកសាលាត្រូវបង្ខំចិត្តជ្រើសរើសសមាជិក SSC ប្រភេទនេះ។ នៅតាមសាលារៀនមួយចំនួន សមាជិក SSC ថែមទាំងស្នើសុំឲ្យអ្នកសម្ភាសន៍សុំឲ្យអ្នកថ្មី និងមានវ័យក្មេងមកជំនួសខ្លួនទៀតផង ដោយសារសមត្ថភាពរបស់ពួកគាត់នៅខ្សោយពេកក្នុងការដោះ ស្រាយការងារនេះ។ ហេតុដូច្នេះហើយ ការខ្វះការចូលរួមគឺមានសភាពស្មុគស្មាញដោយសារការខ្វះការយល់ដឹងមួយពីតួនាទី និងការទទួលខុសត្រូវក្នុងចំណោម SSCs ហាក់ដូចជាកាន់តែមានសភាពធ្ងន់ធ្ងរថែមទៀត ដោយសារសមត្ថភាពទាបរបស់ពួកគាត់។ នាយកសាលាម្នាក់បានបន្ថែមទៀតថា ៖

*“សមាជិក SSC ទាំងអស់ពុំដែលបានចូលរួមនៅក្នុងការសង្កេតមើលលើគ្រូបង្រៀន ឬសាលារៀនទេ ដោយ សារពួកគាត់ជឿថា វាមិនមែនជាការកិច្ចរបស់គាត់ ហើយពួកគាត់ក៏ពុំមានបទពិសោធន៍នៅ ក្នុងវិស័យនេះដែរ”។*

### *ការលើកទឹកចិត្ត និងការគាំទ្រពីសហគមន៍ទាប*

ការលើកទឹកចិត្ត (ឲ្យធ្វើជាសមាជិក) និងការផ្តល់ការគាំទ្ររបស់សហគមន៍ដល់ SSCs គឺជាកត្តារួមចំណែក ដែលទប់ស្កាត់ពួកគាត់មិនឲ្យចូលរួមឲ្យបានពេញលេញនៅក្នុងការងាររបស់សាលារៀន និងសហគមន៍។ សមាជិករបស់ SSC បានរាយការណ៍ថា ពួកគាត់ពុំមានទឹកចិត្តធ្វើការងារឲ្យសាលារៀន ឬសហគមន៍របស់ពួកគាត់ទេ ដោយសារការពុំមានគ្រឿងលើកទឹកចិត្ត។ ស្ថានភាពដូចនោះហាក់ដូចជាកាន់តែអាក្រក់ថែមទៀតនៅពេលដែលអ្នកដែលមិនមែនជា SSC ម្នាក់លើកឡើងថា ៖

*"ខ្ញុំគ្រាន់តែជាជាងសំណង់ម្នាក់ប៉ុណ្ណោះ។ ខ្ញុំអាចមានលទ្ធភាពទិញម៉ូតូ។ ក្នុងនាមជានាយក [សាលា] ម្នាក់ អ្នកអាចជិះកង់មួយតែប៉ុណ្ណោះ"។*

ជាងនេះទៅទៀត សមាជិករបស់ SSC ហាក់ដូចជាមានការគាំទ្រតិចតួចពីអាជ្ញាធរដែនដី។ ការសម្ភាសន៍បានគាំទ្រថា អាជ្ញាធរដែនដីពុំបានយកចិត្តទុកដាក់ច្រើនពីការងាររបស់ SSC ទេ ពួកគាត់យកចិត្តទុកដាក់តែពីការងារស្នូលរបស់ពួកគាត់នៅកន្លែងធ្វើការរបស់ពួកគាត់ប៉ុណ្ណោះ។ គេបានរាយការណ៍បន្ថែមទៀតថា តួនាទីរបស់សមាជិកសហគមន៍នៅក្នុងការអប់រំមិនត្រូវគេទទួលយក ឬយល់ឲ្យបានទូលំទូលាយទេ។ ពួកគាត់ចង្អុលបង្ហាញថា សកម្មភាពរបស់សាលារៀនគឺជាការទទួលខុសត្រូវតែឯងរបស់រដ្ឋាភិបាល។ ពួកគាត់ពុំមានការទទួលខុសត្រូវណាមួយក្នុងការអនុវត្តភារកិច្ចទាំងនោះទេ។ ជាផលវិបាកមួយ សហគមន៍មានទំនោរបង្វែរការយកចិត្តទុកដាក់របស់ខ្លួនទៅលើការគាំទ្រសកម្មភាពផ្នែកសាសនាសម្រាប់បុណ្យកុសល ផ្ទាល់របស់ខ្លួនទៅវិញ។

### *បញ្ហានៃការប្រាស្រ័យទាក់ទង និងកិច្ចសហប្រតិបត្តិការ*

ការខ្វះខាតនូវការប្រាស្រ័យទាក់ទង និងកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាពរវាងសាលារៀន និង SSC និងសហគមន៍គឺជាការប្រឈមមុខដ៏ចំបងមួយផ្សេងទៀត។ នាយកសាលាម្នាក់បានបញ្ជាក់ថា "ការងារស្ទើរតែដូចគ្នាដោយសារសមាជិក SSC ពុំបានស្គាល់សូម្បីសមាជិកម្នាក់ៗនៅក្នុងគណៈកម្មការនេះ"។ បើតាមរបាយការណ៍ សាលារៀនមួយចំនួន សូម្បីនៅភ្នំពេញក៏ដោយពុំបានស្គាល់ថែមទៀតផងនូវសមាជិក SSC របស់ខ្លួន។ សមាជិកមួយចំនួនទើបតែដឹងថា ពួកគាត់គឺជាសមាជិករបស់ SSC នៅថ្ងៃដែលអ្នកប្រមូលទិន្នន័យហៅពួកគាត់មក។ ជាងនេះទៅទៀត វាហាក់ដូចជាថា នាយកសាលាពុំបានបង្កើតឲ្យមានការទាក់ទងគ្នាយ៉ាងស្អិតរមួតមួយជាមួយសហគមន៍ទេ ដូចដែលសមាជិកសហគមន៍នេះបានកត់សំគាល់នៅក្នុងការសម្ភាសន៍ ៖

*"សហគមន៍ពុំបានដឹងសូម្បីតែថាតើសាលារៀនចង់បានអ្វី"។*

កិច្ចសហការរវាង SSC និងនាយកសាលាក៏ជាចំណោទមួយដែរ។ ការសម្ភាសន៍តាមមូលដ្ឋាន និងការកត់សំគាល់ផ្សេងៗបញ្ជាក់ថា លំហូរការងារមានតែរវាងប្រធានរបស់ SSC និងនាយកសាលាប៉ុណ្ណោះ។ តាមរបាយការណ៍ សមាជិក SSC ផ្សេងទៀតពុំបានដឹងពីលំហូរការងាររបស់គណៈកម្មការនេះទេ។ សូម្បីតែនៅក្នុងករណីរបស់សាលារៀនវត្តបូព៌ ដែលជាសាលាបឋមសិក្សាគំរូនៅក្នុងប្រទេសកម្ពុជាក៏ដោយ ការងារត្រូវបានគេតម្រង់ទៅរកនាយកសាលា និងប្រធាន SSC ដែលធ្វើឲ្យព័ត៌មានដែលចាំបាច់មួយចំនួនមិនត្រូវបានគេផ្សព្វផ្សាយឲ្យបានទូលំទូលាយទេ។

***ការផ្តល់មូលនិធិ និងការរៃអង្គាសមូលនិធិ***

ការដំណើរការរបស់ SSCs ត្រូវទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារការខ្វះការផ្តល់មូលនិធិ។ ជារួម សមា ជិកSSCបានចូលរួមនៅក្នុងការងាររបស់សាលារៀនដោយឈរលើមូលដ្ឋានស្ម័គ្រចិត្តប៉ុណ្ណោះ។ ប្រសិនបើពុំមានការគាំទ្រណាមួយទេ នោះនឹងមានការគាំទ្រផ្នែកហិរញ្ញវត្ថុតិចតួចប៉ុណ្ណោះពីសាលារៀន។ ហេតុដូច្នេះហើយ បើតាមលក្ខណៈបច្ចេកទេសគឺពុំការផ្តល់មូលនិធិដល់ការងាររបស់ SSCs ទេ។ ហេតុដូច្នេះហើយ ការរៃអង្គាសមូលនិធិគឺជាជម្រើសមួយផ្សេងទៀតសម្រាប់ឲ្យសាលារៀន និងSSCបន្តដំណើរការ។ ដោយសារពួកគាត់ភាគច្រើនមកពីអង្គការសាសនា សមាជិក SSC បានបង្កើតឲ្យមានព្រឹត្តិការណ៍រៃអង្គាសមូលនិធិតាមរយៈពិធីបុណ្យសាសនាដើម្បីទទួលបានការរួមវិភាគទានពីឪពុកម្តាយ និងសមាជិកសហគមន៍ក្នុងគោលបំណងទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍសាលារៀន។ ទោះជាយ៉ាងនេះក្តី SSC រាយការណ៍ថា ៖

*ការរៃអង្គាសមូលនិធិលែងជាការទាក់ទាញការយកចិត្តទុកដាក់ និងការជឿជាក់របស់សហគមន៍ និងឪពុកម្តាយទៀតហើយនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារសហគមន៍មានជីវភាពក្រីក្រពេក និងបានធ្វើចំណាកស្រុកទៅកាន់តំបន់ផ្សេងទៀតនៅក្នុងតំបន់ជនបទ។ ទម្រង់ផ្សេងទៀតនៃការរៃអង្គាសមូលនិធិត្រូវបានធ្វើឡើងតាមរយៈការផ្តល់ស្រោមសំបុត្រដល់ឪពុកម្តាយដើម្បីប្រមូលវិភាគទានមួយចំនួនសម្រាប់ការអភិវឌ្ឍសាលារៀន ការអនុវត្តដែលមានលទ្ធផលផ្លែផ្កាគឺជាចំណោទមួយដោយសារគម្លាតកាន់តែរីកធំឡើងចំពោះការប្រាស្រ័យទាក់ទង និងទំនាក់ទំនងរវាងសាលារៀន និងសហគមន៍។ "បុណ្យផ្កា [3] " មិនមានប្រយោជន៍ទេដោយសារមូលនិធិដែលរៃអង្គាស បានគឺគ្រប់គ្រាន់សម្រាប់តែចំណាយទៅលើម្ហូបអាហារ និងពិធីបុណ្យខ្លួនឯងប៉ុណ្ណោះ។*

ការខ្វះតម្លាភាពក៏បណ្តាលឲ្យមានបញ្ហាមួយដែលទប់ស្កាត់ការចូលរួមរបស់សហគមន៍ផងដែរក្នុងការរៃអង្គាសមូលនិធិដោយសារសាលារៀនពុំបានរាយការណ៍ឲ្យបានជាក់លាក់ពីការចំណាយផ្សេងៗ (តម្លាភាពនៃការងារ និងលទ្ធកម្មរាល់ការចំណាយទាំងអស់)។ លើសពីនេះទៅទៀត សហគមន៍មិនចង់ចូលរួមក្នុងការងាររបស់សាលារៀនទេ ដោយសារគ្រូបង្រៀនបានប្រមូលលុយពីសិស្សរួចទៅហើយ។ ភ្នំពេញគឺជា ឧទាហរណ៍ចំបងមួយនៃការខ្វះការចូលរួមរបស់សហគមន៍ដោយសារហេតុផលនេះ។ ជារួមការទាក់ទាញសហគមន៍ឲ្យចូលរួមផ្តល់មូលនិធិដល់សាលារៀន ឬរៃអង្គាសមូលនិធិបានក្លាយទៅជាបញ្ហាចំបងមួយដែលត្រូវស្វែងរកដំណោះស្រាយសមស្របជាបន្ទាន់ពីគ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់ ចាប់ពីនាយកសាលា ឬ ចាប់ពីសមាជិក SSC ឡើងទៅ។

***ការប្រតិបត្តិល្អរបស់ SSC ៖ករណីរបស់សាលារៀនចំនួន២***

តាមរបាយការណ៍ ទោះបីជាសាលារៀននៅតាមតំបន់ខុសៗគ្នានៅក្នុងការសិក្សានេះមានកម្រិតនៃការចូលរួមរបស់សហគមន៍ទាប និងមានការប្រតិបត្តិគណនេយ្យភាពល្អតិចតួចក៏ដោយ ក៏ឧទាហរណ៍មួយចំនួនដែលសាលារៀនបានធ្វើ ដើម្បីឲ្យសហគមន៍ចូលរួមអាចត្រូវបានគេទាញចេញពីការសិក្សានេះដែរ។ ឧទាហរណ៍នៅក្នុងផ្នែកនេះសាលារៀនត្រូវបានគេសិក្សាស្វែងយល់ ដើម្បីចងក្រងជាឯកសារនូវការប្រតិបត្តិល្អមួយចំនួន

[3] "បុណ្យផ្កា" គឺជាពិធីបុណ្យសាសនាមួយដែលគេរៀបចំឡើងដើម្បីប្រមូលមូលនិធិសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាក់លាក់មួយនៅក្នុងសហគមន៍។

ដែលគេអាចប្រើប្រាស់ដើម្បីផ្សព្វផ្សាយពីការចូលរួមរបស់សហគមន៍។ សកម្មភាពនានាដែលគួរយកជាគំរូដែលគេបានរកឃើញនៅក្នុងការដំណើរការដ៏ល្អរបស់ SSC រួមមានចំណុចដូចខាងក្រោម៖

- រៀបចំការប្រជុំជាទៀងទាត់ជាមួយឪពុកម្តាយ និងសហគមន៍។
- ទទួលយកធាតុចូល (inputs) ពីពួកគាត់ និងដាក់បញ្ចូលវាទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ។
- ស្នើសុំឲ្យមានការរួមវិភាគទានដោយស្ម័គ្រចិត្តពីឪពុកម្តាយ (សម្ភារៈបង្រៀន និងរៀន ការផ្តល់ប្រាក់បន្ថែមដល់គ្រូបង្រៀន។ល។)។
- នាយកសាលាមិនត្រូវកាន់កាប់គណនីធនាគាររបស់សាលារៀនទេដើម្បីធានាបាននូវតម្លាភាពផ្នែកហិរញ្ញវត្ថុ។
- រាយការណ៍ដល់សហគមន៍នូវអ្វីដែលសាលារៀនបានធ្វើ។
- ឪពុកម្តាយ និងសហគមន៍ត្រូវបានគេអញ្ជើញឲ្យមកពិនិត្យការរីកចំរើនរបស់សាលារៀន។
- គ្រូបង្រៀនត្រូវបានគេជំរុញលើកទឹកចិត្តឲ្យទទួលបាននូវការអភិវឌ្ឍន៍ផ្នែកវិជ្ជាជីវៈច្រើនថែមទៀត និងត្រូវបានគេផ្តល់ឲ្យនូវការទទួលស្គាល់ និងការកោតសរសើរកាន់តែច្រើនឡើង។
- នាយកសាលាបំពេញការងារក្នុងភាពជាអ្នកដឹកនាំ ទំនាក់ទំនងខាងក្រៅនិងខាងក្នុង និងការប្រាស្រ័យទាក់ទង ចំណែងភារកិច្ចរដ្ឋបាល និងផ្សេងៗទៀតត្រូវបានគេធ្វើប្រតិភូកម្មទៅឲ្យនាយករង។
- ការសម្រេចចិត្តនានាត្រូវបានធ្វើឡើងដោយបុគ្គលិករបស់សាលារៀន និងសហគមន៍រួមគ្នា។

ការប្រតិបត្តិល្អទាំងនេះឆ្លុះបញ្ចាំងជាចម្បងនូវគំនិតផ្តួចផ្តើម និងវិធានការនានាដែលនាយកសាលាត្រូវអនុវត្តជាជាងដោយគ្រាន់តែធ្វើតាមសេចក្តីណែនាំរបស់ថ្នាក់ជាតិ។ នៅក្នុងសាលារៀនដែលគួរយកគំរូតាមនាយកសាលាហាក់ដូចជាបានដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុងការកៀរគរអ្នកផ្សេងៗទៀតដើម្បីសម្របសម្រួលដំណើរការគ្រប់គ្រងសាលារៀន និងសកម្មភាពនានាដែលគេរំពឹងទុកថា SSC នឹងចូលរួមជាមួយ។ នៅតាមសាលារៀនដែលមានការប្រតិបត្តិល្អបំផុតសមត្ថភាពខ្ពស់របស់នាយកសាលា គឺជាកត្តាគន្លឹះមួយ។ តួនាទីរបស់នាយកសាលាមានសារៈសំខាន់ណាស់ដោយសារសមាជិក SSC ពុំបានដឹងច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនទេ បើពុំមានការជំរុញលើកទឹកចិត្តនេះ។ គម្រោងអភិបាលកិច្ចសាលារៀន (២០១៤)[4] តាមរយៈអង្គការ CARE បានផ្តល់នូវការគាំទ្រជាភស្តុតាងដែលការបណ្តុះបណ្តាលសមាជិក SSCត្រូវបានគេត្រូវការដើម្បីបង្កើនការយល់ដឹងរបស់ខ្លួនទៅលើដំណើរការរបស់ SSC ដោយសារបើពុំមានការបណ្តុះបណ្តាលការកសាងសមត្ថភាពជាលក្ខណៈប្រព័ន្ធទេ សមាជិក SSC ពុំបានដឹងឲ្យបានពេញលេញពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនឡើយដោយទុកឲ្យអ្នកដទៃបង្កើតគំនិតផ្តួចផ្តើម និងវិធានការនានាដែលទាក់ទងនឹងសកម្មភាពអភិវឌ្ឍសាលារៀនជំនួសវិញ។ ចំពោះចំណុចនេះ នាយកសាលាចាំបាច់ត្រូវមានសមត្ថភាពក្នុងការបង្កើតគំនិតផ្តួចផ្តើម និងសកម្មភាពក្នុងគោលបំណងលើកកម្ពស់ការអនុវត្តនូវតួនាទី និងការទទួលខុសត្រូវរបស់ SSC។ តួលេខទី២ និងទី៣ ៖ បង្ហាញថានៅក្នុង ខេត្តនានាដែលសាលារៀនដែលជាសំណាកមាននាយកសាលាដែលមានកម្រិតនៃការអប់រំកាន់តែខ្ពស់ ដំណើរការរបស់ SSC ក៏ត្រូវបានគេចាត់ទុកថាកាន់តែមានប្រសិទ្ធភាពដែរ។

---

[4] គម្រោងអភិបាលកិច្ចរបស់សាលារៀនត្រូវបានរៀបចំឡើងដោយអង្គការ CARE និងត្រូវបានផ្តល់មូលនិធិតាមរយៈមូលនិធិភាពជាដៃគូសម្រាប់ការកសាងសមត្ថភាពរបស់ MoEYS (CDPF)។ គម្រោងត្រូវបានគេអនុវត្តនៅឆ្នាំ២០១៣ ដែលជាការសង្កេតទិន្នន័យមូលដ្ឋាន និងនៅក្នុងខែតុលា និងវិច្ឆិកា ឆ្នាំ២០១៤ ជាការសង្កេតទិន្នន័យបញ្ចប់(end line) ដើម្បីលើកស្ទួយសមត្ថភាពរបស់ក្រុមការងារបណ្តុះ-បណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក (DTMT) និង SSCs។

បទពិសោធន៍ដ៏ស្ទាត់ជំនាញមួយដែលសមាជិក NGO របស់ NEP បានលើកឡើងក្នុងកិច្ចប្រជុំពិគ្រោះយោបល់មួយ ជាមួយ NGO ដែលកំពុងធ្វើការជាមួយ SSC គឺទាក់ទងនឹងការចូលរួមរបស់ SSC នៅក្នុងការគ្រប់គ្រងការបែងចែកឯកសណ្ឋានដល់សិស្សសាលាបឋមសិក្សា។ តាមរយៈការចូលរួមជាមួយគម្រោង NGO សមាជិក SSC បានដឹងកាន់តែច្រើនឡើងពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ហើយបានចូលរួមចំណែកប្រកប ដោយអត្ថន័យខ្លឹមសារចំពោះសាលារៀនរបស់ខ្លួន។

គម្រោងចំនួន២របស់អង្គការសេវាជំនួយសង្គ្រោះកាតូលិក (CRS) ដែលមានឈ្មោះថា ការយកចិត្តទុកដាក់" របស់សង្គម និងការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ EICS)" និង "គម្រោងបែងចែកឯកសណ្ឋាន" កំពុងត្រូវបានគេអនុវត្តនៅក្នុងសាលារៀនបឋមសិក្សាចំនួន១៨នៅក្នុងស្រុកចំនួន៣ (ស្រុកបាទី ព្រៃកប្បាស និងសំរោង) ក្នុងខេត្តតាកែវដោយមានគោលបំណងក្នុងការធានាថាកុមារពិការបានចូលរៀន និងសម្រេចលទ្ធផលល្អក្នុងសាលារៀន។

គេសង្កេតឃើញថា ទោះបីជា SSCs ត្រូវបានគេតម្រូវឲ្យមានសម្រាប់សាលារៀននីមួយៗក៏ដោយ SSCs ជាច្រើនពុំបានដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនទេ ហើយក៏ពុំមានដំណើរការល្អដែរក្នុងការគាំទ្រការអប់រំនៅកម្រិតសាលារៀន។ ហេតុដូច្នេះហើយ គម្រោង CRS បានប្រើប្រាស់សេចក្តីណែនាំសម្រាប់ SSC ដែលចេញផ្សាយដោយ MoEYS ដើម្បីរៀបចំជាផ្លូវការនូវរចនាសម្ព័ន្ធ SSC កសាងសមត្ថភាពរបស់ពួកគាត់ ដែលទទួលជោគជ័យបំផុតក្នុងការឲ្យសហគមន៍តាមមូលដ្ឋានចូលរួមគាំទ្រដល់គម្រោង។ គម្រោងបានឲ្យ SSCs ចូលរួមនៅក្នុងសកម្មភាពរបស់គម្រោងជាច្រើនដូចជា ការរៀបចំលើកកម្ពស់ការយល់ដឹងស្តីពីសិទ្ធិរបស់កុមារពិការ យុទ្ធនាការចុះឈ្មោះចូលរៀន CwDs ការពិនិត្យ និងបញ្ជូនពួកគេអោយទៅទទួលសេវាកម្មផ្នែកវេជ្ជសាស្ត្រកាយសម្បទា ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ការប្រជុំប្រចាំត្រីមាសរវាងសាលារៀន ឪពុកម្តាយ និងការជ្រើសរើសអ្នកទទួលផលរបស់គម្រោង SSCs ក រៃអង្គាសមូលនិធិ និងការគ្រប់គ្រងមូលនិធិដើម្បីជួយលើកកម្ពស់បរិស្ថាននៃការបង្រៀន និងការរៀន។ល។

លទ្ធផលនានាបង្ហាញថា SSCs ដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន និងមានការប្រាស្រ័យទាក់ទង កិច្ចសហប្រតិបត្តិការល្អជាមួយសាលារៀន និងឪពុកម្តាយដើម្បីគាំទ្រការអប់រំសម្រាប់កុមារនៅក្នុងសហគមន៍របស់ពួកគាត់។ ផែនការប្រតិបត្តិប្រចាំឆ្នាំសម្រាប់សាលារៀននីមួយៗត្រូវបានគេរៀបចំឡើងយ៉ាងច្បាស់លាស់ អ្នកទទួលផលរបស់គម្រោងត្រូវបានគេពិនិត្យដោយប្រុងប្រយ័ត្ន និងត្រូវបានគេបញ្ជូនឲ្យទៅទទួលសេវាកម្មផ្សេងៗ ត្រូវបានគេជ្រើសរើសដើម្បីធានាបាននូវគណនេយ្យភាព និងតម្លាភាពសម្រាប់អ្នកទទួលផល ការឯកភាពដ៏ច្បាស់លាស់មួយទៅលើការគ្រប់គ្រងមូលនិធិដែលជាការរួមវិភាគទាន និងផែនការសម្រាប់ការចំណាយត្រូវបានគេបង្កើតឡើងរួមគ្នា និងដោយប្រុងប្រយ័ត្ន ហើយត្រូវបានគេប្រើប្រាស់នៅក្នុងមធ្យោបាយដែលមានតម្លាភាព និងប្រសិទ្ធិភាពបំផុតដើម្បីធានាបាននូវផលប្រយោជន៍ជារួមដល់សលារៀន សហគមន៍ ។ល។

សំណូមពររបស់មូលដ្ឋាន ដោយមានការប្រឈមមុខទាំងអស់ដូចដែលបានបង្ហាញខាងលើ គម្រោងនៃការ ស្រាវជ្រាវនេះអាចទាញយកបាននូវតម្រូវការ និងដំណោះស្រាយជាក់ស្តែងមួយចំនួនពីនាយកសាលា និងសមាជិកសហគមន៍។ លទ្ធផលបានផ្តល់នូវធាតុចូលនានាដូចខាងក្រោមសម្រាប់កែលម្អការងាររបស់ SSC និងការចូលរួមរបស់សហគមន៍។ ទី១ និងសំខាន់បំផុត គេបានស្នើសុំថា ការបណ្តុះបណ្តាល SSCs គួរត្រូវបានគេរៀបចំឡើងដើម្បីពង្រីកការចូលរួមរបស់ពួកគាត់នៅក្នុងសកម្មភាពរបស់សាលារៀន។ គេត្រូវការសកម្មភាពនៃការតាមដានទៅតាមពេលវេលាជាក់លាក់ពីសំណាក់សាលារៀនទៅលើការបំពេញការងាររបស់ SSC ក្នុងគោល

បំណាងវាយតម្លៃពីកម្រិត និងលក្ខណៈនៃការចូលរួមរបស់ពួកគាត់នៅក្នុងការងារ និង សកម្មភាពអភិវឌ្ឍសាលារៀន។

ទី២ គេចាំបាច់ត្រូវជ្រើសរើស SSCs ពីក្នុងចំណោមក្រុមដែលមានចំណេះដឹង ឥទ្ធិពល ការប្ដេជ្ញាចិត្ត ជាពិសេសពីក្នុងចំណោមមនុស្សដែលមានបទពិសោធន៍ក្នុងការអប់រំ និង ឬការគ្រប់គ្រង។ ការកសាងសមត្ថភាពស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងភាពជាអ្នកដឹកនាំសម្រាប់ SSCs និងនាយកសាលាអាចជួយលើកកម្ពស់សមត្ថភាពរបស់សមាជិក SSC និងនាយកសាលាក្នុងការយល់ពីរបៀបចំណាយលុយ (របៀបបំពេញទម្រង់នៃការចំណាយ)។

ទី៣ SSC និងសាលារៀនចាំបាច់ត្រូវមានការប្រាស្រ័យទាក់ទងគ្នាច្រើនថែមទៀតតាមរយៈការប្រជុំឲ្យបាន ញឹកញាប់។ ការសង្កេតតាមមូលដ្ឋានបង្ហាញថា ការប្រាស្រ័យទាក់ទងមិនបានល្អគឺជាកត្តាដ៏ចំបងមួយដែលនាំទៅរកការខ្វះខាតការយល់ដឹងពីអ្វីដែលគេចាំបាច់ត្រូវធ្វើ និងអ្វីដែលគេបានធ្វើរួចហើយសម្រាប់ការអភិវឌ្ឍសាលារៀន។ ចំណុចនេះនឹងពន្យល់បានមួយផ្នែក ពីការខ្វះខាតការចូលរួមរបស់សហគមន៍ក្នុងកម្រិតខ្ពស់នៅក្នុងសកម្មភាពអភិវឌ្ឍសាលារៀនផ្សេងៗជាច្រើន។

ចុងក្រោយ ប៉ុន្តែមិនមែនមិនសំខាន់នោះទេ គឺគេត្រូវគិតគូរពិចារណាពីការគាំទ្រផ្នែកហិរញ្ញវត្ថុដើម្បីធានានិរន្តរភាពដល់ដំណើរការរបស់ SSCs និងដើម្បីលើកកម្ពស់ទំនាក់ទំនងសាលារៀន និងសហគមន៍។ ភាគីដែលពាក់ព័ន្ធទាំងអស់មានទស្សនៈដូចគ្នាថាសាលារៀន ឬក្រសួងត្រូវបង្កើតឲ្យមានប្រព័ន្ធមួយក្នុងការផ្ដល់រង្វាន់ ឬផ្ដល់គ្រឿងលើកទឹកចិត្តដល់ SSCs ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសាលារៀន។ ថវិកាជាច់ដោយឡែកមួយសម្រាប់ SSCs នៅក្នុងទម្រង់មួយដូចជាថវិកាតាមកម្មវិធី (PB) នឹងជួយកែលម្អការមានកម្លាំងចិត្ត និងការងាររបស់នាយកសាលា និង SSCs។ លើសពីនេះទៅទៀតគួរមានគម្រោងប្រាក់បៀវត្សជាក់លាក់មួយសម្រាប់ SSCs បើទោះបីជាចំនួនមិនត្រូវបានគេបញ្ជាក់ឲ្យបានច្បាស់លាស់ក៏ដោយ។

## ៥. ការពិភាក្សា

***ការចូលរួមរបស់សហគមន៍***

ការស្រាវជ្រាវពីគណនេយ្យភាពរបស់សាលារៀន និងសង្គមនេះគឺជាការសិក្សាដ៏ចំបងមួយនៅក្នុងបរិបទនៃការអប់រំរបស់ប្រទេសកម្ពុជាដែលសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅពីវិសាលភាពដែល SSCs បានចូលរួមនៅក្នុងការបំពេញការងាររបស់សាលារៀន និងការប្រឈមមុខចំពោះការចូលរួមរបស់សហគមន៍នៅក្នុងការបំពេញការងាររបស់សាលារៀននៅកំរិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅក្នុងប្រទេសកម្ពុជា ដែលបើមិនដូច្នេះទេ នឹងត្រូវបានគេមើលរំលងនៅក្នុងគោលនយោបាយ និងការអនុវត្តជាក់ស្តែង។ ការសិក្សានេះផ្តល់ឲ្យភាគីដែលពាក់ព័ន្ធទាំងអស់នូវការយល់ដឹងដែលមានការអភិវឌ្ឍមួយពីរបៀបដែល SSC ដំណើរការក្នុងតថភាពជាក់ស្តែងដោយប្រៀបធៀបទៅនឹងអ្វីដែលមានចែងនៅក្នុងសេចក្តីណែនាំ។ ហេតុដូច្នេះហើយ លទ្ធផលនានាផ្តល់នូវចំណែកជាភស្តុតាងផ្សេងៗ ដែលមានលក្ខណៈបច្ចុប្បន្នភាពពិសេសពីរបីចំណុចដល់តួសេចក្តីតូចមួយនៃការស្រាវជ្រាវ ស្តីពីការចូលរួមរបស់សហគមន៍ និងគណនេយ្យភាពរបស់សាលារៀននៅក្នុងប្រទេសកម្ពុជា។

គម្រោងបច្ចុប្បន្ននេះរកឃើញថា ការចូលរួមរបស់សហគមន៍នៅក្នុងការបំពេញការងាររបស់សាលារៀននៅក្នុងវដ្តន៍នៃការអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិជាទូទៅនៅមានកម្រិតទាបនៅឡើយ ជាពិសេសនៅទីក្រុង។ ទោះជាយ៉ាងណាក៏ដោយភស្តុតាងត្រូវបានគេរកឃើញទៅលើកម្រិតនៃការចូលរួមខ្ពស់គួរសមរបស់ពួកគាត់នៅក្នុងការជួយសាលារៀនរៀបចំផែនការរបស់សាលារៀន និងនៅក្នុងការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន។ ការរកឃើញនេះគាំទ្រនូវការរកឃើញរបស់ Nguon (២០១១) ដែលបានរកឃើញនូវកម្រិតនៃការចូលរួមយ៉ាងច្រើនរបស់ SSC នៅក្នុងការបង្កើតផែនការរបស់សាលារៀន។ ការរកឃើញដែលការចូលរួមរបស់ SSC នៅក្នុងការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធបានបន្ថែមនូវការយល់ដឹង និងការរីកចម្រើនថ្មីមួយចំពោះការចូលរួមរបស់សហគមន៍នៅក្នុងការបំពេញការងាររបស់សាលារៀននៅប្រទេសកម្ពុជា ដោយបន្ថែមទៅលើអ្វីដែលគេបានពិពណ៌នានៅក្នុងការរកឃើញរបស់ Nguon។ ហេតុដូច្នេះហើយ ការសិក្សានេះក៏បង្ហាញនូវការផ្លាស់ប្តូរជាវិជ្ជមានមួយគ្រាន់បើដែរដែលថាសាលារៀនបានធ្វើការយ៉ាងច្រើន ដើម្បីលើកកម្ពស់ការចូលរួមរបស់សហគមន៍តាម រយៈការទាក់ទាញ SSCs ឲ្យចូលរួមនៅក្នុងសកម្មភាពស្នូលមួយចំនួនទាក់ទងនឹងការប្រមូលកុមារគ្រប់អាយុចូលរៀន ការអប់រំប្រជាជនតាមមូលដ្ឋានឲ្យបញ្ជូនកូនៗរបស់ពួកគាត់មកសាលារៀន ផ្សព្វផ្សាយពីបរិស្ថានសុខភាពតាមសាលារៀន ព្រមទាំងការចុះទស្សនៈកិច្ចសាលារៀនដើម្បីត្រួតពិនិត្យការរៀនសូត្ររបស់សិស្ស ដែលនេះបញ្ជាក់ថាតួនាទីរបស់ SSC ត្រូវបានគេផ្តោតច្រើនជាងទៅលើការរៃអង្គាសមូលនិធិ និងការធ្វើវិភាគទានដល់សាលារៀនទៅ ទៀត។ ជារួម ទោះបីជាពុំមានលក្ខណៈស៊ីជម្រៅក៏ដោយ ការរកឃើញនេះហាក់ដូចជាបង្ហាញថា ការចូលរួមរបស់សហគមន៍នៅក្នុងការបំពេញការងាររបស់សាលារៀនដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងការចូលរួមរបស់ SSC មានការកែលម្អយ៉ាងច្រើន។ និយាយយ៉ាងសាមញ្ញការរកឃើញនេះបង្ហាញថា សកម្មភាពដែលទាក់ទងនឹងសាលារៀនកាន់តែច្រើនឡើងត្រូវបានសហគមន៍ចូលរួម ទោះបីពុំមានលក្ខណៈស៊ីជម្រៅក៏ដោយ។

លទ្ធផលនានាបង្ហាញឲ្យឃើញនូវការពិត ដែលគួរឲ្យកត់សំគាល់មួយចំនួនអំពីលក្ខណៈនៃការចូលរួមរបស់ ពួកគាត់ផងដែរ។ ជារួមការសិក្សានេះបានរកឃើញថា សមាជិក SSC ហាក់ដូចជាមានការចាប់អារម្មណ៍ចំពោះចំណុចបញ្ហានៃតម្លាភាពផ្នែកហិរញ្ញវត្ថុទាក់ទងនឹងសាលារៀន និងសហគមន៍ ខណៈដែលពួកគាត់មាន

ការចូលរួមតិចតួចនៅក្នុងសកម្មភាពប្រមូល និងគ្រប់គ្រងថវិកាជាមួយសាលារៀន។ តាមការអនុវត្តជាក់ស្តែង SSCs មានការចាប់អារម្មណ៍ច្រើនជាងចំពោះថវិការបស់សាលារៀន និងការប្រើប្រាស់ថវិកា។ សកម្មភាពផ្សេងៗទៀតដែលទាក់ទងនឹងការប្រមូល និងការគ្រប់គ្រងមូលនិធិនៅតែមិនទាន់ត្រូវបានគេបំពេញនៅឡើយ។ ការរកឃើញនេះបញ្ជាក់ថា SSCs ពុំទាន់បានដើរតួនាទីដ៏សកម្មមួយផ្នែកហិរញ្ញវត្ថុ និងការធ្វើសេចក្តីសម្រេចចិត្តរបស់សាលារៀននៅឡើយដែលជាលទ្ធផលមួយដែលផ្តល់នូវវឌ្ឍនភាពតិចតួចចំពោះអ្វីដែលគេបានបញ្ជាក់អះអាងនៅក្នុងការរកឃើញរបស់ Nguon (២០១១) និង Pellini (២០០៥, ២០០៧)។ ចំពោះហេតុផលមួយចំនួន ការព្រួយបារម្ភចំពោះតម្លាភាពផ្នែកហិរញ្ញវត្ថុក្នុងចំណោម SSCs គឺជាអ្វីដែលអាចពន្យល់បានដោយប្រុងប្រយ័ត្នចំពោះលក្ខណៈនៃការចូលរួមរបស់ពួកគាត់។ ចេតនារបស់សាលារៀនក្នុងការលើកកម្ពស់ការចូលរួមវិភាគទានរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀនក៏អាចជាកត្តាមួយផងដែរ។ ក្នុងពេលជាមួយគ្នានេះដែរ អ្វីដែលអាចកត់សម្គាល់បានចំពោះការចូលរួមរបស់ពួកគាត់នៅក្នុងការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនគឺថា សហគមន៍មានទំនោរទៅរកការផ្លាស់ប្តូរការយកចិត្តទុកដាក់ទៅលើការថែរក្សាជាជាងទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន។ ដូចដែលបានរាយការណ៍នៅក្នុងការសម្ភាសន៍ជាមួយសមាជិក SSC ភាពក្រីក្រ ចំណាកស្រុក និងការបាត់បង់ការជឿទុកចិត្តក្នុងចំណោមសហគមន៍គឺជាកត្តាដ៏ចំបងដែលពន្យល់ពីការផ្លាស់ប្តូរនោះ។ ខណៈពេលដែលការរកឃើញនេះបង្ហាញថា តួនាទីរបស់ SSC មិនត្រូវបានគេបំពេញឲ្យបានទូលំទូលាយនោះ វាបានផ្តល់ឲ្យនូវការផ្លាស់ប្តូរមួយចំពោះការចូលរួមរបស់ SSC នៅក្នុងការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅក្នុងប្រទេសកម្ពុជា។

### *ការបំពេញការងាររបស់សាលារៀន*

ដូចដែលលទ្ធផលនានាបានបង្ហាញសាលារៀនមានគណនេយ្យភាពជាសំខាន់ចំពោះការងាររដ្ឋបាល ព្រមទាំងកម្មវិធីសិក្សា និងការបង្រៀន។ តួនាទីរបស់នាយកសាលាត្រូវបានគេកម្រិតជាសំខាន់ចំពោះភារកិច្ចទាំង២នេះ ដោយបន្ថែមទៅលើសកម្មភាពគ្រប់គ្រងផ្សេងៗទៀតដែលទាក់ទងនឹងសាលារៀនដែលមានការទាក់ទងជាពិសេសជាមួយ MoEYS។ លទ្ធផលទាំងនេះហាក់ដូចជាបង្ហាញថា នាយកសាលាដើរតួនាទីជាសំខាន់មួយក្នុងការបំពេញនូវភារកិច្ចរបស់ខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការដែលបានកំណត់ដោយ DoE/PoE/MoEYS ដោយពុំអើពើនឹងតួនាទីរបស់ខ្លួនក្នុងការតភ្ជាប់ទំនាក់ទំនងរបស់សាលារៀនជាមួយសហគមន៍ និងសាលារៀនផ្សេងៗទៀត។ លទ្ធផលដូចនេះបញ្ជាក់ពីការពិតដែលថា គណនេយ្យភាពរបស់សាលារៀនគឺជាភារកិច្ចចំបងមួយក្នុងចំណោមនាយកសាលា។ ជាលទ្ធផល គណនេយ្យភាពរបស់សាលារៀននៅតែជាចំណោទមួយ។ ការរកឃើញនេះមានប្រយោជន៍ណាស់នៅក្នុងមធ្យោបាយមួយដែលការពង្រីកសមត្ថភាពរបស់នាយកសាលាឲ្យទូលំទូលាយគឺមានសារៈសំខាន់ ដោយសារនៅក្នុងវិសាលភាពមួយចំនួន នាយកសាលាពុំត្រូវបានគេបណ្តុះបណ្តាលឲ្យបានល្អដើម្បីយល់ដឹងឲ្យបានច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនទេ ជាពិសេសទាក់ទងនឹងចំណេះដឹងរបស់ពួកគាត់ពីដំណើរការរបស់សាលារៀនសម្រាប់សហគមន៍ និងសង្គម។ ហេតុដូច្នេះហើយ ការរកឃើញនេះសន្និដ្ឋានថា គណនេយ្យភាពរបស់សាលារៀនពុំត្រូវបានគេអនុវត្តន៍ឲ្យបានទូលំទូលាយទេនៅក្នុងចំណោមនាយកសាលា។ មានការយល់ដឹងផ្ទុយគ្នាមួយចំពោះតួនាទី និងការទទួលខុសត្រូវក្នុងចំណោមភាគីដែលពាក់ព័ន្ធនឹងការអប់រំទាំងនោះ ដោយធ្វើឲ្យសាលារៀនពុំបានយល់ដឹងច្បាស់លាស់ថា តើអ្វីដែលគេត្រូវមានគណនេយ្យភាពចំពោះ។

ដូចគ្នានេះដែរ ការសិក្សានេះបានរកឃើញថា សកម្មភាពវាយតម្លៃសាលារៀនពុំត្រូវបានគេបំពេញឲ្យបានពេញលេញទេនៅតាមសាលារៀន។ មានការអនុវត្តជាក់ស្តែងដែលមានកម្រិតមួយពីការវាយតម្លៃដោយខ្លួនឯង និងពីខាងក្រៅរបស់សាលារៀន។ ការបោះពុម្ពផ្សាយនូវរបាយការណ៍ស្តីពីការបំពេញការងាររបស់សាលារៀនមិនត្រូវបានគេធ្វើឡើងទេនៅតាមសាលារៀនភាគច្រើននៅក្នុងការសិក្សានេះ។ គេរំពឹងទុកថា នឹងទទួលបានលទ្ធផលនេះ ដោយសារប្រព័ន្ធវាយតម្លៃសាលារៀនពុំត្រូវបានគេអនុវត្តឲ្យបានពេញលេញទេនៅក្នុងប្រទេសកម្ពុជា។ ជាពិសេស ទោះបីជា MoEYS រៀបចំការធ្វើអធិការកិច្ចនៅតាមសាលារៀនជារៀងរាល់ឆ្នាំក៏ដោយ ក៏ការវាយតម្លៃសាលារៀនមិនមែនជាការផ្ទង់ផ្តោតដ៏ចំបងមួយទេ។ ការខ្វះនូវចំណេះដឹងរបស់នាយកសាលានៅក្នុងការរៀបចំការវាយតម្លៃដោយខ្លួនឯងក៏នឹងនាំទៅរកការខ្វះខាតនូវការអនុវត្តនូវការវាយតម្លៃរបស់សាលារៀន និងការបោះពុម្ពផ្សាយនូវរបាយការណ៍វាយតម្លៃរបស់សាលារៀនដែរ។ លទ្ធផលនេះគឺមិនមែនថ្មីទេ។ តាមការប្រមើលមើល គណនេយ្យភាពចំពោះការរៀនសូត្ររបស់សិស្សនៅតែជាចំណោទដដែល ដោយសារមានគម្លាតដែលកាន់តែរីកធំឡើងរវាងសាលារៀន និងសហគមន៍ ចំពោះចំណេះដឹងនៃការបំពេញការងាររបស់សាលារៀន និងការរៀនសូត្ររបស់សិស្ស។

ការពិតដ៏សំខាន់នៃគណនេយ្យភាពរបស់សាលារៀននៅក្នុងប្រទេសកម្ពុជាគឺមានទំនាក់ទំនងជាមួយនឹងវិសាលភាពដែលនាយកសាលាបានដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។ លទ្ធផលនានាបង្ហាញថាមានដំណើរការដែលមានកម្រិតដែលនាយកសាលាយល់ឃើញថាជាការទទួលខុសត្រូវចំបងៗរបស់ខ្លួន។ ដូចដែលលទ្ធផលនានាបានចង្អុលបង្ហាញពួកគាត់បានយល់ឃើញថា ពួកគាត់ត្រូវទទួលខុសត្រូវច្រើនថែមទៀតចំពោះការចុះឈ្មោះចូលរៀនរបស់សិស្ស និងសរសេររបាយការណ៍ស្តីពីការបំពេញការងាររបស់សាលារៀន។ ភារកិច្ចផ្សេងៗទៀតដែលទាក់ទងនឹងសាលារៀន ដូចជាការជ្រើសរើស/ការបណ្តេញគ្រូបង្រៀន ការជ្រើសរើសសៀវភៅអាន ឬខ្លឹមសារបង្រៀន និងការកំណត់ថវិកាសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន បើតាមសេចក្តីរាយការណ៍ ត្រូវបានតម្រង់ទិសដោយ PoE/DoE/MoEYS។ ការរកឃើញ នេះចោទជាសំណួរទៅលើសមត្ថភាព និងកម្រិតស្វ័យភាពរបស់នាយកសាលានៅក្នុងប្រទេសកម្ពុជាចំពោះការបំពេញភារកិច្ចដែលទាក់ទងនឹងសាលារៀន។ ការនេះនឹងមានផលប៉ះពាល់យ៉ាងច្រើន ទៅលើកម្រិតនៃការយល់ដឹងរបស់ពួកគាត់ពីអ្វីដែលសាលារៀនត្រូវមានគណនេយ្យភាពចំពោះនៅក្នុងការអនុវត្តជាក់ស្តែង ជាពិសេសទាក់ទងនឹងសហគមន៍។

ការសិក្សានេះរកឃើញថា ព័ត៌មានស្តីពីផែនការអភិវឌ្ឍសាលារៀនមិនត្រូវបានគេចែកផ្សាយឲ្យបានទូលំទូលាយទេ។ នេះគឺជាភស្តុតាងដែលសមាជិក SSC ហាក់ដូចជាបានរាយការណ៍ពីចំណេះដឹងយ៉ាងច្រើនពីអ្វីដែលសាលារៀនកំពុងធ្វើបើប្រៀបធៀបទៅនឹងសមភាគីរបស់ពួកគាត់ដែលមិនមែនជាសមាជិក SSC។ នៅខាងក្រៅវដ្តន៍របស់ SSC វាទំនងណាស់ថា ការយល់ដឹងពីការបំពេញការងាររបស់សាលារៀននៅមានកម្រិត។ លទ្ធផលបានផ្តល់ភស្តុតាងថា ការប្រាស្រ័យទាក់ទងមានលំហូរតែរវាងនាយកសាលា និង SSCs ប៉ុណ្ណោះ ដែលក្នុងករណីខ្លះគឺមានតែប្រធាន SSC ទេ។ ការចូលរួមរបស់សហគមន៍មានការខ្វះខាតនៅក្នុងករណីនេះ។ ចំណុចនេះត្រូវបានគាំទ្រដោយការរកឃើញដែលបានបង្ហាញពីខាងដើមថា សាលារៀនមានគណនេយ្យភាពជាចំបងចំពោះភារកិច្ចផ្ទៃក្នុងដែលក្រសួងតម្រូវឲ្យមាន។ ផ្ទុយទៅវិញ បើតាមរបាយការណ៍ ពួកគាត់ខកខានក្នុងការពង្រីកដំណើរការរបស់ខ្លួនដើម្បីឲ្យបានដល់សហគមន៍ទាំងមូល។

# ៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

***សេចក្តីសន្និដ្ឋាន***

សេចក្តីសន្និដ្ឋានជាច្រើនត្រូវបានគេទាញយកចេញពីគម្រោងនៃការសិក្សានេះ។ ទី១ ទោះបីជាការចូលរួម របស់សហគមន៍នៅក្នុងការបំពេញការងាររបស់សាលារៀននៅមានកម្រិតទាបក៏ដោយ ជាពិសេសនៅទីក្រុង ក៏មានការរីកចម្រើនមួយចំនួនចំពោះលក្ខណៈនៃការចូលរួមរបស់ពួកគាត់ដែរ។ លទ្ធផលចង្អុលបង្ហាញថា SSCs មានការយល់ដឹងកាន់តែច្រើនឡើងពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ទោះបីជាមិនស្ថិតនៅក្នុង កម្រិតមួយដែលគេចង់បានក៏ដោយ ដោយពួកគាត់បានចូលរួមនៅក្នុងសកម្មភាពផ្សេងៗជាច្រើនទាក់ទងនឹង សាលារៀនជាងអ្វីដែល Pellini បានរាយការណ៍នៅក្នុងរយៈពេល១ទសវត្សកន្លងមកនេះ (សូមមើល Pellini ២០០៥, ២០០៧)។ ជាមូលដ្ឋាន ពួកគាត់បានរួមចំណែកដល់ការអភិវឌ្ឍសាលារៀន តាមរយៈការចូលរួមនៅ ក្នុងការរៀបចំផែនការអភិវឌ្ឍសាលារៀន និងការត្រួតពិនិត្យការអនុវត្តផែនការ។ ទោះបីជាពួកគេចូលរួមតិចនៅ ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលារៀនក៏ដោយ ក៏មានការចូលរួមដែលមានការកើនឡើងមួយពីសំណាក់ សហគមន៍នៅក្នុងការត្រួតពិនិត្យដំណើរការសាងសង់សាលារៀន និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធដែលមាន។ ជាងនេះទៅទៀត ពួកគាត់ក៏ផ្តល់នូវការគាំទ្រមួយចំនួនដល់សាលារៀនដែរក្នុងការធានាបាននូវបរិស្ថានដែល មានសុវត្ថិភាព និងមេត្រីភាពសម្រាប់អ្នករៀនសូត្រ។

ទី២ ការរកឃើញជាគន្លឹះនានានៃការសិក្សាស្រាវជ្រាវនេះទាញនូវការសន្និដ្ឋានមួយថា មានគម្លាតជាខ្លាំង រវាង SSCs និងអ្នកដែលមិនមែន SSCs ចំពោះការយល់ដឹងពីអ្វីដែលសាលារៀនកំពុងដំណើរការ និងដំណើរ យ៉ាងដូចម្តេច ជាពិសេសពីតួនាទី និងការទទួលខុសត្រូវរបស់ SSCs។ អ្នកដែលមិនមែន SSC ហាក់ដូចជាមាន អារម្មណ៍កាន់តែនៅដាច់ឆ្ងាយពីសាលារៀន ដែលធ្វើឲ្យការយល់ដឹងរបស់ពួកគាត់ពីអ្វីដែល SSCs កំពុងធ្វើ កាន់តែមានកម្រិតថែមទៀតបើប្រៀបធៀបជាមួយនឹងសមភាគីរបស់ពួកគាត់ដែលជា SSC។ SSCs ហាក់ដូច ជាមានការយល់ដឹងកាន់តែច្រើនឡើងពីការបំពេញការងាររបស់សាលារៀន យុទ្ធសាស្ត្រ ឬការអនុវត្តជាក់ស្តែង ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍។ ទោះបីជាដូចនេះក្តី ពួកគាត់មានទស្សនៈដូចគ្នាចំពោះការប្រឈម មុខដែលអាចកើតមានដែលរារាំង SSCs ឬសហគមន៍មិនឲ្យចូលរួមឲ្យបានសកម្មនៅក្នុងការបំពេញការងារ ឬ សកម្មភាពអភិវឌ្ឍរបស់សាលារៀន។ ការប្រឈមមុខទាំងនេះ រាប់បញ្ចូលទាំងការខ្វះការយល់ដឹងពីតួនាទី និង ការទទួលខុសត្រូវរបស់ SSC ក្នុងចំណោមនាយកសាលា និងសមាជិក SSC ការមានទឹកចិត្ត ឬការជឿជាក់ ទាបពីសហគមន៍ និងអាជ្ញាធរដែនដី ការខ្វះការប្រាស្រ័យទាក់ទង និងកិច្ចសហប្រតិបត្តិការក្នុងចំណោមនាយក សាលា SSCs និងសហគមន៍ ព្រមទាំងការខ្វះការ ផ្តល់មូលនិធិដើម្បីធ្វើឲ្យមាននិរន្តរភាពដល់ការងាររបស់ SSCs។

ចុងក្រោយតែមិនមែនអស់នោះទេ មានការប្រតិបត្តិល្អមួយចំនួនដែលមានលក្ខណៈហ្មត់ចត់ដែលចាំបាច់ ត្រូវធានា និងលើកកម្ពស់ការងាររបស់ SSCs ព្រមទាំងការចូលរួមរបស់សហគមន៍។ ការសិក្សានេះសន្និដ្ឋានថា SSCs ប្រហែលជាមិនអាចដំណើរការបានល្អទេ ប្រសិនបើតួនាទី និងការទទួលខុសត្រូវរបស់ SSCs មិនត្រូវ បានគេផ្សព្វផ្សាយឲ្យបានច្បាស់លាស់ដល់នាយកសាលា និង SSCs ខ្លួនឯងទេនោះ SSCs ត្រូវបានគេជ្រើស រើសចេញពីក្រុមដែលមានចំណេះដឹង ឥទ្ធិពល ការប្តេជ្ញាចិត្ត ការប្រាស្រ័យទាក់ទងរវាងនាយកសាលា និង

SSCs ត្រូវបានគេតភ្ជាប់ ជាមូលដ្ឋានតាមរយៈការប្រជុំជាទៀងទាត់ និងមាននិរន្តរភាពផ្នែកហិរញ្ញវត្ថុដើម្បីលើកទឹកចិត្តសមាជិកSSCឲ្យធ្វើការជាមួយសាលារៀន និងសហគមន៍ និងធ្វើការដើម្បីសាលារៀន និងសហគមន៍។

***អនុសាសន៍***

របាយការណ៍នេះពុំមានបំណងផ្តល់នូវអនុសាសន៍ដែលមានលក្ខណៈបង្គាប់បញ្ជាផ្នែកគោលនយោបាយ និងការអនុវត្តជាក់ស្តែងដើម្បីពង្រឹងគណនេយ្យភាពរបស់សាលារៀននៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែមានបំណងចង្អុលបង្ហាញនូវចំណុច និងគម្លាតជាគន្លឹះដែលទាញយកចេញពីការប្រតិបត្តិដែលមានស្រាប់នានា ស្តីពីការចូលរួមរបស់សហគមន៍នៅក្នុងការបំពេញការងាររបស់សាលារៀន ដែលជាឧបករណ៍មួយសម្រាប់កែលម្អគណនេយ្យភាពរបស់សាលារៀន។ របាយការណ៍នេះក៏មានបំណងបង្កើតនូវវេទិកាមួយផងដែរ សម្រាប់ការពិភាក្សាដេញដោលផ្នែកគោលនយោបាយ និងការពិភាក្សាបន្ថែមទៀត។ ហេតុដូច្នេះហើយ ចំណុចដែលជាគន្លឹះខាងក្រោមត្រូវបានគេផ្តល់ឲ្យសម្រាប់គោលបំណងនេះ។

***ពង្រឹងនូវការអនុវត្តសេចក្តីណែនាំរបស់ SSC ដែលមានស្រាប់ឡើងវិញ ៖***

មានប្រការជាច្រើននៅក្នុងសេចក្តីណែនាំស្តីពី SSCs ត្រូវបានគេចែងយ៉ាងច្បាស់លាស់។ ទោះជាយ៉ាងនេះក្តី ការអនុវត្តនៅកម្រិតសាលារៀនត្រូវបានគេមើលឃើញថា នៅមានកម្រិតនៅឡើយ។ នៅក្នុងន័យនេះ នាយកសាលា និងគណកម្មការគ្រប់គ្រងសាលារៀនត្រូវយកចិត្តទុកដាក់បន្ថែមទៀត លើការអនុវត្តសេចក្តីណែនាំរបស់ SSC ដើម្បីធានាបានថាការអនុវត្តជាក់ស្តែងរបស់ពួកគាត់នៅកម្រិតសាលារៀន ឆ្លុះបញ្ចាំងពីអ្វីដែលមានចែងនៅក្នុងសេចក្តីណែនាំ ព្រមទាំងប្រើប្រាស់ឲ្យបានល្អបំផុតនូវធនធានរបស់ SSC សម្រាប់សកម្មភាពរបស់សាលារៀន។ ចំណុចដូចខាងក្រោមមានសារៈសំខាន់ណាស់ក្នុងការពិចារណា ៖

១) ជ្រើសរើស ឬជ្រើសរើសឡើងវិញឲ្យបានហ្មត់ចត់នូវSSCដែលមានគុណភាព៖ នាយកសាលា និងគណៈកម្មការគ្រប់គ្រងសាលារៀនត្រូវផ្សព្វផ្សាយព័ត៌មានស្តីពីការជ្រើសរើស និង ឬការបោះឆ្នោតជ្រើសរើសSSCឡើងវិញនៅក្នុងសាលារៀនរបស់ខ្លួន។ នាយកសាលាត្រូវផ្សព្វផ្សាយព័ត៌មានស្តីពីតួនាទីសំខាន់ៗរបស់SSCsក្នុងការលើកកម្ពស់ការបំពេញការងារ និងគណនេយ្យភាពរបស់សាលារៀនដើម្បីទាក់ទាញប្រជាជនដែលមានគុណភាពឲ្យធ្វើជាសមាជិករបស់ SSC ។ SSCs ត្រូវបោះឆ្នោតឡើងវិញជាទៀងទាត់ ដោយយោងទៅលើសេចក្តីណែនាំដែលមានស្រាប់។

២) ផ្តល់អំណាចដល់ SSCs ដើម្បីបំពេញភារកិច្ចរបស់ខ្លួនឲ្យបានពេញលេញ ៖ នាយកសាលា និងគណៈ កម្មការគ្រប់គ្រងសាលារៀនត្រូវធ្វើប្រតិភូកម្មអំណាចដល់ SSC ជាពិសេសក្នុងការត្រួតពិនិត្យការបំពេញការងាររបស់សាលារៀន ដោយរាប់បញ្ចូលទាំងថវិការបស់សាលារៀនដើម្បីធានាថា ថវិការបស់សាលារៀន ត្រូវបានចំណាយក្នុងលក្ខណៈមួយដែលមានតម្លាភាព ដើម្បីឲ្យ SSC អាចរាយការណ៍បានយ៉ាងត្រឹមត្រូវដល់សហគមន៍ក្នុងគោលបំណងទាក់ទាញការគាំទ្រ និងការរួមវិភាគទានច្រើនថែមទៀត។

៣) រចនាសម្ព័ន្ធ សមាសភាព និងតួនាទី និងការទទួលខុសត្រូវរបស់ SSCs គួរត្រូវបានគេបិទផ្សាយដែល នេះអាចមើលឃើញ និងអាចអានបាននៅកម្រិតសាលារៀន។

### *ការពង្រឹងសមត្ថភាពនាយកសាលា និង SSCs*

ការសិក្សានេះរកឃើញនូវការខ្វះខាតការយល់ដឹងឲ្យបានច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវក្នុងចំណោមនាយកសាលា និងសមាជិក SSC ។ ទោះបីជាការកសាងសមត្ថភាពស្តីពីសេចក្តីណែនាំសម្រាប់គណៈកម្មការគ្រប់គ្រងសាលារៀនត្រូវបានគេផ្តល់ឲ្យនៅថ្នាក់ខេត្ត និងសាលារៀនក៏ដោយ ក៏នៅតែមានការខ្វះខាតយ៉ាងសំខាន់មួយចំពោះការយល់ដឹងពីអ្វីដែលសាលារៀនត្រូវបំពេញ ឬត្រូវមានគណនេយ្យភាពចំពោះ និងអ្វីដែល SSCs ត្រូវអនុវត្ត។ ដូចដែលលទ្ធផលនានាបានបង្ហាញសហគមន៍អាចយល់ឃើញថា ការចូលរួមនៅក្នុងការត្រួតពិនិត្យការរៀនសូត្ររបស់សិស្ស និងការបង្រៀនគឺជាការទទួលខុសត្រូវរបស់សាលារៀន ឬរដ្ឋាភិបាលតែមួយគត់។ ហេតុដូច្នេះហើយ នាយកសាលា និង SSCs ចាំបាច់ត្រូវមានការយល់ ដឹងឲ្យបានច្បាស់លាស់មួយនូវតួនាទី និងការទទួលខុសត្រូវដែលពួកគាត់ចាំបាច់ត្រូវអនុវត្ត។ មកដល់ចំណុចនេះ មានអនុសាសន៍គន្លឹះជាក់លាក់ចំនួន២ ៖

- ឲ្យនាយកសាលា និង SSCs ចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាដើម្បីលើកកម្ពស់សមត្ថភាពរបស់ពួកគាត់ទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវរបស់ពួកគាត់ ជាពិសេស សេចក្តីណែនាំរបស់ SSC ។
- ធានាថានាយកសាលាទាំងអស់ត្រូវបានបណ្តុះបណ្តាលស្តីពីជំនាញនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងជាមូលដ្ឋាន ព្រមទាំងជំនាញក្នុងការប្រាស្រ័យទាក់ទងដើម្បីធ្វើឲ្យពួកគាត់មានការយល់ដឹងពីអ្វីដែលសាលាចាំបាច់ត្រូវផ្តល់ឲ្យសហគមន៍។

### *កែលម្អការសម្របសម្រួលក្នុងចំណោមតួអង្គសំខាន់ៗ*

គម្លាតមួយក្នុងការប្រាស្រ័យទាក់ទងរវាងសាលារៀន និងសហគមន៍មិនមែនជារឿងមិនធម្មតាទេ នៅក្នុងប្រទេសមួយដែលផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងសង្គមមិនត្រូវបានគេផ្តល់ឲ្យ និងបញ្ជាក់ឲ្យបានច្បាស់លាស់។ នៅក្នុងប្រទេសកម្ពុជា ការបង្កើត SSCs គឺជាសញ្ញាល្អមួយដែលពង្រឹងដំណើរការវិមជ្ឈការ និងនាំទៅរកការចូលរួមច្រើនថែមទៀតរបស់សហគមន៍នៅក្នុងការបំពេញការងាររបស់សាលារៀន។ ទោះជាយ៉ាងណាក៏ដោយ ជោគជ័យនៃដំណើរការរបស់អង្គការនេះតម្រូវឲ្យមានការសម្របសម្រួលកាន់តែប្រសើរឡើងថែមទៀត ពីគ្រប់អង្គការផ្នែកអភិបាលកិច្ចដែលពាក់ព័ន្ធទាំងអស់។ ហេតុដូច្នេះហើយ ក្រុមការងារបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុកត្រូវ សម្របសម្រួលការប្រជុំផ្លូវការឬប្រជុំពិភាក្សាតាមពេលវេលាជាក់លាក់រវាងគណៈកម្មការគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសមាជិក SSC ។

### *ការពង្រឹងគណនេយ្យភាពផ្នែកហិរញ្ញវត្ថុ*

ការសិក្សាស្រាវជ្រាវនេះបង្ហាញថា ការខ្វះការគាំទ្រពីសហគមន៍ធ្វើឲ្យរាំងស្ទះដល់ការងាររបស់ SSCs និងការអនុវត្តជាក់ស្តែងនូវគណនេយ្យភាពរបស់សាលារៀននៅបឋមសិក្សា និងមធ្យមសិក្សា បឋមភូមិនៅក្នុងប្រទេសកម្ពុជា។ ការខ្វះការជឿជាក់ពីសហគមន៍ទៅលើសាលារៀន ក៏ដូចជាការខ្វះការជឿជាក់របស់ SSCs ទៅលើតម្លាភាពនៃការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុចំពោះការរួមវិភាគទានរបស់សហគមន៍ ជាថវិកា ឬជាសម្ភារៈគឺអាចបណ្តាលឲ្យមានការចូលរួមតិចតួចពីសហគមន៍។ ឧទាហរណ៍ "បុណ្យផ្កា" លែងមានប្រសិទ្ធិភាពទៀតហើយ

ដោយសារការរួមវិភាគទានផ្នែកហិរញ្ញវត្ថុរបស់ខ្លួនសម្រាប់ការអភិវឌ្ឍសាលារៀន ពុំដែលមានរបាយការណ៍ហិរញ្ញវត្ថុត្រូវបានគេផ្សព្វផ្សាយដល់សហគមន៍ឡើយ។ ភាពមិនប្រក្រតីដែលគេចោទប្រកាន់ដោយគ្មានភស្តុតាងនេះហើយគឺជាបញ្ហា។ ដើម្បីទទួលបានការជឿជាក់ពីសហគមន៍ នាយកសាលា និង SSCs ចាំបាច់ត្រូវបង្ហាញតម្លាភាពដល់សហគមន៍តាម រយៈការបោះពុម្ពផ្សាយនូវ របាយការណ៍ឲ្យបានទៀងទាត់។

***ការផ្តល់អំណាចដល់តួនាទីរបស់ក្រុមប្រឹក្សាឃុំ***

ការដែលគួរឲ្យកត់សម្គាល់នៅក្នុងការសិក្សាស្រាវជ្រាវនេះ គឺតួនាទីដែលមានឥទ្ធិពលរបស់ក្រុមប្រឹក្សាឃុំនៅ ក្នុងការអប់រំឪពុកម្តាយ និងសហគមន៍តាមមូលដ្ឋានពីតម្លៃនៃសារៈសំខាន់នៃការអប់រំ និងបញ្ជូនកូនៗរបស់ពួកគាត់ឲ្យមកសាលារៀន។ ដោយសារការខ្វះការចូលរួមឲ្យបានស៊ីជម្រៅពីសហគមន៍នៅក្នុងការងាររបស់សាលារៀន ការ ផ្តល់អំណាចទៅលើតួនាទីរបស់ក្រុមប្រឹក្សាឃុំ នៅក្នុងការទាក់ទាញប្រជាជននៅក្នុងសហគមន៍ឲ្យបានកាន់តែច្រើនឡើងដើម្បីឲ្យមានការយល់ដឹងកាន់តែប្រសើរឡើងពីការបំពេញការងាររបស់សាលារៀន និង SSCs អាចជាផលប្រយោជន៍មួយ។ អនុសាសន៍ជាក់លាក់មានដូចខាងក្រោម ៖

- ឲ្យសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ចូលរួមនៅក្នុងការរៀបចំផែនការអភិវឌ្ឍសាលារៀន និងព្រឹត្តិការណ៍របស់សាលារៀនឲ្យបានទៀងទាត់។
- រៀបចំព្រឹត្តិការណ៍សង្គមតាមមូលដ្ឋានដើម្បីឲ្យសមាជិកក្រុមប្រឹក្សាឃុំមានលទ្ធភាពផ្សព្វផ្សាយពីគោលការណ៍នៃការរៀនសូត្រនៅសាលារៀន ឬបញ្ហាសង្គមផ្សេងៗ ជាពិសេសការងាររបស់ SSCs ដល់កុមារ ឪពុកម្តាយ និងសហគមន៍ទូទៅ។

# ឯកសារយោង


Amo, L. C. (2015). *School accountability and principal behaviors* (Doctoral dissertation, STATE UNIVERSITY OF NEW YORK AT BUFFALO).

Barrera-Osorio, F., Fasih, T., & Patrinos, H. A. (2009). *Decentralized decision-making in schools: The theory and evidence on school-based management*. Washington: The World Bank

Benveniste, G. (1985). The design of school accountability systems. *Educational Evaluation and Policy Analysis, 7*(3), 261-279

Bray, M. (2003). Community initiatives in education: Goals, dimensions and linkages with government. *Compare: A Journal of Comparative and International Education*, *33*(1), 31-45.

Burgess, S. M., Propper, C., Slater, H., & Wilson, D. (2005). Who wins and who loses from school accountability? The distribution of educational gain in English secondary schools. Discussion document. Retrieved from http://www.researchgate.net/publication/4998614

Burke, J. C. (2005). The many faces of accountability. *Achieving accountability in higher education: Balancing public, academic, and market demands*, 1-24.

Caldwell, B. J. (2002). *Autonomy and self-management: Concepts and evidence*. In Bush, T., & Bell, L. (Eds.), The Principles and Practice of Educational Management' (pp. 21-40 ). London: Paul Chapman Publishing

Cambodia Ministry of Education, Youth and Sport [MoEYS]. (2015b). *Teacher policy action plan 2015-2020*. Phnom Penh: MoEYS Printing Office.

Cambodia Ministry of Education, Youth, and Sport. (n.d.). សេចក្តីណែនាំស្តីពី ការបង្កើតនិងដំណើរការរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា [Guideline on the creation and function of primary school supporting committee]. Phnom Penh: Author.

Carnoy, M., & Loeb, S. (2002). Does external accountability affect student outcomes? Across-state analysis. *Educational evaluation and policy analysis*, *24* (4), 305-331.

Coleman, J. S., Campbell, E. Q., Hobson, C. J., McPartland, J., Mood, A. M., Weinfeld, F. D., & York, R. (1966). *Equality of educational opportunity*. Washington, DC, 1066-5684.

Cornwall, A., Lucas, H., & Pasteur, K. (2000). Accountability through participation: developing workable partnership models in the health sector. *IDS BULLETIN*, *31*(1), 1-13.

Cullen, J. B., & Reback, R. (2006). *Tinkering toward accolades: School gaming under a performance accountability system* (No. w12286). National Bureau of Economic Research.

Darling-Hammond, L., & Snyder, J. (2015). Professional capacity and accountability: An introduction. *education policy analysis archives*, *23*, 14.

Deere, D., & Strayer, W. (2001). *Putting schools to the test: School accountability, incentives*. and behavior. Working Paper 113, Private Enterprise Research Center, Texas A&M University (March 2001).

Figlio, D. N., & Page, M. E. (2003). Can school choice and school accountability successfully coexist?. In *The economics of school choice* (pp. 49-66). University of Chicago Press.

Figlio, D., & Loeb, S. (2011). School accountability. *Handbook of the Economics of Education*, *3*, 383-421.

Finn, C. E. (2002). Real accountability in K–12 education: The marriage of Ted and Alice. *School Accountability: An Assessment by the Koret Task Force on K-12 Education.* USA: Hoover Institution Press. Disponible en< URL: http://www.hoover.org/publications/books/fulltext/accountability/23.pdf.

Fullan, M., & Watson, N. (2000). School-based management: Reconceptualizing to improve learning outcomes. *School Effectiveness and School Improvement*, *11*(4), 453-474.

Fuhrman, S., & Elmore, R. F. (Eds.). (2004). *Redesigning accountability systems for education* (Vol. 38). Teachers College Press.

Gong, B. (2002). *Designing school accountability systems: Towards a framework and process.* Washington, DC: Council of Chief State School Officers.

Hanushek, E. A. (2010). *Education production functions: Developed countries evidence*. Retrieved from:http://hanushek.stanford.edu/sites/default/files/publications/Hanushek%202010%20IntEncEduc%202.pdf

Hanushek, E. A., & Raymond, M. E. (2004). The effect of school accountability systems on the level and distribution of student achievement. *Journal of the European Economic Association*, *2*(2), 406-415.

Hanushek, E. A., & Raymond, M. E. (2005). Does school accountability lead to improved student performance? *Journal of policy analysis and management*, *24*(2), 297-327.

Jacob, B. A. (2005). Accountability, incentives and behavior: The impact of high-stakes testing in the Chicago Public Schools. *Journal of Public Economics*, *89*(5), 761-796.

Jones, K. (2004). A balanced school accountability model: An alternative to high-stakes testing. *Phi Delta Kappan*, *85*(8), 584.

Jones, R. (1992). The development of conceptual frameworks of accounting for the public sector. *Financial Accountability & Management*, *8*(4), 249-264.

Levin, H. M. (1974). A conceptual framework for accountability in education. *The School Review*, *82*(3), 363–391.

Linn, R. L. (2003). Accountability: responsibility and reasonable expectations. *Educational Researcher*, *32*(7), 3–13.

Linn, R. L. (2004). Accountability models. *Redesigning accountability systems for education*, 73-95.

